**និស្សិតអាមេរិក ប៉ែន ពេជ្រសក្ខណា**

.....អ្នកនាងទីពីររបស់ពាណិជ្ជករ ប៉ែន ពេជ្រ ប្រាកដជាមានថេរវេលានៅក្នុងស្រុកតិចជាងនៅអាមេរិកក្នុងជីវិត ក្បែរ២៥ឆ្នាំរបស់នាង។
....ការលែងលះរបស់ឪពុកម្ដាយ គឺជារឿងដ៏ឈឺចាប់មួយ ដូច្នេះបន្ទាប់ពីបានអាយុ១៦ឆ្នាំ នាងបានប្រើលេសទៅក្រេបចំណេះដឹងនៅបរទេសដើម្បីគេចវេះចេញពីរឿង ដ៏គួរឲ្យទោមនស្សទាំងឡាយនៅកម្ពុជា។ ព្រឹកនេះនាងបង្ហាញខ្លួននៅភ្នំពេញ វាអត់មានអ្វីចម្លែកទេ ព្រោះថាបញ្ហារបស់ឪពុកកាលពីសប្ដាហ៍មុន បានជំរុញឲ្យនាងត្រូវតែរលះរលាំងវិលមកសួរសុខទុក្ខ។
....ធីតាអភិជនប្រហែលជានៅអាមេរិកយូរពេក បានជាវិធីបើកឡានរបស់នាងហាក់អន្ទះសាមិនស៊ីនឹងបរិវេណផ្លូវក្នុង ក្រុងភ្នំពេញដ៏តូចច្រឡឹងនេះឡើយរហូតដល់......ង៉ឹត.....ទាំងនាងទាំង ភាគីម្ខាងទៀតបានជាន់ហ្វ្រាំងពេញទំហឹងដូចគ្នា ហើយគេចទៅម្នាក់ម្ខាងទាំងសៅហ្មងផ្អើលអស់មនុស្សម្នាអ្នកដំណើរជិត ឆ្ងាយ។

.....ស្រីតូចសក្ខណាបុកដើមទ្រូងនឹងចង្កូតឡាន ទំហំឈឺចាប់មិនស្មើក្ដៅចិត្តទេព្រោះនាងគិតថាភាគីម្ខាងទៀត បើកបរខុសទាំងស្រុង។ ពិសេសទស្សនមនុស្សមកពីស្រុកអភិវឌ្ឍន៍ដូចនាងគឺនៅតែប្រកាន់ថា ពលរដ្ឋក្នុងស្រុកគ្មានភាពម្ចាស់ការគ្រប់គ្រាន់ក្នុងការបញ្ជាយាន ទេ។ អ្នកនាងទីពីរឈានចុះពីជំនិះដោយរុញទ្វារបិទទៅវិញគ្រាំងតាមទំហំ ចិត្តរបស់នាង ដែលក្ដៅឆាបឆួលទន្ទឹមពេលម្ចាស់រថយន្តបដិបក្ខក៏រុញទ្វារដើរចុះ មកដូចគ្នា។
....គេគឺជំនួយការរិទ្ធិដែលជានិច្ចកាលស្អាតសង្ហានិងស្ងប់ស្ងាត់ ។ អ្នកប្រុសទីពីររបស់ ហួត ស៊ីវ ចុះមកពីជំនិះដោយមានដបទឹកសុទ្ធក្នុងដៃហើយដើរតម្រង់ទៅកាន់ ស្រីតូចដែលកំពុងប្រត់ចង្កេះឱនពិនិត្យរថយន្តដ៏ទំនើបរបស់នាង។
គេហៀបនឹងហាមាត់គួរសមទៅកាន់នាង តែគ្មានឱកាសក្នុងការបញ្ចេញវាបានឡើយព្រោះថាធីតាអភិជនជះសម្ដីមកញាប់រន្ទើនះ
«អ្នកនៅភ្នំពេញគេ បើកឡានរបៀបហ្នឹងមែន?»

រឿងដែលពិបាកទទួលយកបំផុតគឺកាលដែលយើងមិនបានធ្វើខុស គេជាភាគីខុសហើយមកស្តីឲ្យយើងច្រែតៗកណ្តាលហ្វូងមនុស្ស ហើយរឹតតែពិសេសគឺគេជាក្មេងស្រីដែលសឹងថាមិនទាន់ជ្រុះពន្លៃពី ក្បាល។
គ្រាន់តែឃើញមុខនាងដែលសម្លក់មកក្លៃដោយឥតមានហេតុផល ជំនួយការរិទ្ធិអស់អារម្មណ៍ក្នុងការសួរសុខទុក្ខនាងទៅហើយ តែអ្នកនៅតែសង្កត់ចិត្តរក្សាឥរិយាបថជាសុភាពបុរសពោលសួរស្រាលៗ៖
«ឡានត្រូវត្រង់ណាខ្លះ?»
«ហ្នឹងហើយមនុស្សស្រុកខ្មែរ! មនុស្សមិនគិត ទៅគិតពីឡាន?»នាងនិយាយទាំងបញ្ចេញកំហឹងមក១០០ភាគរយដោយគ្មាន ហេតុផលធ្វើឲ្យរិទ្ធិចំហមាត់ផ្លុងលែងចេះប្រឈម។ ប៉ែន ពេជ្រសក្ខណាទោះយ៉ាងណាមិនអាចស្គាល់ម្នាក់នេះថាជាមនុស្សជំនិត របស់ឪពុកនាងឡើយម៉្លោះហើយបុរសនេះក៏គ្មានហេតុផលអ្វីស្គាល់នាងថា ជាអ្នកនាងទីពីររបស់ផ្ទះ ប៉ែន ពេជ្រ ដូចគ្នា។ សំឡេងនាងលាន់មកច្រែតៗបន្ថែមក្នុងពេលភាគីបុរសកាន់តែមានអារម្មណ៍លែងហ៊ានសម្លឹងគេឯងជុំវិញ៖
«លោករៀនបើកឡានពីសាលាមួយណា? គ្រូនោះមានប្រាប់ដែរទេ ថាផ្លូវនេះជាសិទ្ធិខាងខ្ញុំទៅមុន?ហើយចំណែកលោកយកមកខាងណេះ ចំពេលខ្ញុំកំពុងទៅដែរ បើកុំតែខ្ញុំចាប់ហ្វ្រាំងស្ទាត់ លោតែទៅប៉ះអាយុជីវិតអ្នកណាផ្សេង លោកមានអីទទួលខុសត្រូវបាន...?»
អ្នកប្រុសទីពីរនៅឈរស្ងៀមទ្រាំស្តាប់ពាក្យបន្ទោសញាប់រន្ថើន របស់ស្រីស្រស់ រហូតដល់មើលទៅនាងជាអ្នកនិយាយក៏ហត់ នាយជាអ្នកស្តាប់ក៏ស្តាប់លែងទាន់....

...ឃើញនាងនៅស្ងៀមវិញព្រោះហត់គឃូសលែងនិយាយរួច គេក៏ដាច់ចិត្តហុចដបទឹកទៅដោយទឹកមុខស្មើ ដឹងអីនារីមកពីប្រទេសជឿនលឿនរុញចេញហើយក្តាប់មាត់បន្តភ្លើង កំហឹងតាមរយៈបបូរមាត់តូចស្តើងបន្តភ្លាម...
«អរគុណហើយ! ត្រៀមបានល្អណាស់ហ្នមានទាំងទឹកសុទ្ធ! ហ្នឹងប្រហែលការបើកបរបំពានអ្នកដទៃទៅជាទម្លាប់ទៅហើយដឹង!»
អស់សំណើចហួសចិត្ត រិទ្ធិនិយាយវិញម្តង៖
«អ្នកនាង! សូមមើលផង អ្នកណាជិះចូលផ្លូវអ្នកណា? នៅតែបន្តិចទៀតអ្នកនាងប៉ះខ្ញុំត្រង់នេះហើយបើខ្ញុំគេចមិនទាន់....»

មិនឲ្យអ្នកប្រុសបានការពារសិទ្ធិរបស់ខ្លួននោះទេ នាងក៏បន្តភាពច្រៃតៗរបស់នាងទាំងទទឹងទិសទៀតធ្វើឲ្យរិទ្ធិ គ្រវីក្បាលលែងចេះនិយាយ គិតពីឈរស្តាប់នាងទាំងសើចហួសចិត្ត ព្រោះនាងដឹងតែពីសូត្រឃ្លាយកឈ្នះមិនដឹងទិសតំបន់រហូតដល់ស្អក កក៏ក្អកខេះៗ ហើយលូកដៃមកកញ្ជក់យកដបទឹកពីដៃនាយទៅក្រេបកណ្តាលហ្វូងមនុស្ស ធ្វើឲ្យអ្នកប្រុសរបស់អគ្គទេសាភិបាលអស់ពីខឹងទៅជាជ្រួញចិញ្ចើម ក្រពាត់ដៃមើលនាងទាំងហួសចិត្ត។

«បងរិទ្ធិមានរឿងអី?»

សំឡេងពៅបញ្ញាលាន់មកពីក្រោយខ្នងធ្វើឲ្យអ្នកប្រុសទីពីរងាកទៅរក អ្នកនាងតូច។ នាងប្រហែលឆ្លងកាត់ឃើញឡាននាយចតចោលនាថ្នល់ម្ខាង ហើយក៏ចុះមកមើលព្រោះបារម្ភ។ អ្នកដកដង្ហើម យូរនិយាយប្រាប់ថៅហ្វាយស្រីជាម្ចាស់បេះដូងវិញ៖

«រឿងយល់ច្រឡំទេអ្នកនាង»

សក្ខណាព្រិចភ្នែកហើយឈ្លក់ទឹកដែលកំពុងក្រេបពាក់កណ្តាល ព្រោះមិនពេញចិត្តនិងការចាត់ទុកថាហេតុការណ៍នេះជារឿងយល់ច្រឡំ នាងងើបមុខសម្លឹងប្រុងថានិយាយបន្ថែមតែក៏វេភ្នែកទៅប៉ះនឹង មេធាវីក្នុងវ័យស្របាលគ្នា។

ធីតាអភិជនកាចឆ្មើមប្តូរទឹកមុខ ហើយបន្ទន់សូរសំឡេង នាងភ្លាត់មាត់៖

«ពៅបញ្ញា?»

«សក្ខណាទេ?»

នារីទាំងពីរបានស្គាល់គ្នានៅអាមេរិក ព្រោះពួកគេចំណាយជីវភាពដ៏ឯកោនៅទីនោះជាច្រើនឆ្នាំដូចគ្នា ដូច្នេះហើយទំនាក់ទំនងរវាងពួកនាងអាចថាល្អជាងគេក្នុងចំណោមបង ប្អូនទាំងប្អូន។

«ឯងនៅទីនេះល្អហើយ ជួយcallហៅពួកInsuranceឲ្យមកធ្វើការជាមួយម្នាក់នេះទៅ!»

នាងនៅតែស្តីបន្តដោយមានះធ្វើឲ្យពៅបញ្ញាលបមើលមុខរិទ្ធិ ហើយទៅជាអស់សំណើចខឹកមុនពេលនិយាយប្រាប់ទៅបងស្រីរួមឪពុក៖

«សក្ខណា! គ្នាឯងទេ! នេះបងរិទ្ធិ មនុស្សជំនិតរបស់ប៉ា!»

ស្រីស្អាតបង្អង់ភាពកាចឆ្នាសហើយវេភ្នែកមករករិទ្ធិសាជាថ្មី។ បុរសងាកមុខចេញក្នុងភាពថ្លៃថ្នូរ ចំណែកនារីបែរជាបូញមាត់ខ្សឹបដាក់ប្អូននាង៖

«គេនេះហ្អី???»

ពៅបញ្ញាញញឹមៈ
«តោះឡើងឡានវិញមុនពេលប៉ូលិសមកដល់!»
«ហើយចុះឯងទៅណា? ខ្ញុំកំពុងចង់ទៅផ្ទះឯងជួបសួរសុខទុក្ខលោកប៉ា!»
ពៅបញ្ញាប្រែទឹកមុខ នាងនិយាយតបតិចៗៈ
«ទៅជាមួយគ្នាទៅ លោកប៉ាមិននៅផ្ទះទេ លោកទៅក្រៅជួបភ្ញៀវ!»
«ភ្ញៀវ??»
ពៅបញ្ញាជៀងភ្នែកផងមើលមករិទ្ធិ។ តាមពិតនាងក៏ទើបតែឮជំនួយការវណ្ណៈខលមកប្រាប់ដែរថានៅសុខៗ ព្រឹកនេះឪពុកខ្លួនសុំណាត់ជួបយុត្តនាដើម្បីអរគុណគេរឿងMr Johan។ ឮកាលណានាងក៏ប្រញាប់ទាក់ទងរករិទ្ធិហើយនាំគ្នាចោលការងារចេញទៅ ទីនោះភ្លាម ព្រោះបារម្ភធំបំផុតគឺរឿងយុត្តនាមិនឃោគយល់បែរជានិយាយអ្វីមួយ ធ្វើឲ្យប៉ះទង្គិចអារម្មណ៍ឪពុកខ្លួនជាយថាហេតុ។
ពេលនេះត្រូវបងស្រីដេញដោលនាងក៏ទម្លាក់សំឡេងនិយាយតិចៗៈ
«គឺជួបមនុស្សដែលបានជួយលោកប៉ារឿងលុយ១១លាននោះ!»
«អូ! អ្នកណាទៅ?»
ពៅបញ្ញាមិនឆ្លើយតបព្រោះតឹងចិត្តនិមិត្តតែនឹកឃើញដល់បុរសនោះកាលណា។ ស្រាប់តែសក្ខណាបន្ថែមមកភ្លាមៈ
«តោះ!! ទៅហ្មងទៅខ្ញុំក៏ចង់ឃើញគេដូចគ្នា!»
ស្រីតូចរវើរភ្នែករកធុងសំរាមនឹងចោលដបទឹកសុទ្ធមិនបាន ក៏ងាកមករកបុរសដែលលែងរវល់នឹងនាង តែនៅឈរនៅក្បែរនោះនៅឡើយ។
នាងដើរទៅរកគេហើយហុចដបទឹកដាក់ទៅក្នុងដៃគេវិញដោយមុខស្មើ មិនខ្ជីសូម្បីតែពោលពាក្យថាអរគុណ ឬសូមទោសធ្វើឲ្យពៅបញ្ញាដែលតាមមើលហួសចិត្តនិយាយលែងចេញគិតតែ មើលប្រតិកម្មរិទ្ធិហើយទើបតឿនប្តូរបរិយាកាសៈ
«តោះបង! យើងទៅ!»

...រថយន្តទំនើបទាំងបីបោលរឹងឆ្ពោះទៅកាន់គោលដៅ ដែលត្រូវបានរាយការណ៍មកប្រាប់ដោយជំនួយការវណ្ណៈ។ គេគឺនៅទីនោះកំដរឧកញ៉ាប៉ែនពេជ្រក្នុងការរង់ចាំជួបយុត្តនា។
....ពៅបញ្ញានិងសក្ខណាដើរកាត់សួនឧទ្យានដ៏ស្រស់បំព្រងនៃភោជនីយដ្ឋាន លំដាប់អភិជន

ដែលនៅទីនោះនាងគិតថាយុត្តនានិងលោកឪពុកកំពុងនៅជួប គ្នានៅឡើយ ដែលកាន់តែគិត នាងចេះតែមានពិភាល់ថាមានរឿងអ្វីមួយមិនល្អហៀប នឹងកើតឡើង។
«នៅមិននៅ ម៉េចក៏លោកប៉ាណាត់ម្នាក់នោះចេញមក? ហើយហេតុអ្វីគេព្រមចេញមកស្រួលៗម្ល៉េះ? គេអាចនឹងបកអាក្រាតរឿងខ្ញុំនឹងគេបញ្ឈឺចិត្តលោកប៉ាដែរទេ?
ឯងគិតច្រើនពេកហើយពៅបញ្ញា កាលពីយប់មិញគេព្រមហើយចំពោះសំណូមពររបស់ឯង អនុស្សាវរីយកាលពីយប់មិញ ក៏មិនមែនមានន័យ ថាគេគ្មានចិត្តល្អខ្លះនោះដែរ! កុំបំភ័យខ្លួនឯងពេក!»
នាងបន្ទូរដង្ហើមដកអារម្មណ៍ចេញពីភាពតានតឹង ហើយងើបមុខវាក់អីនឹងអ្នកណាម្នាក់ដើរសំដៅមកក្នុងទិសដៅផ្ទុយគ្នា។ គេប្រហែលឃើញនាងមុនបានជាបបូរមាត់គេញញឹម ទោះបីនាងមើលមិនឃើញភ្នែកគេ ព្រោះគេបិទបាំងដោយវ៉ែនតាខ្មៅក៏ដោយ។
«គេចេញមកវិញហើយ?»

នោះគឺយុត្តនាបុរសម្នាក់ដែលកាលពីយប់មិញនាងបាននៅជាមួយគេជាង មួយម៉ោងជាមួយទំនាក់ទំនងចម្លែកមួយដែលមានទាំងក្តៅមានទាំង ត្រជាក់។
គេដើរហួសនាងទៅដោយមិននិយាយស្តីអ្វីប្រហែលដោយសារឃើញនាងមាន មនុស្សនៅក្បែរ តែគេងាកមករកនាងជាមួយស្នាមញញឹមមុនពេលចាកចេញទៅ។
«ម្នាក់នោះសើចដាក់ឯងពៅបញ្ញា!....ចង់តែសួរទេ ...គេហ្នឹងជាតារាឬស្អីដែរពាក់វ៉ែនតាខ្មៅអត់ទំនង»
នេះជាទម្លាប់ពូកែទើសទាល់របស់សក្ខណា។ ទោះយ៉ាងណាលើកនេះពៅបញ្ញាគ្មានអារម្មណ៍ឯណានឹងតបសម្តីនាងឡើយ ព្រោះហាក់ក្តុកក្តួលចិត្តចង់ដឹងពីជំនួបរបស់បុរសនោះនិងឪពុកនាង ជាទីបំផុតទៅហើយ។

មិនទាន់អីផងនាងឮសក្ខណារអ៊ូមកបន្ត៖
«ចំណែកជំនួយការលោកប៉ាម្នាក់នោះវិញចតឡានមិនទាន់រួចទៀតមើលទៅ យឺតជាងទាំងស្រីៗទៀត! របៀបបើកឡានអន់ម្លឹងៗ.....»
ស្នូរទូរសព្ទពៅបញ្ញាលាន់ឡើងកាត់ផ្តាច់សម្តីនិស្សិតអាម៉េរិកាំងវ័យ២៥ឆ្នាំ។ ពៅបញ្ញាទទួលមកភ្លាម៖
«បង!? បងណ: មានការអី?»

«អ្នកនាង! លោកឧកញ៉ាមានបញ្ហាហើយ!!»
ពៅបញ្ញារវេភ្នែកដោយអន្ទះសាហើយប្រែទឹកមុខទៅជាស្លេកៈ
«បងនៅទីនោះមែនអត់? ខ្ញុំជិតដល់ហើយ!»
នាងដាក់ទូរសព្ទចុះ ហើយងាកមកតឿនសក្ខណាៈ
«លោកប៉ាមានរឿងហើយ!»

ស្រីអ្នកច្បាប់បន្ថែមល្បឿនជើងរត់ត្រឹកៗតម្រង់គោលដៅ ដោយមានបងប្អូនស្រីម្ដាយទីទៃមកជាមួយផង។ នាងមកដល់បរិវេណភោជនីយដ្ឋានដែលរុំព័ទ្ធដោយមនុស្សម្នាប្រមាណជាង ១០ នាក់ ...បេះដូងនាងស្ទើរគាំងចលនាដោយសារមនុស្សទាំងនោះហាក់ដូចកំពុង ចោមរោមអ្វីមួយមុនពេលត្រូវសន្តិសុខបំបែកចេញ។ ស្រីស្អាតរបូតកាបូបខ្សាក ពេលដែលនាងឃើញរូបរាងអ្នកមានគុណដែលទន់ខ្សោយទើបបានធូរស្រាលពីជំងឺ ត្រូវសន្លប់ស្ដូកស្ដឹងសាជាថ្មី ក្នុងដៃជំនួយការវណ្ណៈ។
«ប៉ា???»
សក្ខណាស្រែកភ្លាត់សំឡេងហើយរត់ចូលទៅក្នុងពេលដែលពៅបញ្ញាមិនអាចសូម្បីនិយាយចេញមួយម៉ាត់។
ស្នាមញញឹមពីក្រោមវ៉ែនតាខ្មៅរបស់យុត្តនាលេចឡើងផ្ទួនៗដុតរោល អារម្មណ៍នាង ហើយធ្លាក់ថ្លើមក្ដុកដែលកាលពីយប់មិញនេះលង់ជឿទុកចិត្តកាយវិការ ទន់ភ្លន់របស់គេ។
«បងរិទ្ធិ! បងរិទ្ធិ! បងរិទ្ធិ! បងរិទ្ធិនៅឯណា»
ពៅបញ្ញាស្រែកហៅដោយរន្ធត់ព្រមទាំងងាករំពៃជុំវិញខ្លួនផង។ គេជាមនុស្សតែម្នាក់គត់ដែលនាងនឹកឃើញក្នុងពេលចលាចលបំផុត។
ជំនួយការរិទ្ធិបោះជំហានវែងៗមកដល់ជាមួយទឹកមុខភ្ញាក់ផ្អើល។ គេង៉េមង៉ាមចំពោះហេតុការណ៍នេះ តែគេនៅតែចិត្តនឹងបានរហូតដល់ទូរសព្ទទៅរកឡានពេទ្យភ្លាមៗក្រោម កែវភ្នែកតក់ស្លុតនៃកុលធីតាអភិជនទាំងទ្វេ។

## ១៦

គំនុំស្នេហ៍រ៉ៃយចំណាស់

....រ៉ឹងៗ.....
ស្នូរទូរសព្ទនាពេលរំលងអធ្រាត្រដូច្នេះ ពេលធម្មតាគឺអាចធ្វើឲ្យ ហួត ស៊ីវ ខឹងច្រឡោត តែលេខរបស់ជំទាវកុសុមាគឺជាទឹកឃ្មុំកំដរចិត្តគាត់ទៅវិញ។ ទោះយ៉ាងនោះក៏ដោយគាត់ក៏មានអារម្មណថាចម្លែក ប្រសិនបើមិនមានហេតុភេទអ្វីកើតឡើង ស្ត្រីត្រកូលហ្លួងមិនសមថារំលងរបៀប ហើយទាក់ទងមកថ្មើរណេះឡើយ។ អ្វីដែលអភិជនសខ្មែរចិននឹកគិតព្រួយបំផុតពេលនេះគឺ ប៉ែន ពេជ្រប្រាថ្នានិងប្អូនស្រីអមរា។ កូនទាំងពីររបស់គាត់ទោះបីធំដុះស្លាបហើយ តែក្នុងបេះដូងឪពុកម្នាក់ ពួកគេនៅតែជាកូនក្មេង ដែលត្រូវការការពារ។ ប្រសិនបើកណ្តាលរាត្រីស្ត្រីនោះ ប្រាប់ថាយុវជនយុវនារីទាំងទ្វេមានហេតុភេទអ្វីកើតឡើង ហួត ស៊ីវ នឹងគាំងបេះដូងមិនខាន។
បុរសចំណាស់ខ្វះស្នេហ៍លូកដៃទទួលដោយគ្រហែមយកសំឡេងផង៖
«អាឡូ!....»
«ល្អហើយដែលលោកមិនទាន់សម្រាន្តស៊ីវ!»
«កុសុមាមានការអី?»
ពាក្យគាត់ដែលហៅឈ្មោះនាងនិងសំនួរដ៏ខ្លីតែបង្កប់ន័យឈឺឆ្អាលហួស បានជួយបង្អន់កំហឹងក្នុង ចិត្តស្ត្រីអភិជន។ លោកជំទាវតបវិញមួយៗ៖
«កូនប្រុសលោក អប់រំបានល្អណាស់! ខ្ញុំចង់និយាយពី ហួត យុត្តនា!»
ហួត ស៊ីវ រវៃភ្នែកគិតទាំងងឿងឆ្ងល់ គាត់មិនទាន់ហាស្តីអ្វីទេគឺនៅរង់ចាំស្តាប់ដំណើររឿង។ លោកជំទាវបន្តមកភ្លាម៖
«ប៉ែន ពេជ្រ ទើបតែចេញពី ICUមកទេ! គឺជាង១០ម៉ោង បន្ទាប់ពីកូនប្រុសលោកបានទៅធ្វើទុក្ខគាត់»

ហួត ស៊ីវ ទទួលអារម្មណ៍ពីរក្នុងពេលព្រមគ្នា ទីមួយគឺត្រូវសប្បាយដែលកូនប្រុសធម៌ពិតជាបានដូចចិត្ត ចំណែកទីពីរគឺត្រូវទោមនស្សព្រោះស្រីដែលគាត់ស្រលាញ់ មើលទៅនៅតែឈឺឆ្អាលចំពោះអតីតស្វាមីនាង។
ម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុធំបំផុតនេះឆ្លើយវិញផ្ទូងទាំងច្រណៃនប្រចណ្ឌ៖
«វាចាស់ហើយ! ស្លាប់ទៅក៏អត់ទាស់អីដែរ!»
រក្សាភាពស្ងប់ស្ងាត់ពេលដែលខឹងបំផុតគឺជាទម្លាប់របស់ជំទាវកុសុមា ដ៏ស្រស់ទ្រលុក។ នៅ

ពេលដែលគ្មានការតបមកវិញតាមទូរសព្ទ ហួត ស៊ីវ ដឹងស្រេចហើយថានាងកំពុងខឹងដល់ថ្នាក់មិនហើបបបូរមាត់ក្រហមដូច សេកនោះទេ ហើយដើម្បីទ្រូងនាងគឺជង្គក់ដោយសារប្រឹងទប់ទោសៈ។

គាត់សើចឌឺនិងនិយាយបន្ថែម៖

«Callមកកណ្ដាលយប់ ស្មានថាមានអីល្អ! ដឹងអីនៅមិនដាច់អាល័យពីប្ដីចាស់សោះ?»

ដឹងថាបុរសនេះចាស់ដល់ថ្នាក់ព្រើលនៅមិនចោលចរិតសេចក្ដីប្រចណ្ឌ ជំទាវស្រស់ស្អាតក្រើនរំលឹកគាត់ទាំងកំហឹង៖

«លោកមើលពណ៌សក់ខ្លួនឯងក្នុងកញ្ចក់ផងទៅស៊ីវ! ថ្មើរណេះហើយលោកយករឿងស្អីមកនិយាយ??? ខ្ញុំ Callនេះចង់ប្រាប់លោកថា ចរិតកូនប្រុសរបស់លោកកាន់តែពេញភ្នែកខ្ញុំក្នុងការលើកកូនស្រីឲ្យ គេណាស់! និយាយឲ្យខ្លី លោកកុំសង្ឃឹមអារឿងឲ្យអមរាទៅធ្វើវាសនាជាមួយប្រុសធុនហ្នឹង! ម្យ៉ាងទៀតក៏គ្មានស្រីឯណា ទៅការជាមួយមនុស្សដែលធ្វើឲ្យប៉ាគេដេកICUនោះដែរ!»

«អញ្ចឹង ចាំប្រាប់ឲ្យគេដឹងគ្រប់គ្នាទៅថា អាពេជ្រមិនមានជាឪវាទេ ! ឪវាកំពុងដេកឈឺចាប់ដេកឯកោនៅឯណេះ!»

ជំទាវខឹងពេញបន្ទុក នាងខាំមាត់និយាយសង្រ្កឹត៖

«លោកនៅវង្វេងម្នាក់ឯងទៅស៊ីវ! តែខ្ញុំគ្រាន់តែផ្ដាំខ្លី ក្មេងបាតសង្គមនោះ គ្មានថ្ងៃបានធ្វើកូនប្រសាខ្ញុំទេមិនថាលោកប្រើវិធីអ្វីក៏ដោយ !»

ស្ត្រីអភិជនទម្លាក់ទូរសព្ទចុះមិនបានយល់ដល់បេះដូងអតីតសង្សារដែលនៅក្ដៅងំដោយភាពច្រណែននោះទៀតឡើយ។

ហួត ស៊ីវ ក្រោកអង្គុយផ្អែកគ្រែទាំងទោមនស្ស គាត់ក្រពាត់ដៃខាំបបូរមាត់។

«នាងខឹងយ៉ាងនេះ ព្រោះអាណិតអាពេជ្រមែនអត់កុសុមា?»

ដៃគាត់រាវចុចទូរសព្ទទៅរកកូនប្រុសទីពីរ....

«ជម្រាបសួរលោកប៉ា!»

«នៅពេទ្យនៅឡើយហ្អីកូន?»

«បាទ! លោកប៉ានៅមិនទាន់សម្រាន្តទៀត?»

«ប៉ាទើបតែឮរឿងអាពេជ្រ! រឿងហេតុវាយ៉ាងម៉េចខ្លះកូន!»

«ទើបចេញពី ICU មួយម៉ោងមុននេះទេ! មិនទាន់ដឹងខ្លួនឡើយ!»
ហួត ស៊ីវ សើចខឹកទម្លាយភាពមួហ្មង៖
«ទេវតាអើយទេវតា នៅកាន់ជើងវាដល់អង្កាល់ទៀត»
ប្រហែលរិទ្ធិរឹតតែតឹងទ្រូងហើយពេលឮវាចានេះបានជាអ្នកនៅស្ងៀម បណ្ដោយឲ្យឪពុកធម៌វាចាមកបន្ថែមដូចមនុស្សមានគំនុំប៉ុនមហា សមុទ្រ៖
«មានគ្រោះច្រើនដងនៅតែមិនអី តើវាសំណាងឬខ្ញុំមិនទាន់បានលេងឲ្យធ្ងន់ដៃ?»

ឃើញរិទ្ធិនៅតែរក្សាភាពស្ងប់ស្ងាត់ ឪពុកធម៌បង្វែរសំណួរទៅកាន់នាយ៖
«ប្រាថ្នានិងអមរានៅទីនោះទេ?»
«ទើបតែត្រលប់ទៅផ្ទះវិញមុននេះ!»
ហួត ស៊ីវ សើចក្អាកក្អាយ៖
«សមមុខវាហើយ ដែលចុងក្រោយដង្ហើមចង្រិតគ្មានកូននៅជិត! វាមានអីគ្រាន់ជាងប៉ាទៅ? វានៅតែយ៉ាប់ព្រោះជំនួយការដែលនៅក្បែរវាឥឡូវនេះក៏ជាកូនប្រុស របស់ប៉ាទៀត!»
រិទ្ធិនិយាយកាត់ស្រាលៗ៖
«អ្នកនាងពៅបញ្ញានិងសក្ខណានៅទីនេះដែរមិនទាន់ទៅវិញទេ!»
ហួត ស៊ីវ ធ្វើមុខមាំពេលឮសូរឈ្មោះក្មេងស្រីទាំងពីរ។ គាត់គឺគ្មានអារម្មណ៍អ្វីជាមួយពួកនាងក្រៅតែពីស្អប់ទេ ព្រោះសរសៃឈាមដែលរត់ចុះឡើងក្នុងបេះដូងក្មេងស្រីទាំងពីរគឺជា ឈាមរបស់មនុស្សដែលគេស្អប់។ ឮតែឈ្មោះមេធាវីពៅបញ្ញា គេនឹកដល់កូនប្រុសច្បងដែលទើបតែបានឡើងគ្រងតំណែងថ្មីៗ។
«កូនឯងធ្វើបានល្អយុត្តនា!»
ហួត ស៊ី គិតតែគាត់មិននិយាយពាក្យនោះចេញមកទេ ព្រោះមិនចង់សរសើរកូនម្នាក់នៅមុខម្នាក់ទៀត។ គាត់បង្វែរទៅធ្វើជាសួរ៖
«យុត្តនាធ្វើរឿងនេះរបៀបម៉េច?»
រិទ្ធិវេភ្នែកគិត។ គេសម្លឹងទៅពៅបញ្ញាដែលនៅក្បែរអគារពីរនាក់សក្ខណាដោយមុខ ស្រពោន។សភាពរបស់នាងគឺឃើចាប់និងមានវិប្បដិសារី។ នាងមិនយំដូចសក្ខណាព្រោះនាងឆ្អែតចិត្ត។ ហើយរិទ្ធិយល់រឿងនេះជាងអ្នកណាទាំងអស់។ គេតបនឹងឪពុកធម៌តិចៗ៖
«គាត់ចង់ជួបអរគុណយុត្តនា! អត់មានអ្នកណាដឹងថាពួកគេជួបគ្នាហើយបាននិយាយអ្វីទេ!

ប៉ុន្តែពេលយុត្តនាចេញបានបន្តិច គាត់ស្រែកហៅជំនួយការម្នាក់ទៀតក្បែរនោះ បន្ទាប់មកក៏សន្លប់!គ្រប់គ្នាគិតយុត្តនានិយាយអ្វីមិនល្អបញ្ឈឺ គាត់ ពិសេសពៅបញ្ញា នាងយល់ថាយុត្តនាបានយករឿងរបស់នាងគ្រប់សព្វទៅបញ្ឈឺឪពុកនាង!»
«អញ្ចឹងមិនល្អ???»ហួត ស៊ីវ និយាយលាយសំណើច។
«បងរិទ្ធិៗ»សំឡេងពៅបញ្ញាហៅមកល្វើយៗកណ្ដាលរាត្រីធ្វើឲ្យ ហួត ស៊ីវ ផ្អាកសំណើចផ្ទៀងស្ដាប់។ សំឡេងកូនប្រុសទីពីរលាន់មកខ្សឹបៗ៖
«គេហៅខ្ញុំ! ប្រហែលឧកញ៉ាមានអីប្រែប្រួលហើយ កូនជម្រាបលាសិនលោកប៉ា»
«បាន! ទៅចុះកូន! តែ....រិទ្ធិអ្ហា....»
គេនៅទ្រឹងនឹងពាក្យហៅឃាត់របស់ឪពុក។ សំឡេងគាត់ស្រាលៗតែរិទ្ធិគិតថាគាត់កំពុងមានគំនិតអ្វីម្យ៉ាង។
«គាត់មិនមែនបង្ខំយើងឲ្យឆ្លៀតឱកាសនេះសម្លាប់ ប៉ែន ពេជ្រ ទេដឹង?»នាយគិតទាំងបារម្ភ។ ហួត ស៊ីវ និយាយមកបន្ថែមមួយៗតែច្បាស់ៗ៖
«ពុកមិនខ្វល់ថាវារស់ឬស្លាប់ទេ! និយាយរួមនេះជាឱកាសដែលផ្ទះវាកំពុងច្របូកច្របល់កូនត្រូវស្រូតពី រឿងគម្រោងការរតនៈសោភ័ណ!»

រិទ្ធិផ្ទុះចេញភាពព្រួយបារម្ភទ្វេតាមពន្លឺភ្នែក។ គេដឹងថាវាចាឪពុកធម៌ដូចជាមានជំនឿចិត្តពីតម្រុយនៃវត្ថុនោះថា អាចនឹងមានអ្នកក្នុងផ្ទះណាផ្សេងម្នាក់ទៀតបានដឹងដែរក្រៅពី ខ្លួនបុរសដែលកំពុងដេកឈឺតែក៏អាចមានន័យឲ្យគេប្រយ័ត្នថា នៅពេលដែលសុខភាពខ្លួនមិនធានាប៉ែនពេជ្រអាចនឹងព្រមទម្លាយបញ្ចេញ អាថ៌កំបាំងនោះប្រាប់ដល់កូនស្រីសំណព្វក្នុងពេលឆាប់ៗនេះក៏ថាបាន?
ហួត ស៊ីវ បិទទូរសព្ទចោលទុកឲ្យកូនប្រុសទីពីររត់ត្រឹកៗត្រលប់ទៅកាន់បន្ទប់អ្នកជំងឺវិញទាំងតឹងណែនដោយចំណោតបញ្ហា។
«បងរិទ្ធិ!! លោកប៉ាដឹងខ្លួនហើយគួរហៅពេទ្យទេ?»
ពៅបញ្ញាស្ដីទាំងរលះរលាំងលាយអំណរ។
រិទ្ធិរវេភ្នែកកាត់របាំងកញ្ចក់ សម្លឹងទៅបុរសចំណាស់នៅខាងក្នុងដែលប្រែប្រួលរាងកាយតិចៗក្រោម ទឹកមុខភ័យស្លឹតស្លក់ភ័យផងអរផងរបស់កូនស្រីពៅផ្ទះធំ ប៉ែន ពេជ្រសក្ខណា។
«លោកប៉ា???»

រិទ្ធិនិយាយតិចៗដាក់ពៅបញ្ញាជាមួយភាពរីករាយក្នុងកែវភ្នែកទាំងសងខាង៖
«លោកឧកញ៉ាលែងអីហើយ!»
អ្នកទាំងពីរស្ទុះចូលទៅខាងក្នុងបន្ទប់.....

១៧

យុត្តនាធ្វើបាបប៉ែនពេជ្រ?

«នេះជាថ្នាំបង្កើនចលនាបេះដូង! ថ្នាំនេះមើលទៅមិនមានគ្រោះថ្នាក់ទេប្រសិនបើគេប្រើវាតាម វេជ្ជបញ្ជា ប៉ុន្តែប្រសិនបើប្រើទៅលើអ្នកមានបញ្ហាបេះដូងនិងសម្ពាធឈាម ហានិភ័យគឺខ្ពស់!»
ប៉ូលិសក្មេងដែលនៅអង្គុយពីមុខរិទ្ធិជាមួយឯកសារមួយខ្ទាស់ក្នុងដៃ និយាយដោយទឹកមុខនឹងន។
នៅពេលអ្នកប្រុសទៅពីរលើកសំណុំឯកសារមកអាននិងពិចារណាដោយស្ងាត់ស្ងៀម គេនោះនិយាយបន្ថែម៖
«ពេលដែលក្រុមយើងឆែកកាមេរ៉ាភោជនីយដ្ឋានគឺចន្លោះរវាងពេល៣០វិនាទី ដែលហួតយុត្តនាចាកចេញពីឧកញ៉ាប៉ែនពេជ្រ គាត់បានលើកដបទឹកពិសេសរបស់គាត់ហូបពីរដង! យើងសង្ស័យថា ថ្នាំត្រូវបានគេដាក់នៅក្នុងដបនោះ ហើយអ្នកដាក់ ប្រាកដជាមិនមែន ហួតយុត្តនា ទេ។»
«មានអីបញ្ជាក់ទេ?»
នេះជាសំណួរដំបូងគេដែលអ្នកប្រុសទីពីរហាចេញមកបន្ទាប់ពី រក្សាភាពនឹងនជាច្រើននាទីមកហើយក្នុងការស្តាប់របាយការណ៍ប៉ូលិស។
«មាន!»
សមត្ថកិច្ចដែលគ្រងដោយសំលៀកបំពាក់ស៊ីវិលបញ្ចេញទឹកមុខម៉ឺងម៉ាត់។ គេងាកឆ្វេងស្តាំហើយបង្ហាញវីដេអូមួយឈុតតាមទូរសព្ទពីមុខរិទ្ធិ។
មើលវាចប់ក្នុងពេលមិនដល់១០វិនាទី រិទ្ធិដកដង្ហើមយូរ៖
«គឺម្នាក់នេះអ្ហេះ?»
ប៉ូលិសងក់ក្បាលផ្ងក់ៗហើយឆ្លើយតប៖
«អ្នករត់តុម្នាក់នេះជាប់សង្ស័យជាងគេ។ ក្នុងពេលលោកឧកញ៉ាដួលសន្លប់ គេស្រូតមកប្តូរ

ដបទឹករបស់គាត់ចេញ! អ្វីៗគឺគេគ្រោងទុកមុន លោកមើលចុះដបទឹកនៅកន្លែងដដែលតែចំណុះវាខុសគ្នាបន្តិច! សរុបមកវិញគឺគេប្តូរវាចេញមុនពេលប៉ូលិសមកដល់!»
«ចុះម៉េចដឹងថាក្នុងទឹកមានថ្នាំ?»
«ព្រោះថា នៅសុខៗគេរត់មកប្តូរដបទឹក! ហើយក្នុងឈាមលោកឧកញ៉ាប៉ែនពេជ្រមានបន្សល់នៅសំណល់សារធាតុរំញោច នេះ! ជាប្រភេទសារធាតុដែលគេអាចច្របល់តែក្នុងវត្ថុរាវប៉ុណ្ណោះវាធ្វើឲ្យយើងមិនពិបាកយល់ទេថា សកម្មភាពដូរដបទឹកចេញនិងជាតិថ្នាំក្នុងឈាម គឺមានការទាក់ទងគ្នា!»
រិទ្ធិបើកភ្នែកមូលក្លំព្រោះយល់សាច់រឿង តែគេនៅតែប្រឹងបញ្ជាក់៖
«បើអញ្ចឹងយើងគ្មានភស្តុតាងចោទអ្នករត់តុនោះទេមែនទេ? ព្រោះយើងគ្មានដបទឹកពិតដែលមានជាតិថ្នាំនៅទីកើតហេតុ!»
ប៉ូលិសសើចចុងមាត់បែបខែងរ៉ែងរួចទើបងាកមកឆ្លើយច្បាស់ៗ៖
«ត្រូវហើយ ព្រោះយើងមិនចង់ចោទគេ តែយើងចង់រកអ្នកដែលបញ្ជាគេ!»
រិទ្ធិអង្គុយត្រង់ខ្លួនព្រោះយកចិត្តទុកដាក់នឹងសម្តីចុងក្រោយនេះ។ គេសួរបកទៅប៉ូលិសវិញ៖
«តែ File Video នោះអាចឲ្យយើងហៅម្នាក់ហ្នឹងមកសួរនាំបានមែនទេ!»
ប៉ូលិសស្លៀកពាក់ស៊ីវិលសើច៖
«បងរិទ្ធិឯង សមតែជាប៉ូលិសទេ!»
រិទ្ធិមិននិយាយមួយម៉ាត់ទៀតសោះ តែគេរវេភ្នែករិះគិត។
«តើនេះជាគ្រោះថ្នាក់ដែរទេ? ប្រសិនបើអ្នកនៅពីក្រោយជាយុត្តនាឬជា.....លោកប៉ា....ការស៊ើបនេះមិននាំទុក្ខដល់ពួកគេ?»
នៅពេលរិទ្ធិរក្សាការស្ងៀមស្ងាត់ គេងើបមុខសម្លឹងមកកាន់ប៉ូលិសទោះមិនបាននិយាយស្តីអ្វី។ក្រសែភ្នែក ប៉ូលិសហាក់រង់ចាំតែសញ្ញាភ្លើងខៀវពីនាយប៉ុណ្ណោះ។
រិទ្ធិរេខ្លួនដកសែកពីហោប៉ៅហើយស៊ីញេហុចឲ្យគេ ប៉ូលិសនោះបង្ហាញភាពរីករាយ គេលូកដៃទទួលរឹងហើយនិយាយអម៖
«ខ្ញុំនឹងធ្វើឲ្យបានឆាប់បំផុត!»
រិទ្ធិនិយាយកាត់ដោយទឹកមុខស្មើ៖
«អត់ទេ! ....ខ្ញុំចង់និយាយថា យើងផ្អាកការស៊ើបនេះសិន!»
ប៉ូលិសឯកជនជ្រួញចិញ្ចើមងឿងឆ្ងល់។

ទឹកមុខគេធ្លាយចេញនូវសំណួរជាស្រេចថា បើមិនឲ្យស៊ើប ឲ្យលុយធ្វើអីច្រើនម្ល៉េះ? តែគេមិនហ៊ានហាស្តីបានត្រឹមនៅធ្វើភ្នែកភ្លឹះៗមើលមុខម្ចាស់ លុយ។
រិទ្ធិបញ្ចប់ភាពរារែករបស់គូសន្ទនា គេសង្កត់ពាក្យធ្ងន់តាមរយៈសំឡេងស្រាលៗ៖
«ខ្ញុំគ្រាន់តែអត់ចង់អូសទូកកុំឲ្យល្អាន.....! ដល់ពេលសមរម្យមួយ លោកគង់តែបានធ្វើការទេ!»
ប៉ូលិសដៀងភ្នែកមើលសន្លឹកសែកក្នុងដៃ គេផ្ទុះសំណើចហើយនិយាយតប៖
«ចង់ចាប់ត្រីបានកុំឲ្យល្អក់ទឹក! ខ្ញុំយល់តើ! អូខេ! ត្រូវការពេលណាទាក់ទងមកខ្ញុំបានគ្រប់ពេល!»

គេក្រោកទៅជាមួយសន្លឹកសែកក្នុងដៃ តែត្រូវរិទ្ធិពោលឃាត់៖
«ឈប់សិន! ....ខ្ញុំចង់និយាយថា រឿងនេះមិនអាចឲ្យអ្នកទីបីដឹងជាដាច់ខាត!»
ប៉ូលិសស៊ីឈ្នួលញាក់ស្មា៖
«នេះជាច្បាប់សំខាន់របស់ពួកខ្ញុំស្រាប់ហើយ! សូមធានា!»
គេចាកចេញទៅ តែបានបន្សល់ទុកនៅលើទ្រូងជំនួយការបង្កប់ នូវប្រស្នាមួយចំនួន។ បន្តិចក្រោយមករិទ្ធិក៏ក្រោករឹងបោះជំហានវែងៗចាកចេញពីទីនោះ ជាមួយសំណុំឯកសារក្នុងដៃ។ គោលដៅរបស់គេគឺផ្ទះយុត្តនា ប៉ុន្តែនៅតាមផ្លូវគេបានប្រទះឃើញរថយន្តរបស់ពៅបញ្ញា គេក៏ប្តូរទិសដៅជិះទៅតាមនាងស្ងាត់ៗ។
រសៀលជ្រាលជ្រេទៅហើយ ចរាចរណ៍នៅរាជធានីភ្នំពេញកាន់តែមមាញឹករហូតដល់ស្រីតូចមិនដឹង ថាជំនួយការឪពុកខ្លួនកំពុងតាមមកពីក្រោយទេ។ ជំនួយការវណ្ណៈដែលជាអ្នកបើកឡានជូនស្រីតូចរេចង្កូតបត់រឹងតាម ច្រកតូចមួយឆ្ពោះទៅរកក្លឹបស្នូកឺរដែលជាទីពេញនិយមសម្រាប់បុរស ស៊ីវិល័យ។
«ពៅបញ្ញាមករកយុត្តនាដល់កន្លែងនេះ? ពួកគេស្និទ្ធស្នាលដល់ថ្នាក់អាចរកគ្នាឃើញគ្រប់កន្លែងទៀត?»
រិទ្ធិសួរខ្លួនឯងក្នុងពេលដែលរថយន្តស្រីស្អាតស៊ីញ៉ូបត់។
គេរក្សាចម្ងាយពីនាងល្មមអាចបំបាំងខ្លួនបាន ហើយទីបំផុតគេចូលទៅរកយុត្តនាតាមទ្វារក្រោយបានមុន ព្រោះពៅបញ្ញានៅរវល់សួរនាំនិងសុំការអនុញ្ញាតពីពួកអ្នកយាម។
«ពៅបញ្ញានៅខាងក្រៅរកផ្លូវគេចសិនទៅ!»

យុត្តនាជ្រួញចិញ្ចើម គេងើបមុខសម្លឹងរិទ្ធិ ៖
«ហេតុអី?»
អ្នកប្រុសទីមួយសួរធ្វើហីព្រោះគេរកនឹកមិនឃើញថាហេតុអ្វីនាងមក ដល់ទីនេះ ហើយហេតុអ្វីបានជាគេត្រូវគេចខ្លួនតាមការបង្គាប់របស់បងប្អូន ធម៌។ រិទ្ធិរវេភ្នែកសម្លឹងពួកម៉ាកយុត្តនាម្នាក់ដែលកំពុងកំដរគេលេង ដោយនៅជ្រុងបន្ទប់ ស្រីស្អាតសិចស៊ីពីរនាក់ទៀតកំពុងចាត់ចែងចាក់ប៊ីយែរ។ ខ្សែភ្នែកអ្នកប្រុសទីពីរចង់បញ្ជាក់ថាមានរឿងសំខាន់ដែលអ្នកមិន អាចនិយាយនៅនឹងមុខមនុស្សទាំងអស់នេះឡើយ។

គេនៅស្ងៀមដោយមុខមាំ ធ្វើឲ្យយុត្តនាងាកទៅបង្គាប់ដៃគូរ៖
«ថ្ងៃនេះប៉ុណ្ណឹងសិនហើយ! មានការបន្តិច!»
បុរសនោះចាកចេញទៅព្រោះយល់ការ។ ចំណែកស្រីៗក៏ទាញកាបូបចាកចេញទាំងមិនសូវសប្បាយចិត្តដែរ។ ក្នុងបន្ទប់សល់តែពីរនាក់បងប្អូន យុត្តនាងើបចោលតាបស្នូគ័រហើយនិយាយដោយញញឹម៖
«ស្រីឆ្នាស់នោះមកធ្វើអី?»
រិទ្ធិរវេភ្នែករកមើលបន្ទប់ទឹក។ វាជាទិសដៅដែលគេនឹងសសៀរខ្លួនទៅនៅពេលបន្ទាន់នេះ។
«ប៉ាគេមិនទាន់ចេញពីពេទ្យរួចផង ឯងគួរយល់ហើយ!»
«ខ្ញុំអត់បានធ្វើអីតានោះទេ!»
«និយាយតែមាត់វាគ្មានបានការទេ! ទាល់តែរកអីមកបញ្ជាក់»
យុត្តនាសើចទាំងទឹកមុខងឿងឆ្ងល់ គេនិយាយបន្ថែម៖
«ស្អីគេ? អត់បានធ្វើអីក៏ត្រូវរកអីមកបញ្ជាក់ដែរ?»
ស្នូរស្បែកជើងកែងចោតដែលរិទ្ធិចំណាំច្បាស់ថាជាអ្នកណាបានលាន់ មកកៀកនឹងទ្វារ។ អ្នកប្រុសទីពីរបន្ថយសំឡេងមុនពេលសសៀរខ្លួនចូលទៅក្នុងបន្ទប់ ទឹក៖
«គេមកជម្រះបញ្ជីជាមួយឯងហើយ! បើមិនរត់ នៅចាំទទួលកម្អែលភ្នំភ្លើងទៅ!»
យុត្តនាចងចិញ្ចើមងាកទៅរកទ្វារ ។
បប្លូរមាត់នាយញញឹមក្នុងពេលបេះដូងរិទ្ធិលោតញាប់ជាងមុន។ ជាអាទិភាពគឺអ្នកមិនចង់ឲ្យនាងដឹងថាអ្នកកំពុងនៅទីនេះ ហើយនិងដឹងថាអ្នកជាមួយយុត្តនាជាបងប្អូនធម៌នឹងគ្នាដាច់ខាត។ គេនៅសំងំក្បែរទ្វារបន្ទប់ទឹក តែត្រចៀករំពៃស្តាប់សូរសព្ទនានាពីក្នុងបន្ទប់ដែលលាន់

មក។
«យុត្តនា!»
សំឡេងអ្នកនាងធំនៃគ្រួសារ ប៉ែន ពេជ្រ លាន់តិចៗតែសោះកក្រោះ ល្មមឲ្យទេសាភិបាលក្មេងងើបមុខដែលកំពុងកើតភាពភ្ញាក់ផ្អើល។
គ្រាន់តែឃើញមុខនាង អ្នកនឹកដល់សម្ដីរិទ្ធិ។
«ភ្នំភ្លើងពិតជាផ្ទុះមែនអី?»គេគិតស្ងាត់ៗក្នុងចិត្តតែបបូរមាត់ញញឹមស្វាគមន៍នាង៖
«អន្ទះសាម៉េះ? មករកដល់កន្លែង!!»
កំហឹងលេចចេញតាមពន្លឺភ្នែកល្ហល្ហេវរបស់នាងដែលសម្លឹងយុត្តនាត្លែ។
អ្នកប្រុសទីមួយដឹងថានាងគ្មានភាពទន់ភ្លន់ដូចកាលពីយប់នោះ សូម្បីតែបន្តិចទេ គេរាងពិបាកចិត្តដែរតែនៅតែបន្តរកពាក្យផ្ដើនតាមទម្លាប់៖
«ចូលចិត្តណាស់ រឿងធ្វើមុខកាចៗ! ម៉េច? ខ្លាចអត់មានគេហៅម៉ែ?»
ថាហើយអ្នកប្រុសឈ្ងោកទៅបន្តលេងស្នូក័រលើក្ដារធ្វើហីក្រោមភាព ក្រេវក្រោធរបស់គូសន្ទនា។ពៅបញ្ញាខាំមាត់និយាយស្ទួតថៃស៖
«មនុស្សក្បត់សម្ដី!»
យុត្តនាមិនយល់ថានាងចង់សំដៅលើរឿងអ្វីទេ។ គេក៏នឹកមិនដល់ដែរថា នាងកំពុងចង់ចោទថាខ្លួននិយាយរឿង ប៉ែន ពេជ្រប្រាថ្នា ចេញប្រាប់ឪពុកនាងកាលពីថ្ងៃនោះ បានជាគាត់នៅសុខៗគាំងបេះដូងដល់ថ្នាក់សង្គ្រោះបន្ទាន់។
គេញាក់ចិញ្ចើមឌីវិញ៖
«អត់ក្បត់ទេ! ខ្ញុំថាយកខ្លួននាង គង់តែយកដដែលហ្នឹង គ្រាន់តែឥឡូវនេះអត់ចង់»
ពៅបញ្ញាខឹងស្ទើរស្រក់ឈាមតាមភ្នែក ទោះបីបន្ទប់នេះគ្មានសល់អ្នកណាទៀតមានតែនាងនឹងគេនៅតទល់ តែនាងនៅតែយល់ថាគេនេះព្រហើន ជម្លើយនិងអសុរោះហួសនឹងទទួលយកបាន។ នាងមិនទាន់មានប្រតិកម្មយ៉ាងណាផង នរៈងើបមុខមកបញ្ចប់ប្រយោគរបស់គេ៖
«នាងឆ្នាសពេក ប្រុសណាមានអារម្មណ៍ទៅអ្វះ?»
ផាច់.....ថ្ពាល់ទេសាភិបាល ហួត យុត្តនា រងមួយកម្លាំងដៃមនុស្សស្រីសាជាថ្មី។ រិទ្ធិបុកពោះព្រោះនេះជាលើកទីមួយដែលអ្នកឃើញនាងកាចដល់ម្លឹង។ ចុះបើពេលនេះយុត្តនាមិនទប់ចិត្ត តើគេនឹងតទៅវិញដោយរបៀបណា? ពីក្នុងបន្ទប់ទឹក អ្នកប្រុសទីពីរប្រឹងតាមដានហេតុ

ការណ៍ខាងក្រៅមិនហ៊ានប្រហែសទេ ព្រោះថាយ៉ាងណាៗ គេក៏នឹងការពារនាង។ ដឹងអីភ្លាមៗនោះនាងសង្កត់សំឡេងសួរទៅយុត្តនា៖

«ប៉ាខ្ញុំនៅក្នុងពេទ្យមិនទាន់ចេញនៅឡើយ! លោកសប្បាយចិត្តហើយឬនៅ?»

យុត្តនាត្រូវមួយដៃក្ដៅចិត្តឆួល អ្នកក្របួចមាត់សងសម្ដីវិញមិនបង្អង់៖

«មនុស្សធ្វើអាក្រក់ លទ្ធផលចុងក្រោយ វាគ្មានអីខុសគ្នាទេ! រឿងអាក្រក់ៗនៅរង់ចាំអញ្ចឹងហើយ! »

ពៅបញ្ញារឹតតែខឹងនាងរឹតតែមាំ។ ស្រីស្អាតមមីភ្នែកដែលពេញដោយងងើកភ្លើងចិត្ត៖

«លោកចេះនិយាយពាក្យហ្នឹងដែរ!? ល្អហើយដែលចេះត្រៀមខ្លួន! រឿងអាក្រក់ៗសម្រាប់មនុស្សអាក្រក់ដូចលោកនឹងមកដល់ឆាប់ៗនេះ!»

នាងសម្លក់គេមិនដកភ្នែកឯដៃរាវបើកកាបូបស្ពាយធំទម្លាក់ ចេញនូវអាវធំក្រាស់ដែលគេគ្របឲ្យនាងកាលពី យប់នោះ ហើយចុងក្រោយគឺកូនសោផ្ទះចាស់ជាន់ទីបួនរបស់គេ។ របស់ទាំងពីរដែលត្រូវបានទម្លាក់ចោលមកលើតាបស្នូគ័ររួមជាមួយ ទឹកមុខឈឺចាប់របស់នាងធ្វើឲ្យបេះដូងអ្នកប្រុសទីមួយទៅជាហេងហាង។

ទឹកមុខនាយប្រែប្រួល ហើយនាយស្ងាត់មាត់ដូចគេចុក។

«យករបស់លោកទៅវិញឲ្យអស់ទៅ! ហើយបើអាច.....យើងកុំដើរឲ្យជួបមុខគ្នាទៀត..!»

កាយវិការនាងគឺប្រាប់ថា នាងនឹងគេចប់ត្រឹមនេះមែនឬ? គេចាប់ផ្ដើមភ្ញាក់ខ្លួនហើយលែងមានចិត្តឌឺដងបញ្ឆេះនាងដូចមុន ប៉ុន្តែគិតយល់ថាអ្វីទៅដែលធ្វើឲ្យនាងខឹងដល់ម្ល៉ឹង។ នោះគឺនាងយល់ច្រឡំថាកាលដែលប៉ានាងគាំងបេះដូងក៏ព្រោះតែគេបាន ក្បត់សម្ដី ដោយនិយាយរឿងទំនាក់ទំនងរវាងJohanនិង ប៉ែន ពេជ្រប្រាថ្នា ចេញមកអស់។

ដូច្នេះពាក្យសន្យារវាងនាងនិងអ្នក ការជំពាក់គ្នានៅ Apartment ជាន់ទី៦ និងស្នាមថើបនៅផ្ទះផ្កាសារិកាកែវ និងក្លាយជាអតីតកាលដែលគ្មានតម្លៃទាំងអស់???

ស្រីស្អាតបង្វិលកាយចាកចេញដោយដកពន្លឺភ្នែកគ្មានមនោសញ្ចេតនារបស់ នាងទៅជាមួយផង ធ្វើឲ្យអ្នកប្រុសរួសរាន់និយាយតិចៗឃាត់នាង៖

«ពៅបញ្ញា! ព្រឹកនោះ ខ្ញុំអត់បានធ្វើអីប៉ានាងទេ! ស្អីក៏ខ្ញុំអត់បាននិយាយដែរ!»

ស្រីស្អាតទប់ដំណើរមកវិញ។ នាងមិនចង់បែរក្រោយទេ ព្រោះតែប្រុសម្នាក់នេះធ្វើឲ្យនាងឆ្អែតចិត្តពេក តែពាក្យប្រកែកគ្មានន័យខ្លឹមសាររបស់គេរឹតតែធ្វើឲ្យនាងទើសចិត្ត ពន់ពេក។

នាងនឹកឃើញដល់ស្នាមញញឹមក្រោមវ៉ែនតាខ្មៅរបស់គេក្នុងពេលដើរ ប្រជ្រួសគ្នានាថ្ងៃនោះ នាងដឹងថាគេសប្បាយចិត្តដែលបាននិយាយរឿងចុកៗទាំងនោះប្រាប់ប៉ា នាង ពេលនេះ សោតគេមកប្រកែកយកត្រូវទៅរួច។ នាងបែរក្រោយសម្លឹងចំភ្នែកគេ ហើយសើចចុងមាត់ចំអកគេ។

«មិនជឿ??? សួរប៉ានាងទៅ! ប្រាប់ទៅប៉ានាងផង ចំណាស់នេះហើយកុំរៀនមួលបង្កាច់ក្មេង វាមិនល្អមើលទេ!»
ពៅបញ្ញាអស់សំណើចដែលគេមកប្រកែកយកត្រូវ តែនាងរឹតតែក្តៅចិត្តដែលគេនិយាយមិនគោរពប៉ានាងម្តងជាពីរ ដង។ ស្រីអ្នកច្បាប់ក្តាប់មាត់និយាយតបៈ
«លោកប៉ាខ្ញុំមិនទាន់មានប្រសាសន៍បាននៅឡើយ! មិនអញ្ចឹងទេ ខ្ញុំអូសលោកឡើងក្រចកសេះហើយ លោកយុត្តនា! តែ.....វាបណ្តោះអាសន្នប៉ុណ្ណោះ! ពេលលោកប៉ាមានប្រសាសន៍បាន! លោកត្រៀមខ្លួនឲ្យល្អទៅ!»
«នាងចង់ឲ្យខ្ញុំនិយាយលើសវនាការថាខ្ញុំអត់បានប្រាប់រឿងអាស្រូវ ៗពីអាបងប្រុសសំអុយរបស់នាងទៅឲ្យប៉ានាងដឹងអញ្ចឹងហ្អីស្រី ល្ងង់»
គេហួសចិត្តដែលនាងក្តៅរោលរាលចិត្តដល់ថ្នាក់មិនចេះគិតវែងឆ្ងាយ តែពៅបញ្ញាវិញយល់ថាគេនៅតែប្រើឃ្លានេះមកគំរាមនាង។ នាងខាំមាត់តបផ្ទួងៈ
«ខ្ញុំលែងខ្វល់ហើយ! រឿងមិនគួរនិយាយលោកនិយាយអស់ទៅហើយ! បំណាច់នឹងខូចមុខ ខ្ញុំត្រូវចាប់លោកញាត់គុកឲ្យបាន!»

នាងកាចពេក រឹងរូសពេកដល់ថ្នាក់អ្នកប្រុសអស់ពីចង់បកស្រាយ គេទៅជាគ្នាន់គ្នាញ់។ នាងបែរខ្លួនចេញទៅ តែត្រូវគេស្រវាទាញដៃមកវិញ។ មធ្យោបាយពន្លត់កំហឹងក្នុងចិត្តស្រីស្អាតគ្មានអ្វីក្រៅពីធ្វើ ឲ្យនាងនឹកឃើញឡើងវិញនូវគ្រាផ្អែមល្ហែមជាមួយគ្នានោះឡើយ។ គេស្រវាឱបចង្កេះនាងហើយលោទៅរកបបូរមាត់ស្លេកងាំងរបស់នាង។ ស្មានមិនដល់ថាមួយប៉ប្រិចភ្នែកនោះប្រអប់ដៃធំមួយឈោងមកទាញក អាវគេចេញពីមេធាវី ហើយកណ្តាប់ដៃអ្នកណាម្នាក់របាំសដូចផ្លេកបន្ទោរដាល់តម្រង់លោក ទេសាភិបាលក្មេងធ្វើឲ្យគេគ្មានឱកាសការពារខ្លួនទាន់ទាល់តែសោះ ព្រោះរវល់តែបារម្ភពីជំហរស្រីតូចខ្លាចនាងរបូតពីដៃដួលផ្ងារក្រោយ។
ផាំង.....យុត្តនាត្រូវមួយដៃចំក្រអូមមាត់ប៉ោងស្តុលហូរឈាមរឹមៗ....

គេប្រហែលបែកអំពិលអំពែកមិនអាចឮសូរគ្រហឹមរបស់ជំនួយការវណ្ណៈទេយ៉ាង....
«យកទៅអាអ្នកលេងអាវ៉ាសែ!»
ហេតុការណ៍វិវឌ្ឍទៅរកស្ថានភាពកាន់តែអាក្រក់ធ្វើឲ្យជំនួយការ រិទ្ធិភាន់ភាំងម្នាក់ឯងក្នុងបន្ទប់ទឹក។ គេដឹងថា ពៅបញ្ញាមកជាមួយជំនួយការនាងហើយគេនោះមិនទុកចិត្តក្នុងការដែល ឲ្យនាងចូលមកតែម្នាក់ឯងទេ ដូច្នេះហើយពេលគេមកទាន់អំបាញ់មិញគេយល់ថាយុត្តនាគឺមាក់ងាយរាងកាយ ថៅហ្វាយគេ។ គាប់ជួនវណ្ណៈចិត្តមិនសូវធ្ងន់គេចាប់ផ្ដើមប្រើហិង្សាលើយុត្តនា ទាំងទទឹងទិសធ្វើឲ្យហេតុការណ៍ចាប់ផ្ដើមពិបាកគ្រប់គ្រង។
ដែលរិទ្ធិបារម្ភមិនមែនរឿងថាយុត្តនាកំពុងត្រូវមួយដៃហូរឈាមទេ តែគេដឹងថាយុត្តនាជាអ្នកណា ហើយត្រឹមសម្បត្តិជំនួយការវណ្ណៈមានអីស៊ូជាមួយអ្នកប្រុសទីមួយរបស់ ហួត ស៊ីវ កើត។
មិនខុសមែន....កំពុងក្រពុលមុខដែលត្រូវស្រីស្អាតយល់ខុស....បន្ទាប់មក ត្រូវអង្គរក្សនាងឲ្យមួយដៃឈាមមាត់ទៀត យុត្តនាលែងដៃពីចង្កេះនាងតូចដែលមុននេះអ្នកមិនហ៊ានលែងព្រោះខ្លាចនាងដួល ហើយបំបែរទិសដៅទៅរកជំនួយការឆេវឆាវដោយសងគេធ្ងន់ៗជាច្រើនកណ្ដាប់ដៃដល់ថ្នាក់រកច្រកតបតលែងកើត។

វណ្ណៈពិតជាគ្រោះថ្នាក់ព្រោះគេមិនស្គាល់យុត្តនាជាអ្នកណា ហើយដែលរិទ្ធិកាន់តែពិបាកព្រោះមិនអាចបង្ហាញខ្លួនទៅជួយគេបាន។
នៅពេលមនុស្សរបស់ឪពុកត្រូវបីបួនដៃហើមពោរមុខមាត់ ហើយកណ្ដាប់ដៃថ្មីរបស់បុរសអ្នកលេងកំពុងតម្រង់ទៅសាជាថ្មី ស្ថានភាពរបស់វណ្ណៈគឺអស់ផ្លូវតដៃតែម្ដង។ ពៅបញ្ញាអស់ពីភាន់ភាំង នាងភ្លាត់មាត់ស្រែកកាត់៖
«ឈប់ភ្លាម!»
កណ្ដាប់ដៃប្រុងបន្តបញ្ចេញកំហឹងឲ្យម្ចាស់វាទៅហើយ តែឲ្យវាបង្អង់មកវិញគឺវាលំបាកណាស់ ដូច្នេះយុត្តនាបន្ថែមមួយដៃនោះ ធ្វើឲ្យវណ្ណៈទន់ជើងដួលចុះដល់ដី ក្រោមពន្លឺភ្នែកក្រហមងៅរបស់រិទ្ធិ។
«មនុស្សមិនចេះគិតនៅតែមិនចេះគិត!»អ្នកប្រុសទីពីររបស់ ហួត ស៊ីវ រអ៊ូម្នាក់ឯងក្នុងចិត្ត ត្បិតដឹងថាយុត្តនាមិនត្រឹមតែមិនអាចធ្វើឲ្យស្រីស្អាតធូរចិត្ត ទេ តែគេថែមទាំងក្លាយជាតួចិត្តអាក្រក់ក្នុងបេះដូងនាង។

«មនុស្សកម្រោល!»នាងស្រែកទាំងតក់ស្លុតប្រាថ្នាឲ្យគេដឹងខ្លួនមកវិញបញ្ឈប់អំពើហិង្សានោះ។

បានដូចចិត្ត គឺសម្ដីមាក់ងាយរបស់នាងធ្វើឲ្យយុត្តនាបញ្ឈប់ការវាយតប់ហើយបែរ មករកស្រីអ្នកច្បាប់ជាមួយភ្លើងកំហឹងក្រហមរោលក្នុងគ្រាប់ភ្នែក និងបបូរមាត់។

នាយលើកដៃជូតឈាមដែលហូររឹមៗ ចំណែកពៅបញ្ញាសម្លក់គេមុនពេលលែងខ្ញីសម្លឹងមុខហើយស្ទុះទៅគ្រាវណ្ណៈឲ្យក្រោក។

«យើងទៅវិញបង!»

អ្នកប្រុសធំដែលមិនធ្លាប់សូម្បីតែរងពាក្យអសុរោះរបស់ អ្នកណាម្នាក់កុំថាឡើយមកត្រូវគេដាល់កញ្ចប់មាត់នៅនឹងមុខស្រី ស្អាតទៀត ចិត្តគេឆេះតិចអី? ដល់មកឃើញនាងគ្រាជំនួយការរបស់ឪពុកដើរសំដៅទ្វារ យុត្តនាលូកដៃទៅទាញកន្ត្រាក់នាងមកវិញ។

ដៃនាងរបូតចេញចេញពីវណ្ណៈ មកជាប់កដៃក្នុងប្រអប់ដៃរឹងដូចដែករបស់យុត្តនាសាជាថ្មី។ គេសម្លឹងភ្នែកនាងទាំងសងខាង ហើយនិយាយម៉ាត់ៗ៖

«ថាខ្ញុំធ្វើបាបប៉ានាង នាងគិតតែម្នាក់ឯងតែគ្មានភស្តុតាងទេ! ចំណែកអារអង្គរក្សចោលម្សៀតរបស់នាង មកដាល់ខ្ញុំដល់កន្លែង គឺខ្ញុំមានភស្តុតាងគ្រប់គ្រាន់ ដឹងផងទៅមេធាវី»

ស្រីតូចសម្លឹងមុខគេត្លៃជាសញ្ញាថានាងគ្មានថ្ងៃចាញ់គ្មានថ្ងៃខ្លាច។ វាចានាងត្រជាក់ស្រេប៖

«ធ្វើអីធ្វើទៅ! ខ្ញុំរង់ចាំទទួលពាក្យបណ្ដឹងពីលោក! ចាំមើល៍ លោកធ្វើអីគាត់បាន!»

មិនសមថា ឈឺមាត់ប៉ុណ្ណឹងហើយស្រីមិនអាណិតសូម្បីតែព្រិចភ្នែកយល់ចិត្តតែ បន្តិច នាងថែមទាំងបើកភ្នែកធំៗ ផ្ដុំសម្ដីផ្ដើនមកថែមទៀត ប្រុសណាដែលថាមិនឆ្អែតចិត្ត?

គេសើចចុងមាត់បង្ហាញស្នាមខួច៖

«បានតើ! យើងភ្នាល់គ្នាមើលទៅ! ខ្ញុំកំដរនាងលេង!»

នាងបង្ហាញការមាក់ងាយអាកប្បកិរិយាប្រុសម្នាក់នេះតាមទឹកមុខ ព្រោះកាន់តែស្ដាប់គេ សម្ដីគេមិនខុសអ្វីពីមនុស្សតាមចិញ្ចើមថ្នល់ក្នុងកុនចិនទេ។ ស្រីអ្នកច្បាប់ឯណាទទួលយកអាកប្បកិរិយាទាំងអស់នេះបាន នាងលែងតហើយរលាស់ដៃនាយចេញមួយទំហឹង។

ក្នុងពេលដែលអាកប្បកិរិយាភាគីខាងស្រីបង្ហាញថា គេស្អប់ខ្ពើមយើងយ៉ាងនេះទៅហើយ យុត្តនាមានកម្លាំងចិត្តឯណាជម្នះចាប់ដៃនាងទៀត គេមានតែបន្ទូរវាទៅតាមចិត្តនាងទាំងអារម្មណ៍សៅហ្មង។

ពីក្រោយខ្នងអ្នកប្រុសដែលឈរច្រត់ចង្កេះទាំងតប់ប្រមល់ នាងគ្រាវណ្ណៈសាជាថ្មីហើយចាកចេញ។ ស្ទើរមិនទាន់ផុតកែងជើងនាង យុត្តនាធាក់ទ្វារបិទទៅវិញគ្រាំងបង្ហាញកំហឹងចិត្ត។ រិទ្ធិដើរចេញមកយឺតៗ។ ទឹកមុខគេបង្ហាញថាហេតុការណ៍ប្រទូសរ៉ាយគ្នានៅខាងក្រៅមិនបានធ្វើឲ្យគេស្រួលចិត្តប៉ុន្មានឡើយ។ អ្នកប្រុសទីពីរអង្គុយប៉ុកលើកៅអី ពីមុខយុត្តនា។ គេនិយាយយឺតៗដោយមិនងើបមុខ៖

«ឥឡូវនេះឃើញហើយ ប្រើកំហឹងដោះស្រាយអីចេញអត់!»

យុត្តនាក្តាប់មាត់ដោយសៅហ្មង គេលើកអាវក្រៅលើជញ្ជាំងមកពាក់បម្រុងថាចាកចេញ ឯមាត់ក៏ឆ្លើយខ្លី៖

«ស្រីឆ្នាសនោះ អ្នកណាយកធ្វើប្រពន្ធ ចង្រៃបីជាតិហើយ!»

«ចុះបើគេព្រមយកឯង ឯងព្រមចង្រៃដែរអត់?»រិទ្ធិឌឺវិញព្រោះថាធុញនឹងចរិតមាត់ដាច របស់គេ។យុត្តនានៅស្ងៀមបិទរូតអាវក្រៅតែគេនៅសំងំស្តាប់សម្តី បងប្អូនធម៌។ រិទ្ធិបន្តភ្លាម៖

«បើឯងស្រលាញ់គេ ហើយនិយាយស្តីអាក្រក់ស្តាប់ម្ល៉ឹងៗស្រីណាគេព្រមយល់ចិត្តឯង?»

«អ្នកណាស្រលាញ់គេឲ្យប្រាកដលោកជំនួយការ?»យុត្តនាឌឺវិញ។

រិទ្ធិដកដង្ហើមយូរ គេក្រោកដើរមកលើកប៊ីយែរដែលសល់នៅលើនោះមកក្រេបបន្តពីយុត្តនា៖

«ដូរប្រធានបទ! អូខេ! និយាយរឿងឧកញ៉ា ប៉ែន ពេជ្រ ឯងនិងគាត់និយាយអីខ្លះកាលពីព្រឹកនោះ?»

យុត្តនានៅស្ងៀមបន្តិចទើបងាកទៅគាស់មួយកំប៉ុងផ្សេងផឹកកំដររិទ្ធិមុននឹងឆ្លើយតប៖

«គ្មានអីទេ តានោះដើរតួជាមនុស្សល្អ មកនិយាយអរគុណខ្ញុំ! តែប៉ុណ្ណឹង!»

«ចុះឯងទៅថាអីឲ្យគាត់ខ្លះ?»

«អត់មាន!»

«មួយម៉ាត់ក៏អត់?»

«ត្រូវហើយ!!»

«ឯងយល់ថាមានគេជឿឯងដែរយុត្តនា!»

«អត់ខ្វល់! ខ្ញុំមិនដែលខ្លាចទេ បើមានថាមានហើយ!»

«ចុះម៉េចគាត់គាំងបេះដូងប៉ុន្មាននិនាទីក្រោយពេលឯងដើរចេញ?»

«អាហ្នឹងទាល់តែសួរតាហ្នឹងខ្លួនឯងទៅ!»

រិទ្ធិឈប់បន្តិចទើបនិយាយបន្ត៖
«តាមចរិតឯង.....»

រិទ្ធិមិនបញ្ចប់ទេ តែយុត្តនាយល់ពីអ្វីដែលគេកំពុងចង់និយាយ។ តាមចរិតខ្លួនសូម្បីតែរិទ្ធិក៏មិនជឿថាអ្នកមិនបានឆ្លៀតពេលនោះ ខឹងឯងឱពុកពៅបញ្ញាដែរ តែគេខ្លួនឯងដឹងច្បាស់ថា ហេតុអ្វីព្រឹកនោះគេនៅស្ងៀមចំពោះមុខសត្រូវសម្លាប់ឪពុក។ គេនិយាយតបធ្វើហី៖
«ចង់ជេរតានោះគ្មានអីពិបាកទេ ខ្វះថ្ងៃជេរណាស់? សំខាន់យប់នោះ ទើបតែបានថើបកូនស្រីគេហើយ ក៏នឹកឃើញខ្មិលរករឿងឱគេទៅ!»
រិទ្ធិនឹកឃើញដល់ស្ថានភាពរបស់អ្នកនាងតូចដែលចុះមកវិញកាលពីយប់ នោះ។ នាងគ្មានសូម្បីតែស្បែកជើង ហើយចុងក្រោយបានដណ្តប់អាវយុត្តនារហូតដល់ផ្ទះទៀត។ អ្នកទាំងពីរពិតជាបានរំលឹកអនុស្សាវរីយចាស់ដល់ថ្នាក់យល់ចិត្ត គ្នាហើយពិតមែន?
អញ្ចឹងមានតែអ្នកណាម្នាក់នោះពិតជាចង់បំផ្លាញទំនាក់ទំនងរវាងពួក គេដោយចេតនា? តើអាចជាឪពុកខ្លួនហួតស៊ីវទេ? បើមែនម៉េចក៏គាត់ទើបនឹង callមកពេលឪពុកពៅបញ្ញាចេញពី ICUរួចទៅហើយចុះបើគាត់ជ្រុលជាគាំងបេះដូងស្លាប់មែន ព័ត៌មានស្តីពីគម្រោងធុរកិច្ចរាប់សិបឆ្នាំនោះមិនកប់បាត់ទៅតាម មរណភាពរបស់គាត់ទៅហើយ? ច្បាស់ជាមិនមែនគាត់ធ្វើឡើយ រិទ្ធិកាន់តែប្រាកដចិត្តចំពោះរឿងនេះ។

ឃើញគេនៅស្ងៀមយុត្តនាញាក់ចិញ្ចើមបន្តប្រយោគ៖
«ម៉េច? ក្រែងចង់ព្ទការពិតណាស់ហ្អី? ព្ទហើយសប្បាយចិត្តនៅ? ខឹងជំនួសអ្នកនាងធំឯងឬមួយកើតរោគប្រចណ្ឌ?»
«បាន! ឲ្យច្បាស់រឿងមួយ! គ្នាអត់ដណ្តើមស្រីជាមួយបងប្អូនឯងទេ! ចាំទុកយុត្តនា!»រិទ្ធិនិយាយដោយទឹកមុខស្មើ។ យុត្តនាសើចស្ងួត រិទ្ធិពោលបន្តភ្លាម៖
«ឧកញ៉ាត្រូវថ្នាំរំញោច! ប្រាកដណាស់ មានគេលបដាក់!»
មិនខ្វីរវល់ភ្ញាក់ផ្អើលយុត្តនាតបវិញ៖
«ចុះមិនទៅប្រាប់ថៅហ្វាយស្រីឯងទៅ! កុំឲ្យគេកប៉ាល់ភ្លើងពេក! ឱគេសត្រូវច្រើនម្ល៉ឹងៗ កុំដើរវាលដាលបង្ខូចគេឯង!»
រិទ្ធិមិនខ្វល់នឹងចរិតធូរល្ហុយរបស់គូសន្ទនាទេ។ យុត្តនាស្មោះត្រង់និងគ្មានល្បិចល្បងជាទម្លាប់របស់គេ ចំណែកស្ថានការណ៍ពេលនេះគឺផ្សេង គេពន្យល់បងប្អូនធម៌៖

«ចុះហេតុអីគេចាំរើសយកពេលឯងជួបជាមួយគាត់ដើម្បីចាត់ការ!»
យុត្តនាបញ្ឈប់កំប៉ុង Alcohol ត្រឹមបបូរមាត់ ព្រោះសម្ដីរិទ្ធិធ្វើឲ្យអ្នកប្រុសធនាគារចេះគិតស៊ីជម្រៅឡើងវិញ ក្នុងហេតុការណ៍នោះ។
«អាវបល់យកណាឈរចាំបោសដៃមើលពៅបញ្ញាលេងខ្ញុំទេដឹង? មានតែឯងរិទ្ធិ?»
«ឈប់និយាយលេងទៅ! ខ្ញុំឲ្យគេស៊ើបហើយ! អ្នករត់តុម្នាក់បានជូរយកដបនោះចេញមុនពេលប៉ូលិសមកដល់! សួរតែក្មេងនោះការពិតនឹងចេញមក សំខាន់ខ្ញុំមកនេះគឺមកបញ្ជាក់នឹងឯង បើឯងអត់បានធ្វើទេ ខ្ញុំនឹងឲ្យគេស៊ើបបន្ត!»
«ឯងឡប់ហើយ!»គេរអ៊ូតិចៗជាសញ្ញាថា គេគ្មានពាក់ព័ន្ធជាមួយរឿងអស់នោះឡើយ។ រិទ្ធិយល់ពីអ្វីដែលយុត្តនាឆ្លើយតប។ គេងក់ក្បាលផ្ងក់ៗ៖
«ខ្ញុំចង់ដឹងថាគេគ្រាន់តែចង់ឲ្យឯងនិងពៅបញ្ញាមានរឿងឬមួយ គេចង់ឲ្យលោកប៉ានិងផ្ទះប៉ែនពេជ្រកាន់តែមានរឿង?»
«ស្អីគេ! ឯងកំពុងមើលកុន? ក្លាយជា FBIពីអង្កាល់មក?»
«មិនបាច់ខ្វល់ច្រើនទេគ្រាន់តែប្រាប់មក! រឿងឯងទៅជួបឧកញ៉ាប៉ែនពេជ្រមានអ្នកណាដឹងខ្លះ?»
យុត្តនាវេភ្នែករិះគិត.....

## ១៨

## ល្បិចទុរយសប្រើពេលជិតម្ភៃឆ្នាំ

....ផ្សែងធូបហុយទ្រលោម....បិទបាំងពីមុខស៊ុមរូបថតយុវជនម្នាក់សម្បុរសកាយសម្បទាមាំមួន ទឹកមុខញញឹមពព្រាយ។
ទោះយ៉ាងណា គ្រឿងសក្ការនៅពីមុខគេបង្ហាញថាគេលែងមានជីវិតលើលោកនេះទៀតហើយ។
«អាហ៊ា! មួយរយៈនេះរវល់ពេក មិនបានមកមើលអាហ៊ាញឹកញាប់! តែអាហ៊ាត្រូវសប្បាយចិត្ត! អ្វីៗជិតបានដល់ដៃយើងហើយ! ក្រឡាអុកដែលយើងរៀបជាមួយគ្នា ឲ្យអាស៊ីវជាមួយអាពេជ្រវាបុកគ្នា ឥឡូវវាជិតដល់ពេលរបួសប្រយុទ្ធលែងកើតហើយ អាគម្រោងរកស៊ីត្បូងនោះ មុនក្រោយជារបស់យើង! អាហ៊ាចាំមើល!»
ពន្លឺព្រះអាទិត្យចាំងតាមប្រលោះបន្ទះក្ដារនៃកូនផ្ទះឈើ ឆ្លុះលើទឹកមុខជ្រីវជ្រួញរបស់បុរស

ចិនវ័យចំណាស់។ គេមិនពិបាកស្គាល់គាត់ទេព្រោះគាត់តែងតែបង្ហាញខ្លួនជានិច្ចកាល ក្បែរអគ្គទេសាភិបាលល្បី ហួត ស៊ីវ។
«ហ៊ាប៉េងមកលេងទៀតហើយ?»
សំឡេងស្រ្តីកាត់ចិនម្នាក់លាន់មកពីមាត់ទ្វារ។
ប៉េងដកដៃចេញពីជើងធូបហើយងាកទៅញញឹមស្វាគមន៍ភ្ញៀវ។
«អាចេឯងទើបមកពីផ្សារ? »
«ត្រូវហើយ! ហើយចុះប៉េងឯងមកដល់មិនខលមុន?»
«អត់មានគម្រោងទេ! ថ្ងៃនេះសប្បាយចិត្តក៏ឡើងឡានឈ្នួលមករឹង!»
គាត់លូកកាបូបយកលុយមួយចំនួនប្រគល់ទៅឲ្យស្រីនោះជាមួយសម្តីទន់ភ្លន់៖
«ច្រើនឆ្នាំមកនេះ បានអាចេហើយចេញចូលជួយមើលថែទាំផ្ទះនេះ! ខ្ញុំអរគុណណាស់»
ស្រ្តីនោះញញឹមទទួលលុយទុកហើយចាក់ទឹកឲ្យគាត់ ព្រមទាំងនិយាយមិនស្វាត់៖
«ហ៊ាក៏ចាស់ដែរហើយ! រកប្រពន្ធទៅ!»
«និយាយមើលតែអាចេហ្នឹងលែងចង់ជួយខ្ញុំមើលរក្សាផ្ទះនេះ?»
«អត់ទេ! ថ្ងៃមុនមានក្មេងប្រុសម្នាក់ខ្ពស់សម្បុរខ្មៅស្រអែមរបៀបដូចកូន ខ្មែរ មកសួរនាំម៉ុំនេះ! ខ្ញុំឃើញរាងគេជាអ្នកមាន សមតែជាអ្នកប្រុសផ្ទះធំណាមួយស្មានតែថាមករកហ៊ាប៉េងឯង? អ្នកខ្លះគេនិយាយថា ជួនកាលហ៊ាឯងទៅនៅភ្នំពេញយូរទៅ អត់ការប្រពន្ធ តែមានកូនធម៌មិនដឹងអាចថាគេនោះរកស៊ីមានបានគេមកស៊ើបសួររក ហ៊ាឯងវិញ!»
បុរសចំណាស់ថ្លោះទឹកមុខ។ គេរវៃភ្នែកដ៏តូចនោះគិតទាំងមាត់សួរវិញ៖
«ហើយចុះគេនោះជាអ្នកណាមករកអីនៅទីនេះ?»
«អត់ដឹងទេ! គេនិយាយលេងជាមួយអាហ្គិចលក់ទឹកកក និយាយជាមួយចែហួង និងអាទ្រាលក់ចាប់ហួយ និយាយចុះនិយាយឡើងសួរនាំពីគ្រួសារហ៊ាប៉េងឯង បងប្អូនប៉ុន្មាននាក់ពីដើមនៅឯណាធ្វើអី!!»

ប៉េងប្រញាប់ប្រញាល់ហូតរូបថតមួយសន្លឹក ពីក្នុងកាបូបលុយហុចឲ្យស្ត្រីនោះពិនិត្យភ្លាម៖
«អាចេឯងមើលមើល៍! ម្នាក់នោះមានក្នុងរូបនេះទេ?»
ស្ត្រីនោះឱនពិនិត្យភ្លាមភ្ញាក់ផ្អើលភ្លែត៖
«ត្រូវហើយ! ម្នាក់នេះ!»

ក្រោមដៃនាងចង្កុលចំរូបរិទ្ធិដែលនៅអមខាងឆ្វេងហួតស៊ីវ។ ទោះយ៉ាងណាការចំណាំរបស់ស្ត្រីនោះធ្វើឲ្យប៉េងធ្លាក់ថ្លើមក្តុក ។

«កូនប្រុសទីពីររបស់អាស៊ីវមកដល់ភូមិនេះ?»

គាត់គិតក្នុងចិត្តជាមួយស្នាមញញឹមមិនសូវសមទៅកាន់គូសន្ទនា។

មិនខុសពីអ្វីដែលប៉េងគិតទុកទេ យប់នោះគាត់បានត្រលប់មកដល់ផ្ទះនៅភ្នំពេញវិញ ដោយមានអ្នកប្រុសទីពីរ ហួត ខេមរិទ្ធិ នៅរង់ចាំពីក្រោមផ្ទះរួចជាស្រេច។

គាត់ឈានទៅរករិទ្ធិដែលបង្ហាញខ្លួនក្បែរឡានខ្មៅរលើបរបស់គេ ។ ទោះបីអ្នកប្រុសទីពីររបស់ ហួត ស៊ីវ មិនឆេវឆាវនឹងល្បីខាងកាប់ចាក់ដូចជាអ្នកប្រុសធំ ប៉ុន្តែទឹកមុខត្រជាក់ព្រមទាំងចរិតនឹងនរបស់គេធ្វើឲ្យប៉េង ស្វះស្វែងរកវិធីទប់ទល់ដោយលំបាក។ នៅតែមានឫកពាត្រុនៗដូចដែលពួកគេធ្លាប់ឃើញតាំងពីតូចៗមក។

«អ្នកប្រុសទីពីរ!?»

រិទ្ធិសម្លឹងបុរសចំណាស់ដែលជានិច្ចកាលនៅក្បែរត្រចៀកឪពុកធម៌ខ្លួន បុរសនេះនិយាយរកអ្នកតែភ្នែកគាត់ក៏មិនហ៊ានសម្លឹងអ្នកចំឡើយ។ រិទ្ធិដកដង្ហើមយូរ មុនពេលនិយាយនូវប្រយោគដែលប៉េងបានទាយទុកមុននិងកំពុងរង់ចាំ៖

«ពូធ្វើរឿងហ្នឹងធ្វើអី?»

បុរសចំណាស់ធ្វើជាងីងើរបៀបមិនយល់រឿង ធ្វើឲ្យរិទ្ធិកាន់តែធ្វើមុខស្មើសម្លឹងចំមុខគាត់មិនដកភ្នែក៖

«ពូឲ្យគេទៅធ្វើអីឱកញ៉ា ប៉ែន ពេជ្រ?»

ប៉េងនៅស្ងៀមមិនស្តី តែគ្រាប់ភ្នែកគាត់ចាប់ផ្តើមក្រឡឹបក្រឡាប់។

«ពូនៅស្ងៀម គេចមិនឆ្លើយសំណួរខ្ញុំអត់បានទេ!»

រិទ្ធិជ្រែងហោប៉ៅនៅពីមុខគាត់។ បុរសចំណាស់ឆ្លើយវិញយឺតៗទាំងដង្ហើមធំ៖

«ខ្ញុំអត់គេចទេទាន តែមិនដឹងត្រូវនិយាយពីណាទៅណា!»

«ងាយទេ! ពូគ្រាន់តែឆ្លើយឲ្យច្បាស់នឹងសំណួរនិមួយៗរបស់ខ្ញុំទៅ! ពូប្រើគេឲ្យទៅដាក់ថ្នាំក្នុងទឹកឱកញ៉ា ប៉ែន ពេជ្រ»

ប៉េងស្មានមិនដល់ទេថា សូម្បីរឿងល្អិតយ៉ាងនេះក៏គេដឹង បានន័យថាគេបានស្រាវជ្រាវរឿងនេះច្បាស់លាស់ មានវត្ថុតាងក្នុងដៃអស់ហើយបានជាទៅជួបគាត់។ គ្មានផ្លូវគេចបាន បុរស

ចំណាស់ដកដង្ហើមធំឆ្លើយពង្វាង៖
«ខ្ញុំធ្វើគ្រប់យ៉ាងដើម្បីលោកអគ្គ!»
រិទ្ធិសើចគ្មានសំឡេង។
«ខ្ញុំគ្មានបំណងផ្សេងទេ!»
បុរសជាលេខាពោលបន្ត។
អ្នកប្រុសទីពីរសម្លឹងមុខគាត់ជាមួយប្រយោគដេញដោល៖
«ប៉ាខ្ញុំទើបតែដឹងរឿង ប៉ែន ពេជ្រ ចូលពេទ្យ បានន័យថាលោកមិនជ្រាបពីរឿងហ្នឹង រឹតតែមិនដឹងពីរឿងថ្នាំរំញោចអីទៅទៀត! លោកកុំចង់ប្រើវិធីនេះមកកុហកខ្ញុំលេខាប៉េង!»
«លោកអគ្គ មិនដឹងមែន ប៉ុន្តែតួនាទីខ្ញុំជាកូនចៅត្រូវដោះទុក្ខចៅហ្វាយ! ប៉ែន ពេជ្រ ធ្វើអាក្រក់ក្បត់ពួកម៉ាក វាជាបន្លាក្នុងភ្នែកលោកអគ្គ មានឱកាសខ្ញុំត្រូវតែចាត់ការវា!»
«ចុះហេតុអីពូរើសពេលដែលយុត្តនាត្រូវទៅជួបគាត់ហើយដាក់ថ្នាំក្នុងទឹកគាត់?»
«បំពុលវាគឺបំពុលហើយ ពេលណាក៏ដូចគ្នាដែរ!»
«ខុសហើយ! គឺពូមានបំណងចង់ឲ្យបងប្រុសខ្ញុំទទួលខុសត្រូវរឿងនេះ ដូច្នេះចង់មិនចង់ លោកប៉ាខ្ញុំក៏នឹងជាប់ពាក់ព័ន្ធ! ខ្ញុំមិនដឹងថា តើពូធ្វើនេះជួយបញ្ចេញកំហឹងគាត់ ឬចង់ទាញគាត់ទម្លាក់ទេ!»
ប៉េងរក្សាភាពស្មើធេងលើផ្ទៃមុខ៖
«ខ្ញុំស្មោះត្រង់ដើរតាមលោកអគ្គជាងម្ភៃឆ្នាំមកហើយ! តាំងពីអ្នកប្រុសទីពីរមិនទាន់ក្លាយជាអ្នកផ្ទះនោះម្ល៉េះ! ចិត្តខ្ញុំស្មោះចំពោះលោកអគ្គ មានតែលោកអគ្គទេដែលយល់!»

ថាហើយបុរសចំណាស់ចាកចេញទៅរឹងមិនរវល់នឹងរិទ្ធិដែលនៅឈរទ្រឹង នោះទៀតឡើយ។ កាយវិការគាត់គឺក្អេងក្អាងច្បាស់ណាស់ ចំណែកសម្ដីគាត់រឹតតែបញ្ជាក់ទៀតថា ទំនាក់ទំនងគាត់និងហ្លួត ស៊ីវ មានប្រវត្តិនិងរយៈកាលមាំទាំជាងអ្នកប្រុសដែលជាកូនចិញ្ចឹមទៅទៀត។
រិទ្ធិនិយាយតិចៗពីក្រោយខ្នងបុរសសៃចិន៖
«ពូប៉េង! ប៉ាខ្ញុំអត់ល្ងង់ជាងពូទេ! បើពូពិតជាឲ្យតម្លៃមនោសញ្ចេតនាច្រើនឆ្នាំមកនេះមែន ពូឈប់ទៅ!»
ប៉េងសើចរលាក់ស្មា គាត់មិនបែរក្រោយក៏មិនខ្វីញញើតក្នុងការឆ្លើយតប៖
«ចាំមើលសិន! ថា ហ្លួត ស៊ីវ ជឿឯងឬជឿខ្ញុំ!»

គាត់ដើរទ្បើងទៅលើផ្ទះ ក្រោមភាពតឹងតែងដែលកាន់តែលេចចេញឡើងកំដរដើមទ្រូងអ្នកប្រុសទីពីរ។
ចង់មិនចង់ ការពិតបានលេចចេញមកហើយ។ ឪពុកខ្លួនគឺកំពុងស្ថិតនៅក្បែរមនុស្សចិត្តមិនត្រង់។ ឯបំណងពិតរបស់លេខាប៉េង ជាអ្វីក៏មិនដឹងតើបញ្ហានេះអ្នកអាចស្រាយចេញដោយវិធីណា?
ជំនួយការបង្កប់ខ្លួនលើកទូរសព្ទចុច....
នៅក្រោមស្បៃរាត្រីស្ងាត់សូន្យ គ្មានអ្នកណាដឹងថាវិទ្ធិនិយាយជាមួយអ្នកណាហើយនិយាយពីអ្វីខ្លះទេ តែសកម្មភាពគេកំពុងត្រូវបានឃ្លាំមើលដោយយកចិត្តទុកដាក់ពីជាន់ ខាងលើ ដូចនេះហើយក្រោយពេលគេឡើងរថយន្តចាកចេញមិនដល់ ១០ នាទីស្រួលបួលផងលេខាប៉េងចុះមកក្រោមដែរហើយ គាត់ឡើងម៉ូតូឌុប.......។

...ជំនួយការវិទ្ធិកំពុងស្ថិតនៅក្នុងរង្វង់ចំណោទថាតើគេគួរ ធ្វើសកម្មភាពបែបណាជាការឆ្លើយតបនឹងអារម្មណ៍សង្ស័យចំពោះលេខាប៉េង?
ប្រការដែលសំខាន់គឺតើលេខាប៉េងពិតជាមានឧបាយកលផ្សេងនៅពីក្រោយ សកម្មភាពរបស់គាត់ពិតមែនឬយ៉ាងណា។ បើគ្រាន់តែករណីពាក់ព័ន្ធរបស់គាត់ទៅក្នុងការលបដាក់ថ្នាំរំញោចលើឧកញ៉ាប៉ែន ពេជ្រ គេអាចការពារខ្លួនបានដោយចម្លើយថា គឺដើម្បីឪពុកធម៌របស់ខ្លួន ហួត ហ៊ីវ។
គោលដៅរបស់វិទ្ធិពេលនេះគឺទៅកាន់ផ្ទះ ហួត ស៊ីវ ដើម្បីសាកសួរយោបល់អ្នកមានគុណរូបនេះនៅរឿងមួយចំនួនដែលខ្លួនគិត មិនយល់ ប៉ុន្តែរថយន្តដ៏ទំនើបពណ៌ក្រហមមួយដែលបើកគ្រេងគ្រាងនៅពីមុខនាយ បានរំខានដល់សន្ទុះចិត្តវិទ្ធិក្នុងការស្រូតឲ្យដល់ផ្ទះឪពុក។ គេបង្ខំចិត្តវេចង្កូតទៅផ្លូវផ្សេងមួយទៀតនឹងបើកបង្ហួសពីកូន រថយន្តទំនើបនោះ។ កន្ទុយភ្នែកចៃដន្យរបស់ជំនួយការវិទ្ធិវាត់ទៅប្រទះនឹងម្ចាស់រថយន្ត ដែលជាស្ត្រីវ័យក្មេងម្នាក់។
«អមរា?»
ប៉ែន ពេជ្រអមរា ក្នុងសកម្មភាពស្រវឹង។ នាងបញ្ជាយានយន្តដោយលំបាក ហើយមិនរវល់សូម្បីវិទ្ធិកំពុងតែសម្លឹងមកនាងដោយភ្លឹកភ្លាំង។ អ្នកប្រុសទីពីររបស់ ហួត ស៊ីវ បោះបង់ចោលគោលដៅហើយបំភ្លេចចោលករណីរបស់លេខាប៉េងសូន្យឈឹង។ ពីព្រោះចំពោះមុខ នារីម្នាក់នេះគ្មានលទ្ធភាពបញ្ជាយានយន្តពិតប្រាកដណាស់។ មិនខុសមែនគ្រាន់តែស៊ីញ៉ូអែបទៅនឹង

ចិញ្ចើមផ្លូវគេងាកមកក៏ឃើញ អមរាឈប់ឡានទទឹងផ្លូវទៅហើយ។
«អ្នកនាងអមរា?»

គេគោះកញ្ចក់ហៅតិចៗបួនប្រាំដងទើបឃើញស្រីស្អាតងើបក្បាលចេញពីចង្កូតរថយន្ត៖
«រិទ្ធិលោកមែន ល្អហើយដែលជួបលោកនៅទីនេះ!»
ក្រោមក្រសៃភ្នែកព្រួយបារម្ភរបស់ជំនួយរិទ្ធិ ធីតាអភិជនយោងកាយដ៏ល្វតល្វន់ជាមួយរាងកាយដ៏សិចស៊ីជាមួយ សំលៀកបំពាក់ជាទីពេញនិយម សម្រាប់បណ្ដាអ្នកទៅក្លឹបរាត្រី ដោយនាងដើរចាកចោលជំនិះសំដៅមករកអ្នកកំលោះវិញ។
«រិទ្ធិឡាននេះមិនដឹងជាខូចអីទេ វាអត់ទៅមុខទៀតសោះ!»
អ្នកប្រុសទីពីរដឹងថារថយន្តមិនខូចទេ តែមនុស្សទេដែលមានបញ្ហា ប៉ុន្តែគេនៅរក្សាភាពស្មើធេងលើផ្ទៃមុខ។
«ខ្ញុំជូនអ្នកនាងទៅផ្ទះ!»
«អ្នកណាពឹងឲ្យលោកជូនខ្ញុំទៅផ្ទះ?»
«រិទ្ធិ!! បើថាលោកពិតជាចិត្តល្អមែន កំដរខ្ញុំនៅផឹកបន្តិចទៀតទៅ នេះជាម៉ោងលោកសម្រាកតើមែនអត់? លោកទំនេរមែនអត់? ខ្ញុំដឹងថាប៉ាខ្ញុំមិនប្រើលោកទេមែនអត់?»
រិទ្ធិរេភ្នែកសម្លឹងជុំវិញខ្លួនទោះបីថ្មើរនេះផ្លូវស្ងាត់ជ្រងំ ប៉ុន្តែរថយន្តនៅច្រងាងកណ្ដាលផ្លូវបញ្ច្រាសមួយ។ គេឆ្លើយឲ្យរួចពីមាត់ ព្រោះដឹងថានាងស្រវឹង៖
«អូខេ អ្នកនាងអង្គុយក្នុងឡានខ្ញុំសិន ខ្ញុំរៀបរយរថយន្តអ្នកនាងសិន!»
«បាន ធ្វើអីធ្វើឲ្យឆាប់ៗទៅ!»

ស្រីស្អាតដើរលើស្បែកជើងកែងខ្ពស់ស្រួចកុបកុបតម្រង់ទៅកាន់ រថយន្តនាយជំនួយការ ប៉ុន្តែនាងមិនចូលទៅអង្គុយខាងក្នុងទេ បែរជាឈរក្រពាត់ដៃក្បែរទ្វារឡានសម្លឹងមករករថយន្ត។ ភ្នែកនាងមមីដោយសារឥទ្ធិពលជាតិអាកុលកំដរដោយបបូរមាត់ក្រហមដូច ម្ទេសទុំធ្វើឲ្យជំនួយការបើករថយន្តនាងបណ្ដើរ នឹកបារម្ភនាងបណ្ដើរដោយសារផ្លូវថ្នល់ស្ងាត់សូន្យ ហើយនាងស្អាតដល់ម្ល៉ឹង។
«អ្នកនាងពៅ ខ្ញុំនៅផ្លូវ ១០៨ សង្កាត់បឹងកេងកង២ អ្នកនាងជួយទាក់ទងទៅផ្ទះអ្នកនាងអមរាផង ស្ថានភាពគាត់ដូចជាមិនអាចបើកឡានទៅផ្ទះវិញបានទេ!»
បញ្ជូនព័ត៌មានដល់ពៅបញ្ញាបានរួចរាល់ គេអែបរថយន្តទៅដល់ចិញ្ចើមថ្នល់ល្មម។ រិទ្ធិចុះពី

លើរថយន្តរបស់ស្រីស្អាត ហើយដើរតម្រង់ទៅរកនាង ដែលកំពុងឈរក្រពាត់ដៃងាកមករក ហាក់រង់ចាំអ្នក។
«ខ្ញុំទៅយកទឹកជូនអ្នកនាង!»
ស្រីស្អាតតាមសម្លឹងគេ ដែលដើរហួសពីនាងទៅឃ្លុបឡានខាងក្រោយ នាងទើបតែចាប់អារម្មណ៍ថានេះមិនមែនជារថយន្តរបស់ពៅបញ្ញាទេ។ នាងគិតក្នុងចិត្តស្ងាត់ៗ៖
«គេនេះមានលុយពីណាមក ប្រើរថយន្តទំនើបមើលតែកូនអ្នកមាន បើជាឡានលោកប៉ា ថ្មើរណេះ គេមានសិទ្ធិអីយកចេញ?»
ប្រហែលជាឃើញបបូរមាត់និងផែនថ្ពាល់នាងក្រហមដោយជាតិសុរា បានជាជំនួយការកំលោះបើកគម្របដបទឹករួចជាស្រេចមុនពេលហុចទៅឲ្យ នាង។
«អ្នកណាប្រាប់លោកថាខ្ញុំចង់ញ៉ាំទឹក?»
គេមិនឆ្លើយនឹងសំណួរនាង ប៉ុន្តែទឹកនៅតែហុចមកហើយកែវភ្នែករបស់គេនិងទឹកមុខស្មើផេង តែភាពស្រស់សង្ហារបស់គេធ្វើឲ្យនារីហាក់ភ្ញាក់ខ្លួនមកវិញខ្លះ ថា ឬនាងមិនគួរបិតនៅក្នុងស្ថានភាពបែបនេះ កំដរភ្នែកប្រុសកំលោះម្នាក់ឡើយ។

អមរាងាកភ្នែកចេញពីក្រសែភ្នែកនាយ នាងធ្វើជាចចេសនិយាយបន្ថែម៖
«ហើយប៊ីយ៉ែរមួយដបក៏លោកអត់មានដែរ?»
«ញ៉ាំជាតិស្រវឹងច្រើនពេកអត់ល្អទេ!»
តាមពិតគេមិនចង់ប្រើពាក្យថានាងស្រវឹងហើយ ព្រោះដឹងថានាងប្រកែក។ ដឹងអីស្រីស្អាតឆ្លើយមកវិញភ្លាម ទោះបីជានាងបែរខ្នងឲ្យអ្នកក៏ដោយ៖
«សម្រាប់អ្នកផ្សេងវាអត់ល្អ តែសម្រាប់ខ្ញុំវាល្អ! គឺល្អដែលអាចឲ្យខ្ញុំភ្លេចថាខ្លួនឯងជាកូនស្រីដែលឪពុកម្ដាយ លែងលះគ្នា! ជាកូនស្រីដែលមានប្រវត្តិរញ៉េរញ៉ៃ!»
ជំនួយការវិទ្ធិទម្លាក់ភ្នែកសម្លឹងដី ដៃគេមួលបិទដបទឹកសុទ្ធវិញដោយមិនដឹងខ្លួន គេអត់និយាយស្ដីប៉ុន្តែអារម្មណ៍គេវិលខ្វាល់នឹកដល់រឿងស្មុគស្មាញ មួយចំនួន។ សំឡេងស្រីស្អាតលាន់បន្តមកដោយរអាក់រអួល៖
«ប៉ាខ្ញុំនៅក្នុងពេទ្យនៅឡើយ! កូនៗមកជុំគ្នាមានកូនដើមមានកូនចុង! អ្នកម៉ាក់មិនមកព្រោះពួកគាត់មានបញ្ហានឹងគ្នា! ខ្ញុំអត់ខ្វល់ថាពួកគាត់មានរឿងអីទេ! និយាយរួម ខ្ញុំអត់ត្រូវការដឹងអ្វីទាំងអស់ ខ្ញុំត្រូវការពួកគាត់ត្រូវគ្នាវិញ! ប៉ាខ្ញុំមិនដែលនិយាយអីទាំងអស់ តែគាត់ក៏មិនដែល

មកផ្ទះវិញដែរ ទោះបីប្រពន្ធចុងគាត់ស្លាប់ទៅច្រើនឆ្នាំហើយក៏ដោយ! លោកនិយាយទៅមើល រិទ្ធិ ខ្ញុំស្រវឹងជាមួយស្វាងមួយណាល្អជាង!»

នាងបញ្ចប់មនោសញ្ចេតនាញាប់ញ័រនោះអមដោយសំណោកខ្សឹកខ្សួល ហើយទន់ជង្គង់អង្គុយចុះទៅលើផ្លូវ។ ការលួងលោមខ្លួនឯងក្នុងនាមជាជនបង្កប់ព្រមទាំងការលួងលោមខ្លួនឯង ក្នុងការទ្រាំមើលស្រីដែលខ្លួនស្រលាញ់បំផុតត្រូវបានហួងហែងដោយ បងប្រុសធម៌របស់ខ្លួន រិទ្ធិអាចធ្វើបានយ៉ាងល្អ ប៉ុន្តែពេលនេះឲ្យគេមកលួងលោមនារីដ៏ស្រស់ស្អាតម្នាក់ ដែលទើបតែជួបគ្នាពីរលើកគេពិតជាគ្មានវិធីណាឲ្យប្រសើរជាងការ នៅឈរស្ងៀមឡើយ។
«ទម្រាំនាងដឹងថាខ្ញុំជាអ្នកណា ប៉ាធម៌ខ្ញុំជាអ្នកណា ខ្ញុំមកធ្វើជំនួយការនាងដើម្បីអ្វី តើផែនដីនេះនឹងក្រឡាប់ចាក់យ៉ាងណាទៅ? ហេតុអីក៏មនុស្សចាស់បន្សល់នូវបញ្ហាច្រើនម៉េះសម្រាប់នារីស្អាត បរិសុទ្ធ ដូចនាងនិងពៅបញ្ញា?»
គេគិតទាំងអាណិតនាងពេញក្នុងចិត្ត។
នាងឱបដៃកាន់តែតឹងជាងមុន នៅក្រោមសន្សើមរាត្រីដែលកំពុងតែធ្លាក់មកជោកជាំ។
រិទ្ធិទម្លាក់ខ្លួនអង្គុយសន្សឹមៗទល់មុខនាង៖
«អ្នកនាងអមរាចូលទៅក្នុងឡានវិញល្អជាង!»
ស្រីស្អាតបំផុតនៅក្នុងគ្រួសារ ប៉ែន ពេជ្រ ងើបមុខសម្លឹងមុខអ្នកប្រុសទីពីររបស់ ហួត ស៊ីវ។ តំណក់ទឹកភ្នែករលើបរលោងរបស់នាងធ្វើឲ្យបេះដូងរបស់ជំនួយការរិទ្ធិ ទៅជារំជួយញាប់ញ័រ។ ពៅបញ្ញា មិនដែលស្រក់ទឹកភ្នែកសូម្បីមួយតំណក់ឲ្យអ្នកដទៃបានឃើញ ក៏គង់អាចយកបេះដូងជំនួយការរិទ្ធិបានទៅហើយទម្រាំនារីស្អាតថ្នាក់ នេះ ហើយមានទឹកភ្នែកជាអាវុធដ៏មុតស្រួចទៀត។
រិទ្ធិបំភ័ន្តខ្លួនឯងចេញពីភាពលន្លង់លន្លោចនេះដោយធ្វើជានិយាយបន្លប់៖
«អ្នកនាងចូលឡានវិញទៅ ប្រយ័ត្នផ្តាសាយ!»
ស្រីស្អាតនៅតែមិនឆ្លើយទោះបីគេខំនិយាយមកពីរដងហើយក៏ដោយ ធ្វើឲ្យគេងាកទៅមើលមុខនាងវិញសាជាថ្មីចំពេលដែលក្រសែភ្នែកក្រៀម ស្រពោនរបស់នាងឆាបយកអារម្មណ៍អ្នកកំលោះ ឲ្យរន្ធត់ពេញទ្រូងតែម្តង។ អ្នកដកភ្នែកវិញមិនបាន ថាប្រយោគទីបីលែងកើត ប៉ុន្តែត្រចៀកនៅអាចប្រើការបាន ព្រោះគេបានឮសូរសៀងរអាក់រអួលរបស់នាងលាន់មកខ្សាវៗ៖
«រិទ្ធិ! លោកឱបខ្ញុំបន្តិចបានទេ?»

កុំថាឡើយជំនួយការរិទ្ធិដែលមិនធ្លាប់ឱបនារីណាពីមុនមក សូម្បីតែនារីដែលគេលួចស្រលាញ់ជាស្នេហាដំបូងក៏គេមិនដែលហ៊ាន ស្រមៃថាថ្ងៃណាមួយនឹងបានលារង្វង់ដៃទៅឱបនាងនោះដែរ។ គេនៅភាន់ភាំងរវាងភាពរំជើបរំជួលនិងការកំណត់ព្រំដែនខ្លួននឹងនាង ក្នុងនាមជាមនុស្សប្រុសម្នាក់ បើប្រៀបធៀបនឹងយុត្តនាគេគឺខ្ចីបទពិសោធន៍ពេកហើយក្នុងបញ្ហាស្រីៗ ដូច្នេះអ្នកប្រុសទីពីរមិនដឹងទេថាភាពស្ងៀមស្ងាត់របស់គេធ្វើ ឲ្យនារីពាក់កណ្តាលស្រវឹងពាក់កណ្តាលដឹងខ្លួនកាន់តែទន់ចិត្ត ហើយបង្ហូរទឹកភ្នែកយំសសិត។

«ប៉ាខ្ញុំរើសយកពៅបញ្ញាចោលខ្ញុំគាត់មិនដែលមកឱបខ្ញុំទេ ឥឡូវនេះសូម្បីជំនួយការគាត់ក៏ដូចគ្នា!»

នាងយកដៃច្រានអ្នកប្រុសដែលកំពុងតែអង្គុយស្រឡាំងកាំងដូចគល់ឈើ ហើយនាងស្ទុះក្រោកដើរញាប់ស្មេរសំដៅរថយន្តរបស់នាង ធ្វើឲ្យរិទ្ធិភ្ញាក់អារម្មណ៍មកវិញមួយរំពេច។ អ្នកដឹងថាស្ថានភាពនាងបែបនេះ បើឲ្យនាងចូលក្នុងឡានបានហើយបើកចេញទៅលទ្ធផលអាក្រក់ច្រើនជាងល្អ ដូច្នេះហើយអ្នកស្ទុះក្រោករឹងទៅតាមនាងជាបន្ទាន់ មាត់ស្រែកហៅឃាត់នាងថា៖

«អ្នកនាងអមរាៗ!»

អ្នកបោះជំហានវែងៗពីក្រោយនាងខណៈនាងកាន់តែដើរញាប់ស្មេរ ដឹងអីស្រាប់តែនៅពេលអ្នកដើរជិតដល់នាង នាងបែរត្រលប់ក្រោយឱបអ្នកពេញទំហឹង។

ក្នុងវិនាទីដែលរិទ្ធិនៅស្រឡាំងកាំងស្រីស្អាតបានឱបអ្នកពេញរង្វង់ ដៃទៅហើយ។ ដោយសារនាងទាបជាងអ្នកពេក ទោះបីមានស្បែកជើងកែងជាជំនួយក៏មុខនាងទៅទើរនៅត្រឹមដើមទ្រូងអ្នកប៉ុណ្ណោះ។ ឃើញអ្នកប្រុសទីពីរនៅស្ងៀមឈឹងដូចគល់ឈើ អមរាកាន់តែយំគគ្រុករំជួយអស់ដងខ្លួន។ តើបេះដូងបុរសណាដែលសាងឡើងពីថ្ម ដាច់ចិត្តថាមិនលូកដៃទៅស្រវាឱបនាង អ្នកនោះប្រាកដជាមិនមែនជំនួយការរិទ្ធិទេ។ ភាពអណ្តែតអណ្តូងលេចចេញឡើងរយៈពន្លឺភ្នែករបស់អ្នកប្រុសទីពីរ មិនដឹងហេតុអ្វីគេស្រាប់តែចង់ឱបនាងជាខ្លាំង។ គេលើកម្រាមដៃអង្អែលសក់នាងថ្នមៗដោយចិត្តក្តុកក្តួលពន់ប្រមាណ។

ពន្លឺហ្វាឡានបាច់ឆ្វាចពញ្ញាក់អារម្មណ៍រិទ្ធិឲ្យដាច់ចេញពី មនោសញ្ចេតនាទន់ជ្រាយ ស្នូរឈប់ឡានលាន់ម៉ឺតដូចបេះបិទទៅនឹងកំហឹងរបស់ស្រីស្អាតម្នាក់ ទៀត ដែលឈានជើងស្ទុះចុះពីលើរថយន្តនោះ៖

«បងអមរា!»
ជំនួយការរិទ្ធិលាដៃខ្សាកពីនារីអភិជន ព្រោះគេស្គាល់សំឡេងដែលទើបមកដល់នោះច្បាស់ នាងគឺជាកូនស្រីទីបីនិងជានារីដែលរិទ្ធិយល់ថា គ្មានហេតុផលបំផុតនៅក្នុងចំណោមកូនស្រីរបស់ឧកញ៉ាប៉ែន ពេជ្រ។
គេខ្សឹបតិចៗដាក់អមរា៖
«អ្នកនាងសក្ខណាមកហើយ!»
ប៉ែន ពេជ្រសក្ខណា និស្សិតស្រីមកពីអាមេរិកដែលទើបតែព្រលះអ្នកយ៉ាងចាស់ដៃកាលពីប៉ុន្មានថ្ងៃមុននេះ បានបង្ហាញវត្តមានសាជាថ្មី រិទ្ធិដឹងថាប្រហែល ពៅបញ្ញា ជាអ្នកផ្តល់ព័ត៌មានទៅ ដើម្បីឲ្យនាងមកនាំបងស្រីនាងទៅផ្ទះ។
«ស្រីឆ្នាសនេះប្រាកដជាយល់ច្រឡំមិនខាន ពេលដែលនាងមកឃើញខ្ញុំឱបបងស្រីនាង!»
រិទ្ធិគិតក្នុងចិត្តយ៉ាងសោកស្តាយ គ្រាន់តែឃើញទឹកមុខនាងដែលមិនខ្វីសម្លឹងមុខអ្នកក៏រិទ្ធិមានអារម្មណ៍អាក្រក់បាត់ទៅហើយ។ នៅពីក្រោយខ្នងស្រីតូច សក្ខណា សូហ្វ័រឡានមាឌធំក្រអាញស្ទុះចុះមកសស្លើតសស្លក់ក្នុងពេល សក្ខណា និយាយផង ដៀងកន្ទុយភ្នែកសម្លក់រិទ្ធិផង៖
«ពូ! បើកឡានបងទៅផ្ទះ ចំណែកខ្ញុំដឹកគាត់ដោយខ្លួនឯង!»
នាងថាហើយចាប់អូសដៃបងស្រីដែលពាក់កណ្តាលដឹងខ្លួនពាក់កណ្តាល ស្រវឹងតម្រង់ទៅរថយន្ត ធ្វើឲ្យអមរាប្រឹងដើរតាមទាំងត្រដាបត្រដួស។
មិនដឹងនឹកឃើញយ៉ាងម៉េចកូនភ្លោះស្រីរបស់ ហួត ស៊ីវ ស្រាប់តែបែរក្រោយមករកជំនួយការដែលឈរផ្ទឹងជាមួយនឹងវាចាសុភាព ស្លូតបូត៖
«អរគុណហើយបងរិទ្ធិ!»
សម្តីទន់ភ្លន់របស់អមរាធ្វើឲ្យ សក្ខណា ងាកមករកអ្នកប្រុសទីពីរសាជាថ្មីមុនពេលនាងរុញបងស្រីឡើងឡានហើយ បិទទ្វារគ្រាំង។
«កាយវិការនាងដូចគិតថាខ្ញុំធ្វើអីបំពានបងនាងអីចឹង!»
រិទ្ធិគិតទាំងទោមនស្ស។ សម្រាប់អ្នកជាមនុស្សប្រុសគឺអត់បញ្ហាស្រាប់ទៅហើយ ប៉ុន្តែនាងជាមនុស្សស្រី តើនាងនឹងត្រូវម្តាយថាស្តីយ៉ាងម្តេចខ្លះ? ហើយអ្នកផងដែលដឹងរឿងរួមទាំងសូហ្វ័រឡានទៀត គេគិតអាស្រូវពីនាងដូចម្តេចខ្លះ។

ស្រីតូច សក្ខណា បញ្ឆោះឡានហើយបំបោលចេញរឹង ចាកចោលកំលោះមាឌធំខ្ពស់កណ្ដាលរាត្រីកាលស្ងាត់ជ្រងំ។

## ១៩

ឪពុកនិងកូន

...ស្នូរកណ្ដឹងទ្វារដាស់ ហួត ស៊ីវ ឲ្យក្រោកពីគ្រែ។ ទោះបីថ្មើរនេះ លោកអគ្គទេសាភិបាលមិនទាន់លង់លក់ទៅក្នុងដំណេក ប៉ុន្តែគាត់គិតថាអ្នកដែលហ៊ានមកដាស់គាត់ពេលនេះមានតែកូនប្រុស ធម៌ទាំងពីរឬមួយក៏កូនប្រុសបង្កើត ប៉ែន ពេជ្រប្រាថ្នាប៉ុណ្ណោះ។ គាត់ត្រូវភ្ញាក់ផ្អើលដោយសារនៅលើScreenបង្ហាញមុខអ្នកផ្សេងដែល កំពុងឈរក្បែរទ្វារ គាត់លូកដៃបើកគន្លឹះហើយចាប់ផ្ដើមនូវសំណួរខ្លី៖
«យប់ជ្រៅម្ល៉េះប៉េង?»
«ខ្ញុំមានការបន្ទាន់ទាន!»
«ចូលមក!»
Apartment នេះស្ងប់ស្ងាត់ដោយសារ ហួត ស៊ីវ ទម្លាប់រស់នៅតែម្នាក់ឯង វាមិនមែនជាផ្ទះធំរបស់គាត់ទេ ប៉ុន្តែវាជាកន្លែងដែលអាចជួយឲ្យគាត់អណ្ដែតអណ្ដូងនឹកគិតដល់ សង្សារចាស់ដោយគ្មានគេរំខាន។ សម្រាប់លេខាប៉េងទីនេះគឺជាកន្លែងល្អបំផុតក្នុងការមូលបង្កាច់ ជំនួយការវិទ្ធិ៖
«អត់មានពេលទៀតទេទាន! កូនធម៌ទីពីររបស់លោកអគ្គលែងទុកចិត្តបានហើយ ទីបំផុតគេចូលដៃជាមួយ ប៉ែន ពេជ្រ ស្រលាញ់កូនស្រីវា ហើយមិនដែលខ្វល់អំពីការស្វែងរកតម្រុយនៃគម្រោងការរតនៈសោភ័ណនោះ ទេ!»
សម្ដីរបស់ប៉េងធ្វើឲ្យ ហួត ស៊ីវ ដែលទើបតែដើរបានបីបួនជំហានតម្រង់ទៅរកទូរទឹកកកត្រូវបញ្ឈប់ជើង ឈរទ្រឹងវិញ។ ឃើញបុរសចំណាស់ហាក់ត្រូវបានរំញោចដោយសម្ដីប៉ុន្មានម៉ាត់របស់ខ្លួន ប៉េងកាន់តែបានចិត្តស្ទុះចូលទៅក្បែរគាត់ ហើយខ្សឹបដាក់ត្រចៀកតិចៗ៖
«មួយរយៈនេះ អ្នកប្រុសជួលប៉ូលិសស៊ីឈ្នួលឲ្យតាមដានឪពុកធម៌ខ្លួនឯង និងស្វែងរកភស្តុតាងដើម្បីបង្ហាញអ្នកប្រុសយុត្តនាថា ពៅបញ្ញានិងឪពុកវាគ្មានពាក់ព័ន្ធនិងការតាមធ្វើបាបអ្នកប្រុស យុត្តនាទេ!»

ហួត ស៊ីវ បែរក្រោយសម្លឹងមុខប៉េងយ៉ាងមុត។ លេខាដែលដើរតាមបម្រើ ហួត ស៊ីវ ជាងម្ភៃឆ្នាំហើយនេះពិតជាអាចសង្ស័យខ្លះៗថាមុននេះរិទ្ធិពិត ជាអាចទូរសព្ទមករកឪពុកគេរួចស្រេចក៏ដោយ ក៏ប៉េងនៅតែមានជំនឿចិត្តថា រិទ្ធិគ្មានភស្តុតាងគ្រប់គ្រាន់ក្នុងការបកអាក្រាតគេឡើយ៖

«ហេតុអីវាធ្វើអីចឹង?»

«ងាយយល់ទេ អ្នកប្រុសទីពីរគាត់ស្រលាញ់កូនស្រីអា ប៉ែន ពេជ្រ! ជនជាតិចិនមានសុភាសិតមួយឃ្លាថា អ្នកក្លាហាននៅតែមិនអាចឆ្លងផុតដំណាក់ស្រីស្រស់ អ្នកប្រុសទៅនៅផ្ទះនោះយូរមកហើយ ស៊ើបអីក៏មិនចេញគឺវាខុសប្រក្រតីបាត់ទៅហើយ ឥលូវនេះគាត់ខំបញ្ជាក់ឲ្យយុត្តនាដឹងខ្លួនថា ឪពុកកូននោះមិនមែនជាមនុស្សអាក្រក់គឺមានចេតនានាំអ្នកប្រុសធំឲ្យ រួមដៃប្រឆាំងឪពុកខ្លួនឯង!»

«កូនខ្ញុំមិនធ្វើអីចឹងទេ!»

ហួត ស៊ីវ និយាយដោយមាំទាំ៖

«លោកអគ្គខ្ញុំដើរតាមលោកម្ភៃឆ្នាំជាងហើយ តើខ្ញុំដែលធ្វើអ្វីមួយឲ្យថ្លោះធ្លោយដែរអត់ ខ្ញុំស្រលាញ់លោកស្មើនឹងជីវិតរបស់ខ្ញុំ មនុស្សនៅឆ្ងាយពីយើងគឺលែងទុកចិត្តបានហើយ បើលោកអគ្គនៅតែបន្តថាចោរថាកូនខ្លាចថាទម្រាំលោកអគ្គដឹងវាយឺត ពេលទៅហើយ!»

ហួត ស៊ីវ រវេ្ភកគិតចុះឡើង គាត់និយាយមួយៗដោយឥតព្រាងទុក៖

«ឯងគួរតែមានមូលហេតុច្បាស់លាស់ដើម្បីឲ្យខ្ញុំជឿដែរមែនអត់?»

«លោកអគ្គតំណែងកំពូលនៅធនាគារកណ្តាល លោកម្ចាស់ប្រគល់ទៅឲ្យអ្នកប្រុសធំ នៅពេលដែលយើងគ្រប់គ្នាដឹងហើយថា អ្នកប្រុសទីពីរទើបមានសមត្ថភាពគ្រប់គ្រាន់ស័ក្តិសមនឹងតំណែងនេះ! អ្នកប្រុសធំតាំងពីតូចមកដើរលេងរហេតរហូតទីបំផុតមកអង្គុយលើ បល្ល័ង្កចំណែកអ្នកប្រុសទីពីរច្រើនឆ្នាំមកនេះនៅវេទនាកំព្រាឯផ្ទះ ប៉ែន ពេជ្រ ក្នុងនាមជាអ្នកបម្រើគេចុងក្រោយមនោសញ្ចេតនាឪពុកនិងកូនប្រាកដជារលាយដូចអំបិលត្រូវទឹក នឹងសល់តែការប្រណែននិងមិនសុខចិត្ត ទាំងនេះអាចប្រែក្លាយទៅជាគំនុំកប់យ៉ាងស៊ីជម្រៅក្នុងបេះដូងមនុស្ស ហើយភ្លើងគំនុំនេះអាចធ្វើឲ្យឆេះលោកអគ្គបានយ៉ាងងាយ...»

ហួត ស៊ីវ គំហកកាត់៖

«ឯងនិយាយឆ្កួតយកអី សូត្រទ្រឹស្តីរវើរវាយឯងស្មានតែទីនេះជារោងហ៊ីឬ?»

ប៉េងក្តុកក្តាក់ក្នុងចិត្តព្រោះថាច្រើនឆ្នាំមកនេះមិនដែលមាន ពេលណាមួយ ដែលគេផ្លុំសម្តីទៅ

មិនចូលត្រចៀកបុរសខូចចិត្ត ហួត ស៊ីវ នោះឡើយ។
«ឬមួយថាមនោសញ្ចេតនាឪកូនវា គ្មានផ្លូវបំបែកបានមែន? ឯងគិតថាអញព្រមចាញ់ឯងអាក្មេងចិញ្ចើមថ្មល់» ប៉េងលួចគិតក្នុងចិត្ត តែគាត់បានបញ្ឈាទឹកភ្នែកឲ្យស្រក់ចុះមកយ៉ាងប៉ិនប្រសប់។
«ឯងយំធ្វើស្អី? អាយុចំណាស់នេះទៅហើយធ្វើឫកដូចមនុស្សស្រីគ្មានបានការ»
«ខ្ញុំបារម្ភពីលោកអគ្គ ព្រោះថាអ្វីៗអាចនឹងផ្ទុយពីគម្រោងការទាំងអស់របស់យើង ក្មេងនោះនៅជាមួយគេយូរឆ្នាំមកហើយ វាដេកនៅទីនេះតិចជាងដេកនៅផ្ទះនោះ ក្មេងស្រី ពៅបញ្ញានោះជាងដប់ឆ្នាំហើយនៅតែមិនអាចឲ្យអ្នកប្រុសធំអាចបំភ្លេចបាន ទម្រាំបើអ្នកប្រុសទីពីរដែលមានចិត្តទន់របៀបនេះ»
«ឯងក៏ចេះថាគេចិត្តទន់ដែរ ចុះមានរឿងអីកូនខ្ញុំត្រូវដាច់ចិត្តពីខ្ញុំ»
«គេមិនដាច់ចិត្តសម្លាប់លោកអគ្គគឺពិតមែន តែគេអាចថារារាំងគម្រោងការទាំងឡាយរបស់យើង ក៏ដោយសារតែហេតុផលចិត្តទន់អាណិតអ្នកផ្ទះនោះដែរ សរុបមកវិញធ្វើការងារធំប្រើមនុស្សដែលចិត្តល្អពេកច្បាស់ជា បរាជ័យនៅទីបញ្ចប់»
ហួត ស៊ីវ ដៀងកន្ទុយភ្នែកសម្លឹងលេខាប៉េង ព្រោះបុរសចិនវ័យចំណាស់នេះ មិនមែនស្តាប់មិនយល់ទេថា មនុស្សជំនិតកំពុងដៀមដាមថាគាត់ជាមនុស្សចិត្តមិនដាច់ធ្វើស្តេច មិនកើត។ ហួត ស៊ីវ លាន់ម៉ាត់សួរបញ្រ្ជាសទៅវិញ៖
«ចុះឯងចង់ឲ្យខ្ញុំធ្វើម៉េច?»
លេខាប៉េងទឹកមុខស្មើ៖
«បើបញ្ជូនអ្នកប្រុសទីពីរឲ្យទៅឆ្ងាយ ដូចពាក្យចាស់ថាកុំឲ្យយប់យូរសុបិនច្រើន! ក៏ប៉ុន្តែអ្នកប្រុសទីពីរដូចជាដឹងរឿងច្រើនពេកហើយ»
ហួត ស៊ីវ សម្លឹងមុខប៉េងយ៉ាងមុត សម្តីរបស់ប៉េងគឺមានន័យថា សូម្បីតែជីវិតក៏គេមិនចង់ទុកឲ្យដែរ?
ម្ខាងជាមនុស្សជំនិតម្ខាងជាកូនប្រុសដែលស្លូតបូតត្រឹមត្រូវ ហួត ស៊ីវ ត្រូវហ៊ុមព័ទ្ធដោយភាពសង្ស័យ គាត់ជឿថាអ្វីដែលប៉េងធ្វើគឺព្រោះស្រលាញ់គាត់ ប៉ុន្តែបើឲ្យគាត់ងក់ក្បាលសម្លាប់កូនប្រុសទីពីរ ព្រោះតែពាក្យមួយម៉ាត់ដ៏ឆ្កួតលីលាថា យប់យូរសុបិនច្រើននោះ គឺគ្មានសូម្បីមួយភាគរយទេដែលថាអាចនឹងកើតឡើង ។
គាត់ក្រពាត់ដៃទាំងពីរទៅក្រោយ ហើយឆ្លើយច្បាស់ៗ៖

«ឪពុកគម្រក់យ៉ាងណាក៏មិនដល់ថ្នាក់សម្លាប់កូនឯងដែរ ឯងកុំល្ងីល្ងើភ័យស្លន់ស្លោរហួតដល់គិតរឿងឆ្កួតៗអស់នេះ»
ប៉េងឆ្លើយតបវិញរឹងៈ
«លោកអគ្គមិនបាច់សម្លាប់អ្នកប្រុសទីពីរទេ...»

ហួត ស៊ីវ ងាកមុខរឹងៈ
«ឯងមានគំនិតស្អីទៀតហើយ?»
«កូនប្រុសស្រលាញ់ម្ដាយជាងឪពុក លោកអគ្គអញ្ជើញម្ដាយអ្នកប្រុសទីពីរមកនៅផ្ទះធំប្រៀបដូចជាដួងចៃ អ្នកប្រុសទីពីរនៅក្នុងកណ្ដាប់ដៃលោកអគ្គទាំងស្រុង អំណឹះតទៅគេចង់មុជក៏មិនបានជ្រៅ ចង់ហោះទៅលើក៏មិនឆ្ងាយ»
ហួត ស៊ីវ ដៀងភ្នែកសម្លឹងប៉េង បើកុំតែគេរំលឹកគាត់ស្ទើរតែភ្លេចទៅហើយថា កាលពីម្ភៃឆ្នាំមុននេះ គាត់បានសុំក្មេងម្នាក់នេះពីស្រីមេម៉ាយម្នាក់ ដែលធ្លាប់ជាអ្នកបម្រើរបស់អតីតសង្សារគឺជំទាវកុសុមា។ ហួត ស៊ីវ ដឹងថារយៈពេលកន្លងមកវិទ្ធិមិនដែលបោះបង់ចោលម្ដាយ ទោះបីគេមិនបាននៅជាមួយគាត់ តែគេនៅតែចុះឡើងស្រុកកំណើតដើម្បីផ្គត់ផ្គង់និងសួរសុខទុក្ខ។ តើយើងគួរធ្វើតាមលេខាប៉េងយកម្ដាយរបស់គេមកទុកក្នុងដៃជាចំណុច ខ្សោយរបស់គេឬទេ?
ហួត ស៊ីវ គិតក្នុងចិត្តទាំងមិនដាច់ស្រេច តែប៉េងនៅបន្តពោលតឿនៈ
«លោកអគ្គ??»
«តែឯងក៏ត្រូវទុកពេលឲ្យខ្ញុំគិតសិនដែរប៉េង»គាត់ឆ្លើយវិញទាំងតានតឹងពេញក្នុងចិត្ត។

## ភាគទី២០

## តារាម៉ូដែលបុស្បានារី

«ការងាររបស់នាងគឺត្រូវនាំ ហួត យុត្តនា ឲ្យទៅឆ្ងាយពីឪពុកវាក្នុងរយៈពេលពីរសប្ដាហ៍នេះ» ប៉េងនិយាយដោយទឹកមុខមាំ។
តារាម៉ូដែលបុស្បានារីអង្គុយលើសាឡុងដោយទឹកមុខខ្វល់ខ្វាយ។ គ្មានអ្នកដឹងទេថាតារាស្រីដែលកំពុងមានជតារាសីខ្ពស់ត្រដែតក្នុង សិល្បៈម្នាក់នេះ តាមពិតគឺជាក្មួយបង្កើតរបស់លេខាប៉េង។

«តែខ្ញុំទើបតែជួបម្នាក់នឹងបានម្ដងគត់ សូម្បីនិយាយគ្នាមួយម៉ាត់ក៏មិនដែលដែរ ខ្ញុំខ្លាចតែ...»
លេខាប៉េងសើចក្អាកក្អាយដើរមកអង្អែលក្បាលក្មួយស្រី៖
«ពូរៀបចំឲ្យ! ឱកាសជួបគ្នាមិនពិបាកបង្កើតទេ ដែលសំខាន់គឺឯងខ្លួនឯង បុស្បា ត្រូវត្រៀមខ្លួនឲ្យបានល្អបន្តិច»
គាត់រវេក្អែកសម្លឹងក្មួយស្រីពីលើដល់ក្រោម បុរសចំណាស់នេះដឹងថា កុំថាឡើយមេធាវីសម្បុរខ្មៅស្រគាំ ទោះបីនិស្សិតស្រីមកពីជប៉ុន ប៉ែន ពេជ្រអមរា ដ៏ស្រស់ផូរផង់ក៏ស៊ូនឹងក្មួយស្រីគាត់មិនបានដែរ។
«អាម្នាក់នឹងវាគ្រោតគ្រោតបន្តិច តែក្មួយត្រូវចាំណាបុស្បា មនុស្សប្រុសកាន់តែគ្រោតគ្រោតគឺគេកាន់តែខ្វះមនោសញ្ចេតនា ដូច្នោះហើយគេត្រូវការវាបំផុត ពូដឹងថាក្មួយពូឆ្លាតគ្រប់គ្រាន់ក្នុងការនាំវាឲ្យទៅបាត់ខ្លួន ក្នុងពេលពីរអាទិត្យនេះ ពូត្រូវការតែពីរអាទិត្យប៉ុណ្ណោះ!»

តាមពិតលេខាប៉េងមិនសមថាតក់ក្រហល់ដល់ថ្នាក់នេះទេ ប៉ុន្តែផែនការរបស់គេត្រូវផ្លាស់ប្ដូរបន្ទាប់ពីគេចាប់អារម្មណ៍ឃើញ ថាសកម្មភាពរបស់គេត្រូវបានឃ្លាំដោយអ្នកប្រុសទីពីរដ៏ ស្ងប់ស្ងាត់។
«តាមថាយើងអាចអត់ធ្មត់រង់ចាំបាន តែឯង អារិទ្ធិ ឯងជាអ្នកបង្រៀនយើងឲ្យកែឆាកល្ខោនទាំងនេះ ចូលដល់វគ្គផ្ដាច់ព្រ័ត្រតែម្ដង! ជួយអត់បាន យើងមានតែបញ្ចប់ឯងហើយនិង ប៉ែន ពេជ្រ យករបស់នោះដល់ដៃហើយ ហួត ស៊ីវ ជាអ្នកទទួលខុសត្រូវជំនួសយើង!»
លេខា ប៉េងគិតដោយមានទំនុកចិត្តពេញបរិបូរណ៍ ផ្ទុយគ្នាទៅនឹងទឹកមុខក្មួយស្រីដែលនៅទីទើរមិនច្បាស់ពីវិធីដែល ត្រូវទៅលេខាប៉េងងាកទៅរកនាង៖
«ឯងព្រួយរឿងអី?»
«ខ្ញុំខ្លាចតែធ្វើឲ្យខូចការលោកពូទេ»
«បើឯងជាក្មេងបំបង់បាយអីចឹងមែន ដប់ឆ្នាំមុនយើងមិនរើសឯងមកចិញ្ចឹម ខំធ្វើការត្រដាបត្រដួសឲ្យឯងរៀនសូត្រ ថែទាំរូបសម្ផស្សមិនចាញ់ក្មេងស្រីមកពីផ្ទះអ្នកមានៗទេ! បើគ្រាន់តែប្រុសអ្នកដើរលេងហាក់លោតម្នាក់ អត់រៀនអត់សូត្រឯងយកបេះដូងគេមិនបាន ពូមិនចិញ្ចឹមឯងមកអស់តែអង្ករ?»
ស្រីស្អាតនៅតែបង្ហាញភាពព្រួយបារម្ភតាមពន្លឺភ្នែក ធ្វើឲ្យលោកមាខំទប់ចិត្តឲ្យត្រជាក់ អង្គុយចុះថ្នមៗក្បែរនាងដោយបន្ទន់សំឡេងពន្យល់បន្ថែម៖

«ក្មេងនោះពូស្គាល់វាច្បាស់ដូចថ្ងៃ វាគ្មានអីស៊ីជម្រៅត្រូវភ័យខ្លាចទេ តាំងពីតូចមកវាដើរលេង ហាក់លោតមិនដែលចូលសាលា រឿងកាប់ចាក់បាញ់បោះគ្មានអ្នកណាដល់វាទេ ប៉ុន្តែបើរឿង ទន់ត្រជាក់ហើយនឹងស្រីស្អាតទើបអាចយកឈ្នះវាបាន!»
«ទោះយ៉ាងណាគេឥលូវជានាយកធនាគារមួយទាំងមូល អត់ខ្វះឯណាស្រីៗតាមសម្លឹងទេ?»
«ឯងខ្វល់ធ្វើស្អី បើពូមិនអនុញ្ញាតស្រីៗអស់នោះចូលក្បែរគេកើតដែរ!»
បុស្បាដៀងភ្នែករិះគិត ស្របពេលសំឡេងពូនៅតែពោលមកបន្ត៖
«ឯងត្រូវចាំ ត្រីនេះជាត្រីនាគ បើវាស៊ីសន្ទូចឯង ឯងមានសំណាងអស់មួយជីវិត ពេលឪវាដើរ ចូលគុក ប្អូនប្រុសវាស្លាប់អន្តរធានបាត់ ឯងគឺជាជំទាវធនាគារជាអ្នកសោយសុខចុងក្រោយ!»
គាត់លើកដៃអង្អែលសក់ក្មួយស្រីដែលចាប់ផ្ដើមមានស្នាមញញឹមចិញ្ចាច លើបបូរមាត់ដ៏ ក្រហមស្រស់របស់នាង។ បុរសចំណាស់និយាយបន្ថែមខ្សឹបៗ៖
«ដើម្បីរស់សុខសាន្តមួយជីវិតលះបង់ច្រើនបន្តិចក៏គ្មានបញ្ហាដែរ។»

ដូច្នេះហើយនៅពីរយប់បន្ទាប់មក គេឃើញមានពិធីជប់លៀងផ្ទេរតំណែងដ៏អធិកអធមនៅ ធនាគារកណ្ដាលរបស់ ហួត ស៊ីវ។ ទេសាភិបាលថ្មីដែលតាមពិតគ្មានអារម្មណ៍អ្វីរីករាយ ទាល់តែសោះនោះ ខំសំរួមឫកពាស្វាគមន៍ភ្ញៀវស្រីប្រុសដើម្បីតែបំពេញមុខឪពុក។ តែទោះបី យ៉ាងណាមិនទាន់បានដល់មួយម៉ោងស្រួលបួលផង គេចាប់អារម្មណ៍ថាធុញសែនធុញទៅ ហើយ។
ដោយមានមេធាវីនៅក្នុងបេះដូងហើយប្រការសំខាន់គឺនាងកំពុងខឹងគេ យ៉ាងធ្ងន់ធ្ងរ អ្នកប្រុស ធំសសៀរខ្លួនចាកចោលក្រុមមនុស្សដែលមានមុខមាត់ ឆ្ពោះទៅសួនច្បារខាងក្រោយ ស្វែង រកសេរីភាពឲ្យអារម្មណ៍ខ្លួនឯង។
«ស្រីឆ្នាសនាងស្មានថាបិទទូរសព្ទប៉ុន្មានថ្ងៃនឹង ខ្ញុំតាមរកនាងអត់ឃើញ?»
គេគិតក្នុងចិត្តទាំងលូកដៃជ្រែងហោប៉ៅងើយមើលទៅលើមេឃ ដកដង្ហើមវែងៗបន្ធូរភាព តានតឹង ដឹងអីកន្ទុយភ្នែកប្រទះឃើញអ្វីមួយគួរឲ្យចាប់អារម្មណ៍នៅលើ រានហាលជាន់ទីមួយ ចំហៀងខាងស្ដាំដៃអ្នក។ គេងាកមុខទៅកាន់ទីនោះជាបន្ទាន់។ ស្រីស្អាតជាសុបភើម៉ូដែល បុស្បានារីដែលមុននេះប៉ុន្មាននាទី ទើបតែបានបង្ហាញម៉ូដគ្រឿងអលង្ការយ៉ាងស្រស់ប្រណីត នៅឯពិធីខាង ក្នុងធ្វើឲ្យប្រុសៗទាំងចាស់ទាំងក្មេង ស្លុងចិត្តស្ទើរភ្លេចដកដង្ហើមនោះ ពេល នេះហាក់កំពុងត្រូវបានតាមរំខានដោយបុរសស្រវឹងជោកពីរបីនាក់។ តាមថាយុត្តនាគ្មាន

ពេលចាប់អារម្មណ៍រឿងអស់នោះទេ ប៉ុន្តែមើលយូរទៅនារីនោះដូចជាកំពុងព្យាយាមគេច ចេញ ប៉ុន្តែប្រុសពីរនាក់នោះនៅតែព្យាយាមរំខាននាង។
«ក្រែងនោះជាបន្ទប់សម្រាប់អ្នកសិល្បៈស្រីៗ ម៉េចក៏អាចពួកស្រវឹងខួបពីរនាក់នោះចូលទៅបាន ឬមួយវាបុគ្គលិកធនាគារ?»

គិតដល់ត្រង់នេះកាលណា យុត្តនាស្ទុះភ្លែតបកក្រោយចូលទៅក្នុងក្រុមហ៊ុនឡើងជណ្តើរតម្រង់ទៅ ជាន់ទីមួយ ហើយហួសទៅកាន់បន្ទប់តែងខ្លួនរបស់ស្រីអ្នកសិល្បៈ មកដល់ក្នុងបន្ទប់គ្មានស្រមោលមនុស្សសូម្បីតែម្នាក់ ព្រោះការសម្តែងទើបនឹងចប់ អ្នកបង្ហាញម៉ូដទាំងអស់បានចុះទៅលៀងសាយភោជនជាមួយភ្ញៀវប្រុសស្រី នានាអស់ទៅហើយ។ យុត្តនាសម្លឹងឆ្ពោះទៅរានហាលខាងមុខបន្ទប់វិញម្តង ពិតណាស់ថានៅទីនោះនារីដើរម៉ូដកំពុងត្រូវបានចែចង់ដោយបុរសពីរ នាក់។ ដោយសារបន្ទប់នោះខណ្ឌដោយផ្ទាំងកញ្ចក់ ទោះបីអ្នកប្រុសទីមួយបន្តជំហានឆ្ពោះទៅតែគេមិនអាចស្តាប់ឮអ្វី បានឡើយ ក្រៅតែពីឃើញបុរសម្នាក់ដែលស្រវឹងទ្រេតទ្រោតកំពុងលូកដៃចាប់ស្មា នាង ហើយពេលនាងព្យាយាមរត់គេចចេញបុរសទាំងពីរបានបង្ខំទាញដៃនាងមក វិញ។ ចំពោះមុខយុត្តនាដឹងថាមនុស្សប្រុសទាំងពីរនោះបានបណ្តោយឲ្យជាតិ សុរាដឹកមុខឲ្យបញ្ចេញនូវសកម្មភាពអនាចារទៅលើនារីភេទសឹងមិនគួរ ឲ្យជឿ។ គេស្ទុះចូលទៅហួសពីរបាំងកញ្ចក់ដោយទាញកអាវអ្នកនោះត្រលប់ក្រោយគ្រវែងពីរនាក់គេទៅនឹងជញ្ជាំងបន្ទប់មួយទំហឹងកូនប្រុស។ ពីរនាក់នោះទំនងជាចំណាំនាយបាន ទោះបីត្រូវឈឺគួរសមមិនត្រឹមមិនហ៊ានខឹងបែរជាឱនលំទោន៖
«លោកនាយក!»

យុត្តនាមិនមាត់សូម្បីមួយម៉ាត់ តែនាយបានបង្ហាញភាពមួម៉ៅលើផ្ទៃមុខ ធ្វើឲ្យពីរនាក់នោះរកច្រករត់គេចជាប្រញាប់។ ទោះឆ្លាតប៉ុណ្ណាអ្នកប្រុសទីមួយទំនងមិនដឹងទេថាអ្វីៗគ្រាន់តែជាល្បិចមួយ។ គេបែរក្រោយយឺតៗមករកស្រីស្អាតដែលនៅពីក្រោយខ្នង នាងបង្ហាញទឹកមុខឈឺចាប់មិននិយាយស្តីមួយម៉ាត់ហើយដើរបាំងខ្នើច របៀបរបួសជើងតម្រង់ទៅបន្ទប់វិញ។
«នាងប្រាកដជាខឹង ដែលកន្លែងយើងទទួលភ្ញៀវដោយវិធីអសីលធម៌បែបនេះ»
គិតដូច្នេះហើយគេងើបមុខនិយាយបង្អាក់ដំណើរនាង៖
«សុំទោស! ??»
ការដែលធ្វើឲ្យគេនិយាយរកនាង គឺជាជ័យជម្នះមួយរបស់បុស្បានារី។ ពាក្យសុំទោសក្នុងនាម

មនុស្សមានការទទួលខុសត្រូវខ្ពស់ ព្រោះខ្លួនជាម្ចាស់ពិធីបានធ្វើឲ្យនាងត្រេកអរ ប៉ុន្តែទឹកមុខនៅតែស្រពោនក្នុងភាពជាតារាសម្តែងដ៏ប៉ិនប្រសប់។

នាងនិយាយទាំងបែរខ្នងធ្វើដូចជាខ្មាសអៀនចំពោះអ្នកប្រុសធនាគារ៖

«អរគុណលោកនាយក! តែ....លោកជ្រាបស្រាប់ហើយ! ពួកខ្ញុំជាអ្នកសិល្បៈ ខ្ញុំអត់ចង់ឲ្យមានព័ត៌មានទេ!»

យុត្តនាសម្លឹងទៅនាងដែលស្អាតស្រទន់ឆ្លុះជាមួយអំពូលភ្លើងរាត្រី ពណ៌សុវណ្ណ គេទើបតែចាប់អារម្មណ៍ថានាងជាស្រីស្អាតបំផុតក្នុងចំណោមនារីទាំង អស់ដែលគេធ្លាប់បានជួប។ បបូរមាត់នាងញ័រទទ្រើកជាសញ្ញាថានាងខឹងហើយឈឺចាប់ ប៉ុន្តែនាងគ្មានសេចក្តីក្លាហានគ្រប់គ្រាន់ក្នុងការស្វែងរក យុត្តិធម៌ឲ្យខ្លួនឯង។ ប្រការនេះធ្វើឲ្យអ្នកប្រុសធំទើសចិត្តជាងគេ។ យុត្តនាខាំមាត់តិចៗ ហើយលូកដៃទៅចាប់កាន់កដៃនារីដែលមានរូបរាងខ្ពស់ស្មើងជាមួយវាចាបញ្ជា៖

«មកតាមខ្ញុំ!»

តែគេអូសនាងដើរបានតែពីរជំហានប៉ុណ្ណោះ ព្រោះជើងនាងឈឺពេក រហូតភ្លាត់មាត់ស្រែកថាអូយ។

«សូម្បីតែជើងក៏ត្រូវគេធ្វើឲ្យឈឺដែរ នៅចង់លើកលែងឲ្យពួកវាហ្នឹងទៀត?»

គេបន្ទោសតិចៗក្នុងចិត្តតាមទម្លាប់ ដែលមិនងាយនិយាយអ្វីចេញមកច្រើនឡើយ។ ចរិតរញ៉េរញ៉ៃនិយាយស្តីច្រើនរបស់គេគឺទុកប្រើតែជាមួយមេធាវី សម្បុរស្រអែមតែប៉ុណ្ណោះ។ គេសម្លឹងនាង ដែលដើរមកលែងរួចទៅហើយ ក៏ប្រទះឃើញភាពគួរឲ្យអាណិតក្នុងកែវភ្នែកថ្លាយង់ទាំងសង។ នាងសម្លឹងមកអ្នកហាក់ចង់អង្វរថាឲ្យចប់ត្រឹមហ្នឹងចុះ ទុកឲ្យនាងនៅម្នាក់ឯងចុះ តែនាងកាន់តែធ្វើយ៉ាងនេះ គេកាន់តែនឹកក្តៅចិត្តចំពោះមនុស្សស្រីរឹងទាំងទ្វេ។ គេឱនមកត្រកងខ្លួននាងដោយបំពាក់ដៃឆ្វេងរបស់បុស្បាមកលើស្មា ខ្លួន ហើយគ្រានាងចាកចេញពីបន្ទប់នោះតម្រង់មកជណ្តើរឆ្ពោះទៅកាន់អង្គ ពិធីដែលពោរពេញទៅដោយមនុស្សម្នានៅឡើយ។ នៅតាមផ្លូវបុស្បាញញឹមក្នុងចិត្ត៖

«មិនទាន់អីផងខ្ញុំនៅស្និទ្ធនឹងគេដល់ថ្នាក់នេះទៅហើយ! គិតទៅលោកគ្មានអីអស្ចារ្យទេ ទើបតែមួយក្បាច់យកបេះដូងលោកបានទៅហើយ ហួត យុត្តនា!»

នាងធ្វើជារើបម្រះចេញពីរង្វង់ដៃអ្នកប្រុស ធ្វើឲ្យគេខ្សឹបប្រាប់នាងវិញតិចៗ៖

«បើនាងទុកឲ្យវារួចខ្លួន វានឹងធ្វើបាបស្រីៗទៀតណាបុស្បា»

«គេយល់ថាខ្ញុំជាអ្នកសិល្បៈ ជាអ្នកសម្ដែងគេតែងតែមើលងាយ ពួកខ្ញុំអត់ធ្មត់ធ្លាប់ទៅហើយ»
«គេគ្មានសិទ្ធិធ្វើអីចឹងទេ ជាពិសេសនៅកន្លែងរបស់ខ្ញុំ»
គេបន្តគ្រានាងចុះមកខាងក្រោមហើយបន្តហួសទៅលើឆាកក្នុងអង្គពិធី ក្រោមក្រសែភ្នែកងឿងឆ្ងល់និងស្រឡាំងកាំងរបស់ភ្ញៀវគ្រប់គ្នា។ ប្រហែលមានតែលេខាប៉េងទេដែលសប្បាយចិត្តជាងគេក្នុងពេលនេះ។ យុត្តនាធ្វើសញ្ញាឲ្យក្រុមតន្ត្រីបញ្ឈប់ការប្រគំហើយគេនិយាយមួយៗ ដោយប្រើមីក្រូហ្វូន៖
«អ្នកណាជាអ្នកធ្វើបាបនាង សូមបង្ហាញខ្លួនភ្លាម»
ស្ងាត់ច្រៀបមនុស្សងាកមើលមុខគ្នាទៅវិញទៅមក ហើយក្រសែភ្នែកជាច្រើនបាញ់មករកនារីដ៏ស្រស់សោភាវិញ។ ការសម្ដែងជាតួកម្សត់អត់បញ្ហាទេសម្រាប់បុស្បានារី នាងទម្លាក់ភ្នែកសម្លឹងកម្រាលព្រំហើយចាប់ផ្ដើមស្រក់ទឹកភ្នែក នាងរុញអ្នកប្រុសទីមួយចេញហើយខំព្យាយាមឈរដោយខ្លួនឯង។ យុត្តនាបន្លឺឡើងជាលើកទីពីរ ក្រោមកាមេរ៉ាតូចធំរបស់បណ្ដាអ្នកសារព័ត៌មាន៖
«ខ្ញុំស្គាល់ឯងជាអ្នកណា ខ្ញុំឲ្យឯងសារភាពព្រោះចង់ឲ្យឯងទទួលទោសស្រាលជាងនេះ ព្រោះថានេះជាកន្លែងរបស់ខ្ញុំ ខ្ញុំត្រូវរកយុត្តិធម៌ឲ្យនារីម្នាក់នេះ»
បុរសស្រវឹងទាំងពីរដើរយឺតចេញពីក្នុងចំណោមមនុស្ស បង្ហាញខ្លួននៅចំពោះមុខគេឯងធ្វើឲ្យសំឡេងពេបជ្រាយលាន់ឡើងយ៉ាង កងរំពង។
នៅពេលដែល ហួត ស៊ីវ កំពុងតែចំហមាត់និយាយអ្វីមិនចេញ លេខាប៉េងធ្វើជាស្រែកឡូឡា៖
«សន្តិសុខទៅណាអស់ហើយ?»

២១

រវាងមេធាវីស្រអែមស្រស់និងនារីម៉ូដែលសម្រស់គ្មានពីរ

ពៅបញ្ញាបញ្ឈប់ពែងតែនៅត្រឹមបបូរមាត់នាង។
ចិញ្ចើមទាំងគូរបស់អ្នកនាងធំជ្រួញចូលគ្នាដោយចម្ងល់ នាងសើចខឹកចំអកឲ្យសន្លឹកទស្សនាវដ្ដីដែលបើកចំហនៅចំពោះមុខខ្លួន។
«ស្អីគេនេះ? គេនឹងអ្នេស? ជានាយកធនាគារ? អ្នកដែលរើសគេមក ប្រាកដជាមានបញ្ហា!»
ប៉ែន ពេជ្រសក្ខណា ដែលអង្គុយនៅពីមុខតុធ្វើការរបស់បងស្រីខុសម្ដាយ បួញមាត់និយាយធ្វើហី៖

«អ្នកតែងតាំងគេគឺអ៊ំ ហួត ស៊ីវ អគ្គទេសាភិបាលធនាគារហ្នឹង!»
«ឯងស្គាល់គាត់ដែរ? ហើយហៅស្និទ្ធម៉េស?»
«គាត់ស្និទ្ធជាមួយជំទាវម៉ាក់ ឧស្សាហ៍ចេញចូលផ្ទះខ្ញុំ ហើយគាត់ក៏ជាមិត្តជិតដិតរបស់ប៉ាយើងដែរ នេះបើតាមអ្នកម៉ាក់ប្រាប់»
ពៅបញ្ញា ងាកមុខចេញធ្វើហី សំឡេងនាងបញ្ចេញនូវភាពគ្នាន់ក្នាញ់៖
«បើឯងបានជួបអ៊ំនោះ ប្រាប់គាត់ផងឲ្យប្រយ័ត្នចំពោះនាយកធនាគារថ្មីរបស់គាត់! មនុស្សយ៉ាប់ ចរិតយ៉ាប់ សម្ដីក៏យ៉ាប់ ច្បាស់ជាអស់អតិថិជនមិនខាន»
សក្ខណា សើចខឹករបៀបហួសចិត្ត៖
«ឯងដឹងហើយ ពៅបញ្ញា ថាខ្ញុំមិនប្រាប់អ៊ំ ស៊ីវតាមពាក្យឡប់ៗទាំងអស់របស់ឯងទេ»
ពៅបញ្ញា ធ្វើមុខគ្នាន់ក្នាញ់សូម្បីនាងក៏មិនដឹងថា តើនាងស្អប់គេឬមួយក៏ក្នាញ់គេ ទើសចិត្តចំពោះគេគ្រប់យ៉ាងនោះទេ។ សក្ខណានិយាយបន្ត៖
«ឯងដឹងស្រាប់ហើយ ហើយឯងដឹងច្បាស់ជាងខ្ញុំទៀត គេជាកូនប្រុសរបស់អ៊ំយុទ្ធ មិត្តម្នាក់ទៀតរបស់លោកប៉ាយើង ហើយរបស់អ៊ំ ស៊ីវ ផងដែរ! គាត់ប្រហែលជាប្រទានតំណែងឲ្យគេដោយសារហេតុផលនេះ»
«ទោះបីអីចឹងក៏ដោយ មានភក្ដីភាពចំពោះមិត្តភ័ក្ដិក៏ដោយ ក៏ត្រូវមើលចរិតឬកពាចំណេះដឹងនិងសមត្ថភាពអ្នកដែលគួរទទួលតំណែង នោះផង! ធន់គេនេះអី...»
សក្ខណា ចងចិញ្ចើមនិយាយឌឺ៖
«ឯងច្រណែនចង់បានតំណែងនោះដែរមែនអត់?»
ពៅបញ្ញា គ្រវីក្បាលដោយហួសចិត្ត៖
«ឯងឡប់ហើយ តោះទៅញ៉ាំបាយ»
តាមពិតនាងចង់និយាយរំលឹកថាដោយសារម្នាក់នេះ ទើបឪពុកខ្លួនត្រូវចូលពេទ្យ ប៉ុន្តែមើលទៅពិបាកណាស់ព្រោះសក្ខណាមកពីក្រៅប្រទេស នាងមានចរិតឃើញយ៉ាងណាថាយ៉ាងនោះ ចង់ឲ្យនាងជឿទាល់តែបង្ហាញភស្តុតាង។ ចំណែករឿងដ៏វែងអន្លាយរវាងនាងនិងបុរសនោះ តើអាចប្រាប់អ្នកទីបីដោយវិធីណាកើត? ដូច្នេះហើយ ពៅបញ្ញា បិទបញ្ចប់ការនិយាយពីបុរសនោះត្រឹមប៉ុណ្ណោះតែម្ដង។
«ទៅញ៉ាំទៅណា?»សក្ខណា សួរកាត់ការរិះគិតរបស់មេធាវីតូច។
«ស្រេចតែឯងទេ ទៅកន្លែងណាក៏បានដែរ»

«បានមេធាវីប៉ាវម្តង គួររកកន្លែងកប់ពពកបន្តិច»
«បាន តែឯងបើកឡានទៅ»
ស្រីស្អាតទាំងទ្វេចាកចេញពីការិយាល័យមេធាវីដោយមាននិស្សិតអាមេរិក ជាអ្នកបញ្ជាយានយន្តយ៉ាងលឿន និងស្ទាត់ជំនាញតាមទម្លាប់របស់នាងសាជាថ្មី នាងត្រូវរេចង្កូតគេចចេញសឹងមិនទាន់ដោយសាររថយន្តមួយទៀតឡើងមកលើ ផ្លូវជាមួយគ្នា ក្នុងវិនាទីតែមួយ។
«បងរិទ្ធិ?»

ពៅបញ្ញាលាន់ម៉ាត់តិចៗក្នុងពេលជំនួយការរិទ្ធិបើកកញ្ចក់មើលមកនាង នាងក៏បើកកញ្ចក់ឆ្លើយឆ្លង៖
«បងរិទ្ធិទៅណា? ញ៉ាំបាយជាមួយគ្នាអត់»
«ខ្ញុំមានការជាមួយមេធាវីម្នាក់ អ្នកនាងអញ្ជើញចុះ»
អ្នកប្រុសទីពីរឱនគួរសមហើយចាកចេញទៅរកចតឡាន ទុកឲ្យសក្ខណាទៅធ្វើមុខក្រញូវចេញឡានវឹង។
«បើអាគាត់ម្នាក់នឹងទៅបាយដែរ ខ្ញុំនឹងហើយដែលត្រូវចេញពីឡាននេះជិះតាក់ស៊ីត្រលប់ទៅផ្ទះ»
«ឯងកើតស្អីឯង? បងរិទ្ធិស្លូតណាស់ រឿងប៉ះឡានគ្នាពីថ្ងៃមុនឯងជាអ្នកខុសទាំងស្រុង បើឯងគិតថាខ្លួនឯងជាអ្នកនាងហើយចង់ទម្លាក់កំហុសទៅអ្នកដទៃតាម ចិត្ត ឯងមិនដឹងជាទៅរៀនដល់ស្រុកពីរស្រុកបីបានប្រយោជន៍ស្អីឯងទេ?»
«ស្អីនែក? កំពុងមានគេស្ដីឲ្យខ្ញុំដោយសារតែអាអ្នកជំនួយការម្នាក់មែនអត់?»
រថយន្តបោលមិនបានមួយដង្ហើមផង ក៏ដល់សណ្ឋាគារផ្កាយប្រាំយ៉ាងប្រណីត។ សក្ខណាបរឡានយឺតចូលទៅក្នុងបរិវេណសណ្ឋាគារកាត់តាមសួនផ្កាធំ ទូលាយស្រស់បំព្រង។ ពៅបញ្ញានិយាយបន្ថែមតិចៗ៖
«មកពីឯងប្រកាន់គេពេក»
«រឿងថ្ងៃមុនអត់ប្រកាន់ក៏បាន ប៉ុន្តែឯងដឹងអត់យប់ដែលឯងខលមកឲ្យខ្ញុំទៅយកបងអមរា ខ្ញុំឃើញអីឯងដឹងអត់ គេឆ្លៀតពេលបងអមរាស្រវឹងបន្លំឱបគាត់ ចោលម្សៀតអីចឹងមនុស្សប្រុសស្រុកខ្មែរ»
លែងឮពៅបញ្ញាឆ្លើយ សក្ខណាងាកមុខសម្លឹងប្អូនស្រី។

មេធាវីគ្មានអារម្មណ៍ក្នុងការជជែកគ្នាទៀតទេ ព្រោះកែវភ្នែកនាងបាញ់ទម្លុះកញ្ចក់ឡានឆ្ពោះទៅរកវត្តមានប្រុស ស្រីមួយគូដែលកំពុងអង្គុយទល់មុខគ្នានៅក្នុងភោជនីយដ្ឋាននៅកៀក បង្អើយ។ សក្ខណារភ្នែកតម្រង់ទៅទីនោះដែរ គេយល់វត្តមានទេសាភិបាលវ័យក្មេងដែលកំពុងចាប់ម្ហូបដាក់ឲ្យនារី ម៉ូដែលដ៏ស្រស់សោភា បុស្បានារី។
«ផែនដីនេះចង្អៀតមែន»
ស្រីតូច សក្ខណានិយាយធ្វើហីក្នុងពេលមួលសោពន្លត់ឡានផង ស្រាប់តែនាងឮ ពៅបញ្ញានិយាយតិចៗ៖
«យើងគួរទៅកន្លែងផ្សេងវិញ»
សក្ខណាលើកចិញ្ចើមបើកភ្នែកធំៗ៖
«ហេតុអី? កន្លែងនេះគេទិញដាច់មែន?»
ពៅបញ្ញា នៅទីទើរងាកមុខចេញ មិនដឹងយ៉ាងម៉េចបេះដូងនាងលោតកាន់តែញាប់។
«នោះគេមើលមកឯងហើយ»
ពៅបញ្ញា ងាកមកវិញឃើញយុត្តនាកំពុងមើលមកនាងមែន។ អ្នកប្រុសទីមួយពិតជាភ្ញាក់ផ្អើលលាយត្រេកអរដែលបានជួបនាងក្នុង ពេលនេះ ប៉ុន្តែភាគីខាងស្រីទេដែលធ្វើឫកពាដូចមិនចង់ឃើញគេ មិនខ្វីទាំងសម្លឹងគេ។
«គេឃើញឯងហើយ បើឯងមិនចូលទៅមានតាឯងហ្នឹងខ្លាចគេ?»
សក្ខណានិយាយតិចៗដោយបើកទ្វាចុះពីឡានធ្វើព្រងើយ ទោះបីយ៉ាងណាវាចាចុងក្រោយរបស់នាងបំផុសឡើងនូវក្តីមានះក្នុង ចិត្តមេធាវីតូចច្រឡឹង។
«លោកនៅនឹង ស្មានថាខ្ញុំមិនហ៊ានចូលយុត្តនា»

នាងឈានចុះពីលើរថយន្តជាមួយទឹកមុខស្មើផេង សក្ខណាមានចេតនាដើរចូលភោជនីយដ្ឋានកាត់តាមតុដែលបុស្បានារីនិង នាយកធនាគារកំពុងសោយសុខអាហារជាមួយគ្នា។ ពៅបញ្ញាដើរជិតមកដល់អ្នកប្រុសធនាគារងើបពីកៅអីដោយមិនដឹងខ្លួន តាមថាពៅបញ្ញាត្រូវតែដើរហួសទៅធ្វើមិនដឹងហើយធ្វើមិនឃើញ ប៉ុន្តែសក្ខណាធ្វើជានៅទ្រឹងពីមុខតុនោះបាំងផ្លូវនាង។
«លោកនាយកធនាគារ ហួត យុត្តនា មែនអត់?»
នាងនិយាយរួសរាយតាមបែបបស្វិមមិនរវល់នឹងភាពទើសទាល់របស់ប្អូនស្រីខ្លួន។

យុត្តនាបង្ហាញឫកពាគួរសមៈ
«អ្នកនាងគឺ...?»
«ខ្ញុំ ប៉ែន ពេជ្រសក្ខណា»
ពៅបញ្ញាហួសចិត្តនាងងាកមុខចេញទាំងលបគិតក្នុងចិត្តម្នាក់ឯងៈ
«នាងឡប់នេះ! ប្រឹងណែនាំខ្លួនឲ្យគេទៅ ឯងបែបស្មានថាគេនឹងចូលចិត្តប៉ាយើងណាស់ហើយ»
បុស្បានារីក្រោកពីកៅអីសន្សឹមៗក្នុងពេលដែលយុត្តនាបែរទឹកមុខ ព្រោះឮត្រកូល ប៉ែន ពេជ្ររបស់នាង។
«ម្នាក់នេះឈ្មោះ ប៉ែន ពេជ្រសក្ខណា អីចឹងមានតែស្រីខ្មៅម្នាក់ទៀតនេះ ជាមេធាវី ប៉ែន ពៅបញ្ញាមែន?»
នាងគិតហើយរវេភ្នែកសម្លឹងពៅបញ្ញា។ ទោះបីបបូរមាត់នាងខំញញឹម ប៉ុន្តែភ្នែកនាងគឺពិនិត្យពៅបញ្ញាមិនឲ្យសល់កន្លែងណាមួយទេ។ មេធាវីស្រីរូបនេះក៏ជាតួអង្គសំខាន់ ដែលឪពុកមានាងបានរៀបរាប់ប្រាប់នាងជារឿយៗ។ តែដោយសារឃើញថាពៅបញ្ញាងាកសម្លឹងទៅទីផ្សេងធ្វើហី បុស្បារវេភ្នែកមករកយុត្តនាវិញម្តង។ វត្តមានរបស់មេធាវីស្រីសម្បុរស្រអែមពិតមានឥទ្ធិពលកែប្រែកែវភ្នែក លោកនាយកធនាគារឲ្យទៅជាអណ្តែតអណ្តូង។ ទិដ្ឋភាពនេះមិនអាចលាក់ជិតពីការតាមសំគាល់ដោយការពិនិត្យពិច័យ របស់នារីម៉ូដែលឡើយ។
«លោកពិតជាលង់ស្រីខ្មៅងងឹតម្នាក់នេះមែនឬយុត្តនា?»
នាងគិតក្នុងចិត្តតែម្នាក់ឯង។ ចំណែកបេះដូងរបស់យុត្តនាក៏ផុសឡើងនូវសំណួរដូចគ្នាៈ
«ស្រីឆ្នាសនាងបាត់ទៅណាយូរម៉េស? ឃើញមុខគ្នាហើយធ្វើដូចមានគំនុំពីជាតិមុនមក»
ហាក់មិនចង់សូម្បីតែនិយាយមួយម៉ាត់ ពៅបញ្ញានិយាយបន្ទោសតិចៗទៅកាន់សក្ខណាៈ
«ឯងនៅយូរម៉េសអត់ហេវបាយទេ?»
សក្ខណាញញឹមគួរសមចុងក្រោយដាក់នាយកធនាគារទើបចាកចេញទៅតាមប្អូនស្រីប្រដំប្រសងវ័យ។
«គេខំងើបទទួលឯង គ្រាន់តែគួរសមបន្តិចតបទៅគេវិញក៏អត់ដែរ ឯងវាកើតស្អីឯង?»
ពៅបញ្ញាអង្គុយសុខចិត្តសម្លឹងចានម្ហូប ព្រោះមិនចង់ងាកឆ្វេងស្តាំក្រែងប្រទះឃើញបុរសនោះនិងស្រីស្អាតជា នារីម៉ូដែល នាំតែកើតចិត្តសៅហ្មងកាន់តែខ្លាំងឡើង។
«បើមិនស្គាល់ឯងទេ អ្នកមើលមកស្មានតែឯងប្រចណ្ឌពីរនាក់នោះហើយ មនុស្សរួសរាយ

រាក់ទាក់សោះ មកធ្វើមុខយ៉ាប់អីចឹងទៅរួច»សក្ខណាបន្ថែម។
«ចុះឯងឈប់និយាយបានហើយនៅ ញ៉ាំបាយបាននៅ ប្រុសម្នាក់នោះកុំឃើញគេខ្ពស់ កុំឃើញគេទើបតែបានងារជានាយកធនាគារ ចង់ទុកចិត្តទៅរាប់អានគេឲ្យសោះ! ទោះបីប៉ាគេនិងប៉ាយើងធ្លាប់ជាពួកម៉ាកក៏ដោយ គេឥលូវជាអីក៏យើងមិនដឹង ថ្ងៃមុនលោកជួបនិយាយជាមួយគេសុខៗស្រាប់តែលោកប៉ាគាំងបេះដូងចូល មន្ទីរពេទ្យ រហូតដល់ពេលនេះរកតែហានិយាយក៏មិនទាន់រួចផង ឃើញមុខគេកាលណាអស់ឆ្ងាញ់បាយអាលីង»

សក្ខណា សើចខឹករបៀបហួសចិត្ត នាងលើកកន្សែងសលើតុមកក្រាលទ្រាប់លើខ្លួនបណ្ដើរនិយាយបណ្ដើរៈ
«កោតតែឯងរៀនមេធាវី រៀនដើម្បីការពារគេឬដើម្បីចោទប្រកាន់ទេ? ថ្ងៃនោះឯងឃើញហើយតើ ពេលយើងដើរចូលទៅគេក៏ដើរចេញមក គេញញឹមស្រស់ដាក់ឯង បានន័យថាពេលគេជួបលោកប៉ាគ្មានរឿងអីកើតឡើងទេ លោកប៉ាទើបតែមានរឿងលុយ១១លាននោះស្ថានភាពជំងឺឡើងចុះជារឿងធម្មតា នៅសុខៗឯងចោទប្រកាន់គេ មិនយល់ថាហួសហេតុពេកទេអី?»
ពៅបញ្ញា លែងនិយាយស្ដី នាងលើកអាហារបញ្ចុកដាក់មាត់ទាំងគ្មានសូម្បីតែរសជាតិបន្តិច។ នាងនិយាយក្នុងចិត្តម្នាក់ឯងស្ងាត់ៗ «ឯងមិនស្គាល់គេទេសក្ខណា ហើយស្នាមញញឹមគេកាលពីថ្ងៃនោះ គឺញញឹមឌឺដងយើង! មនុស្សដូចគេមិនដែលចេះញញឹមដាក់អ្នកណាដោយស្មោះទេ គេកើតមកសម្រាប់តែនិយាយគ្រោតគ្រាត បញ្ឈឺចិត្តអ្នកដទៃនិងធ្វើឲ្យអ្នកដទៃឈឺចាប់តែប៉ុណ្ណោះ» ។

នៅខាងនារីម៉ូដែលវិញ.....ប៉េងអង្គុយសម្លឹងរូបថតមួយចំនួននៅក្នុង កុំព្យូទ័ររបស់គាត់។ ពីក្រោយខ្នងគាត់បុស្បានារីកំពុងរៀបចំចាក់ភេសជ្ជៈ។ ប៉េងនិយាយឡើងដោយរីករាយៈ
«ធ្វើបានល្អ!»
សំឡេងនារីម៉ូដែលរូបស្អាតតបមកវិញស្របពេលនាងលើកភេសជ្ជៈមកដល់៖
«លោកពូ! ថ្ងៃនោះខ្ញុំបានជួបគេតែមួយម៉ោងជាងទេ! ខ្ញុំយកលេសថាចង់អរគុណគេ ដែលជួយរកយុត្តិធម៌ឲ្យខ្ញុំបានជាគេព្រមចេញមកជាមួយគ្នា។ លោកពូថាគេជាមនុស្សដើរលេងអត់ប្រយោជន៍ម៉េច បើមើលទៅគេដូចជាគ្មានពេលទាល់តែសោះ មើលពីក្រៅទៅគឺគេមិនចាប់អារម្មណ៍នឹងខ្ញុំ មិនអីចឹងទេ គេប្រាកដជាមានការងារអីសំខាន់ត្រូវបំពេញមិនខាន!»

លេខាប៉េងសញ្ជឹងគិត គាត់ក៏មិនយល់ដែរថាហេតុអ្វីកូនប្រុសច្បងរបស់ ហួត ស៊ីវ មើលទៅចោលម្សៀតគ្មានបានការ បែរជាឃើញតារាស្រីលំដាប់លេខមួយហើយ គ្មានចិត្តចែចង់នាងទៅវិញ តើគេពិតជាមានការងារអីដែលសំខាន់ហើយគាត់មិនដឹងនោះ។
«បើ ហួត ស៊ីវ ប្រើវាឲ្យធ្វើអី វាមិនដែលពូមិនដឹងនោះទេ ឬមួយថាក្មេងនេះរបិលរប៉ូចមាត់ក ប៉ុន្តែចិត្តថ្លើមជាសុភាពបុរស!»

បុស្បានារីបន្ត នាងអង្គុយចុះក្បែរលោកពូដោយមុខស្មើក។ ប៉េងនិយាយបន្ថែមទាំងសើចក្នុងបំពង់ក៖
«វាមិនដែល គ្មានស្រមោចណាមិនស៊ីស្ករ ទាល់តែក្មេងអាយុបីឆ្នាំបានជឿវា ចាំមើលទៀតទៅមើល វាទ្រាំនៅមុខដំណាក់ស្រីស្អាតបានប៉ុណ្ណា?»
ដូច្នេះហើយនៅយប់បន្ទាប់ ករណីខូចរថយន្តមួយបានកើតមានឡើងនៅចំផ្លូវដែលយុត្តនាបើកឆ្លង កាត់ជារៀងរាល់ថ្ងៃ រឿងដែលចៃដន្យនោះគឺម្ចាស់រថយន្តជាស្រីស្អាតបុស្បានារី។ គ្រាន់តែឮសូរសន្ធឹករថយន្តរបស់ យុត្តនា រើយ៉េចយក្រោយ នាងដឹងជាស្រេចថាត្រីកំពុងស៊ីនុយ។
«បុស្បាឡានកើតអីណឹង?»
«អត់ដឹងទេ! យ៉ាប់មែនហើយ ខលទៅហ្គារ៉ាសណាក៏គេថាជាងសម្រាកអស់ទៀត!»
«ចាំខ្ញុំជួយមើលឲ្យ!»
កាយវិការរបស់អ្នកប្រុសទីមួយក្នុងការបើកឃ្លុបឡានខាងមុខនិងឱន ពិនិត្យពិច័យដោយសុទ្ធចិត្ត ធ្វើឲ្យស្រីស្អាតតាមសម្លឹងគេដោយពន្លឺភ្នែកអណ្ដែតអណ្ដូង។ បុស្បានារីដណ្ដឹងសួរខ្លួនឯងក្នុងចិត្តស្ងាត់។
«លោកពូ! ពូថាគេជាមនុស្សហក់លោតចោលម្សៀតគ្មានបានការ តែខ្ញុំមិនយល់ថាអីចឹងសោះ គេមើលទៅជាសុភាពបុរស រូបរាងស្រស់សង្ហា បើគេគ្មានសមត្ថភាព គ្មានបានការធ្វើម៉េចគេអាចក្លាយជានាយកធនាគារតាំងពីអាយុ ប៉ុណ្ណឹងទៅ ឬមួយសកម្មភាពនិងទង្វើល្អៗអស់នេះ គេមិនធ្លាប់សម្ដែងទៅកាន់អ្នកណាពីមុនមកបានជាពូមិនដឹង? នេះជាអាថ៌កំបាំងរបស់គេមែនទេ? ហើយគេបញ្ចេញវាសម្រាប់តែនារីដែលគេចាប់អារម្មណ៍មែនទេ?»

ទម្លាប់ឲ្យតម្លៃខ្លួនឯងខ្ពស់លើសពីនារីនានា គឺជាទម្លាប់របស់បុស្បានារីជាពិសេសនៅពេលដែលគេងាកមករកនាង ហើយប្រាប់ថាគេមិនអាចធ្វើវាបានទេ ហើយគេក៏ជូននាងទៅផ្ទះ។

«កុំបារម្ភពីឡាននោះ នឹងមានមនុស្សមកអូសយកទៅធ្វើ! ខ្ញុំខលប្រាប់គេរួចហើយ!»
ការរួមរថយន្តជាមួយបុរសដែលជាគោលដៅរបស់ខ្លួន ធ្វើឲ្យបុស្បាយល់ថានាងកំពុងបិតនៅក្នុងឱកាសមាស ដើម្បីឈានឲ្យបានទៅដល់វគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រ។
«ខ្ញុំសុំទោសដែលរំខានលោកច្រើនយ៉ាងនេះ! ថ្ងៃមុនធ្វើឲ្យខូចកម្មវិធីលោក ថ្ងៃនេះមកធ្វើឲ្យលោករង្វល់ជាមួយរថយន្តដ៏ចាស់ជរារបស់ខ្ញុំ ទៀត!»
ជាបុរសគ្មានល្បិចកលម្នាក់ យុត្តនាមិនបានចាប់អារម្មណ៍ទេថា ហេតុអីនៅសុខៗគេឧស្សាហ៍ជួបនារីម្នាក់នេះតទល់តែពីរនាក់ ឯណាទៅជំនួយការរបស់នាង ហើយឯណាទៅរថយន្តទំនើបរបស់នាងក្នុងនាមសុបភើម៉ូដែលកំពុងមាន ទីផ្សារ។
គេមិនដឹងទេថា មធ្យោបាយសាច់កម្មជិះឡានកញ្ចាស់ខូចឡាន សុទ្ធជាមធ្យោបាយដែលធ្វើឲ្យប្រុសៗយល់ថា នាងជាតារាត្រឹមត្រូវ មិនរកស៊ីផ្លូវកាត់ក្រៅពីសិល្បៈ។
គេឆ្លើយតបធ្វើហីៈ
«កុំគិតច្រើនពេក សុទ្ធតែរឿងខ្ញុំអាចជួយបាន ណាមួយផ្ទះយើងនៅក្បែរគ្នាផង!»
តាមពិតអ្វីគ្រប់យ៉ាងពាក់ព័ន្ធនឹងយុត្តនាត្រូវបានប៉េងប្រាប់ បុស្បាគ្មានសល់អ្វីទេ រួមទាំងកន្លែងគេស្នាក់ទៅ ផ្លូវដែលគេជិះកាត់ កន្លែងដែលគេត្រូវទៅកម្សាន្ត ស្រីដែលគេស្រលាញ់ និងស្រីដែលត្រូវរៀបការនឹងគេ។
ប៉ុន្តែនាងធ្វើពើជាមិនដឹងអ្វីទាំងអស់ ដោយបើកភ្នែកទាំងគូភ្លឺចិញ្ចាចសម្ដែងហាក់នាងភ្ញាក់ផ្អើលជាខ្លាំងៈ
«នៅជិតគ្នា?»
«ត្រូវហើយខ្ញុំនៅកម្ពុហោស៍!»
«អូ! កម្ពុហោស៍ អីចឹងយើងជាអ្នកជិតខាងគ្នា!»
យុត្តនាញញឹមបង្ហាញស្នាមខួចដែលមេធាវីចងចាំមិនងាយភ្លេចក្នុងជីវិត នាង។ ក៏ជាបបូរមាត់ដែលធ្លាប់ថើបនាង ពេលនេះបែរជាញញឹមប្រិមប្រិយដាក់តារាស្រីដ៏ស្រស់សោភាម្នាក់ ដៃគេដែលធ្លាប់តែបត់ចង្កូតឡានគ្រវែងក្រវាត់រហូតដល់នាងជ្រុះ ទាំងស្បែកជើងទៀត ពេលនេះបែរជាបើកទ្វារជំនិះនិងចុចជណ្ដើរយន្តជូនតារាស្រីដល់ បន្ទប់ស្នាក់នៅ បើពៅបញ្ញាដឹងតើនាងគិតយ៉ាងណា?
«ឡើងញ៉ាំកាហ្វេសិនអត់?»
«អត់ទេយប់ជ្រៅហើយ ខ្លាចរំខានអ្នកនាង!»

ស្រីស្អាតបង្ហាញភាពស្លូតបូតនឹងការទទួចតាមរយៈពន្លឺភ្នែកដែលនាងសម្លឹងមកនាយៈ «សម្រាប់ខ្ញុំអត់យប់ទេថ្មើរណោះ! ញឹកញាប់ណាស់ដែលខ្ញុំចតដល់ម៉ោងបីភ្លឺ បើលោកនាយក មិនប្រកាន់ឲ្យខ្ញុំសុំរាប់អានផង លោកហត់ដោយសារខ្ញុំយ៉ាងនេះ យ៉ាងហោចណាស់ក៏បាន ឆុងតែមួយពែងសងគុណវិញដែរ មែនអត់!»

ទម្លាប់ចុះចាញ់ភាពទន់ភ្លន់គឺជាចរិតរបស់យុត្តនា។ ការងារសប្តាហ៍ដំបូងនៅធនាគារធ្វើឲ្យគេតឹងតែងជាខ្លាំង។ យប់នេះគេគិតថាគេនឹងចំណាយពេលរំខានមេធាវីតូចរបស់គេសាជាថ្មី ប៉ុន្តែគេក៏មិនដាច់ចិត្តបដិសេធចំពោះពាក្យសុំរាប់អានត្រង់ៗ របស់ស្រីស្អាតម្នាក់នេះដែរ។ អ្នកប្រុសទីមួយញញឹមជំនួសឲ្យពាក្យថា yes ហើយគេឈានចូលទៅក្នុងជណ្ដើរតាមពីក្រោយនាង។ ស្រីនិងប្រុសនៅកន្លែងស្ងាត់តែពីរនាក់ គ្មានអ្វីក្រៅពីអារម្មណ៍ស្នេហានោះទេ យុត្តនាលោកសម្លឹងកំភួនជើងសខ្ចីនិងរាងកាយដ៏ស្រស់ល្វតល្វន់របស់ តារាម៉ូដែលរូបនេះ តាមសភាវៈជាមនុស្សប្រុស។
ជណ្ដើរយោងទៅលើយឺត សំណួរលេចឡើងក្នុងចិត្តអ្នកៈ
«ម៉េចក៏ដូចជាមានអារម្មណ៍ប្លែកៗ ឯងកំពុងត្រូវគេញ៉ែមិនដឹងយុត្តនា?»
នៅពេលនាយកំពុងគិត ស្រាប់តែស្រីស្អាតងាកមកក្រោយរឹងចំពេលអ្នកកំពុងសម្លឹងនាង រកតែដកភ្នែកទៅវិញក៏មិនទាន់ធ្វើឲ្យខ្សែចក្ខុទាំងពីរវិញ ត្របាញ់ចូលគ្នា បញ្ជាឲ្យបេះដូងទាំងសងខាងកើតភាពញាប់ញ័រតាមធម្មជាតិនៃ ប្រុសកំលោះនិងស្រីក្រមុំ។ យុត្តនាស្រាប់តែចាប់អារម្មណ៍ថា មានអាថ៌កំបាំងអ្វីម្យ៉ាងដែលបុស្បានារីបានបញ្ចេញវាមកតាមរយៈទឹក មុខរបស់នាង គេខំញញឹមទប់ស្កាត់អារម្មណ៍ថ្មីៗរបស់ខ្លួន ហើយទ្វារជណ្ដើររបើកខ្វាក ធ្វើឲ្យអ្នកអាចចាកចេញមួយគ្រាពីភាពច្របូកច្របល់ នាងចាក់សោបន្ទប់ហើយអញ្ជើញអ្នកប្រុសចូល ដោយចាប់ផ្ដើមបំពេញភារកិច្ចជាម្ចាស់ផ្ទះ រៀបចំភេសជ្ជៈនិងផ្លែឈើ។

យុត្តនាអង្គុយលើសាឡុងភ្នែកតាមសម្លឹងនាងមិនដាក់ភ្នែក ព្រោះកាលបើនារីម៉ូដែលដ៏ល្បីឈ្មោះម្នាក់មកធ្វើការងារអស់នេះ ផ្គាប់ផ្គុនអ្នក វាពិតជាទិដ្ឋភាពដ៏ពិសេសមួយ។ លោក នាយកធនាគារអាចរារាំងចិត្តខ្លួនឯង មិនឲ្យនិយាយអ្វីលើសលស់ទៅលើនាង តែគេបានផ្ដល់សេរីភាពឲ្យខ្លួនឯងពេញទំហឹងក្នុងការស្រង់ក្លិនដ៏ ក្រអូប នៅពេលដែលនាងមកអង្គុយក្បែរគេ។
«អរគុណណាស់បុស្បា! ធម្មតាៗទៅបានហើយ!»

«បើលោកទុកខ្ញុំជាមិត្តម្នាក់កុំនិយាយពាក្យអស់នេះ!»
នាងនិយាយដោយផ្ទៃមុខស្រពោនហាក់បង្ហាញថានាងប៉ុណ្ណឹងដែរបែរជាបុរសមិនយល់ចិត្ត។
«នៅតែម្នាក់ឯងទេ?»យុត្តនាសួរបន្ទប់។
«ចាស៎ ខ្ញុំជាកូនកំព្រា!»
នាងកាន់តែបង្ហាញភាពស្រងេះស្រងោចពេលលើកកែវទឹកមកជូនអ្នក។
បុរសទទួលយកទាំងអាណិតនាងព្រួច។ គេក្រេបភេសជ្ជៈនោះជាការគួរសម ចំពោះស្រីស្អាត និងមិនចង់ឲ្យនាងស្រពោនជាងនេះឡើយ។
«ខ្ញុំត្រូវគេធ្វើបាបតាំងពីតូចៗមក ទម្រាំបានប៉ុណ្ណេះ ទើបតែមានលោកម្នាក់ទេ ដែលម្ដងជាពីរដងល្អចំពោះខ្ញុំ!»
យុត្តនាដៀងភ្នែកសម្លឹងនាង។ នាងពិតជាគួរឲ្យទន់ចិត្ត។ គេដឹងថាស្រីម្នាក់នេះកំពុងមានអាកប្បកិរិយាទោរទន់ចំពោះខ្លួន ដោយសារតែខ្លួនបានធ្វើល្អលើនាង។ គេកាន់តែមានអារម្មណ៍ល្អចំពោះនាងទ្វេឡើង បើប្រៀបធៀបទៅនឹងពៅបញ្ញា។
«ពៅបញ្ញានាងនឹងបុស្បាម៉េចក៏ខុសពីគ្នាដូចមេឃនឹងដី? នាងកាចឆ្នាសគ្មានទិសតំបន់ សម្ដីគ្មានប្រមាណខ្លួន ប្រើដៃប្រើជើងសូម្បីតែជាមួយមនុស្សប្រុស! កោតតែខ្ញុំនឹកនាងស្ទើរគ្រប់ដង្ហើមចេញចូល! នាងខ្មៅក្រិតអើយ!»
គេនៅស្ងៀមដោយទឹកមុខស្រទន់ធ្វើឲ្យបុស្បា បានចិត្តតាមសម្លឹងអ្នកប្រុសទីមួយដោយ ខ្សែភ្នែកស្រទន់។
យុត្តនាងាកមុខគេចចេញពីមនោសញ្ចេតនានោះ អ្នកក្រោកឈរដោយវាចាទន់ភ្លន់៖
«ខ្ញុំគួរត្រលប់ទៅវិញ ទុកពេលអ្នកនាងសម្រាក!»
ស្រីស្ងួនក្រោកមកតាមដោយទម្លាក់ភ្នែកសម្លឹងព្រំ។ នាងដឹងថានេះជាកាយវិការបញ្ជាក់ថា គេគ្មានសូម្បីតែចំណាប់អារម្មណ៍អ្វីចំពោះនាងឲ្យលើសពីទឹកមួយ កែវដ៏គួរសមនេះ។
«ខ្ញុំរំខានលោកណាស់!»
សូរសំឡេងនាងពោរពេញដោយភាពទោមនស្ស ធ្វើឲ្យបុរសងាកមកវិញសម្លឹងនាងព្រោះមិនដាច់ចិត្ត គេនិយាយតិចៗ៖
«យើងជាកូនកំព្រាដូចគ្នា! មិនបាច់ខ្លាចចិត្តទេ! ថ្ងៃក្រោយមានការអ្វីត្រូវការឲ្យខ្ញុំជួយនាង ត្រូវរកខ្ញុំភ្លាមណ៎ាបុស្បា!»

គេចាកចេញទៅទាំងចិត្តនាងនៅស្តាយស្រណោះនៅឡើយ តែនាងត្រូវបង្ខំចិត្តទទួលយក ដោយសារនៅតែមានក្តីសង្ឃឹមថា នាងនឹងបានគេមកក្នុងដៃនៅក្នុងពេលឆាប់ៗនេះ។
ចំណែកបុរសអ្នកហាក់លោតគេចុះមកដីវិញទាំងអារម្មណ៍វិលខ្វាល់ជុំវិញ បញ្ហាមួយ។ ទោះបីយ៉ាងណាគេនៅតែយល់ថា នារីនេះហាក់ដូចជាមានភាពទាក់ទាញនាយពេកហើយ។ ទាំងអាកប្បកិរិយា ទាំងសម្តីសំដៅ នាងហាក់ទន់ភ្លន់អ្វីយ៉ាងនេះ មិនសមថាតារាស្រីល្បីម្នាក់មកទន់ជ្រាយដាក់បុរសម្នាក់ដោយងាយ ព្រោះគ្រាន់តែបានជួបគ្នាពីរបីដងប៉ុណ្ណឹងទេ។ មកពីនាងមានអតីតកាលឯកោពេក? មិនដែលមានគេយកចិត្តទុកដាក់?
សមដែរ?....នាងជាតារាល្បីម្នាក់ អ្នកគាំទ្រតាមយកចិត្តយកថ្លើមមានគ្រប់ជំហាន នៅមិននៅនាងក្លាយជាតួកម្សត់ម្លឹងទៅកើត? តើនាងចង់បានអីពីយើង? នាងស្រលាញ់យើង?
គេសើចហួសចិត្តនឹងសំណួររបស់ខ្លួនឯង រហូតដល់ឡើងមកដល់បន្ទប់ជាន់ទី៦ដែលនៅជាប់ខាងគ្នា។ ភ្លើងមិនទាន់ ចុចបំភ្លឺស្រួលបួលផងសំឡេងរិទ្ធិស្វាគមន៍គេពីក្នុងសាឡុងមក៖
«សប្បាយចិត្តម៉េះគ្រាន់តែបានកាហ្វេគេមួយកែវ?»
យុត្តនាដឹងថារិទ្ធិមានការសំខាន់ណាស់បានជាឡើងមករកគេទាំងយប់ ហើយមកសំងំចាំក្នុងបន្ទប់ស្ងាត់ៗទៀត។
«ឲ្យមនុស្សយកឡានបុស្បានារីទៅធ្វើឲ្យនាងហើយនៅ?»
«រួចរាល់ហើយទាន! អរគុណដែលប្រើសេវាកម្មខ្ញុំ!» រិទ្ធិនិយាយឌឺចំណែកយុត្តនាថយមកអង្គុយលើសាឡុងក្បែរនោះដែរ ដោយទ្រេតក្បាលច្រងាងដៃទាំងពីរដោយហត់នឿយ។
«ម៉េចដែរជីវិតជានាយកធនាគារសប្តាហ៍ដំបូង?»
«ធុញណាស់! ឯងកុំសួរមើល៍!»គេបង្ហាញទឹកមុខហត់នឿយនិមិត្តតែឮពាក្យធនាគារនោះសេរីភាពគេហាក់ត្រូវរារាំងឲ្យតែគេនឹកឃើញដល់តំណែងដ៏ធ្ងន់លើស្មា គេ។
«ម៉េចក៏គ្រាន់បើដែរ ស្រីតាមឲ្យដូចស្រមោច!»រិទ្ធិនិយាយឌឺធ្វើហីហើយដើរទៅវែករាំងននចេញស្រូបខ្យល់អាកាសឯរានហាលខាងក្រៅដោយសម្លឹងទៅជាន់ខាងក្រោម ដកដង្ហើមវែងៗ។
យុត្តនាស្គាល់គេយូរហើយ នាយដឹងថារិទ្ធិកំពុងស្មុគស្មាញចិត្ត គេរិះគិតដោយស្ងាត់ស្ងៀមដូចគ្នា មុនពេលនិយាយបន្ថែមដាស់តឿន៖
«ឯងចេញទៅឈរនៅក្រៅហ្នឹង ខ្លាចពួកអ្នកស៊ើបការណ៍វាមិនដឹងឯងជាមួយខ្ញុំស្គាល់គ្នា?»
រិទ្ធិបែរដើរចូលមកវិញយឺតៗទាំងញញឹម៖

«ឥឡូវ ចេះប្រយ័ត្នជាងមុនហើយ?»
យុត្តនាមិនខ្វល់នឹងសំណួរបញ្ឆោះនេះ គេនៅតែរក្សាសភាពរិះគិតក្នុងគ្រាប់ភ្នែកទាំងសង។ បប្ចូរមាត់គេបួញក្រេបទឹកត្រជាក់តែមុខគេកាន់តែត្រជាក់ជាងហ្នឹងទៅ ទៀត។ គេគិតអ្វីក៏មិនដឹងតែរិទ្ធិយល់ថា បងធម៌ខ្លួនក៏មិនមែនងាយស្រួលឲ្យអ្នកណាបោកប្រាស់ដែរ។ អ្នកប្រុសទីពីរដាក់បង្គុយតទល់មុខយុត្តនាហើយអត់ធ្មត់រង់ចាំ រហូតដល់អ្នកប្រុសទេសាភិបាល ហើយហើបមាត់និយាយមួយៗ៖
«ចេះតែមានអារម្មណ៍ថាអ្វីៗជុំវិញខ្លួនដូចជាមិនសូវស្រួលសោះ!»
«ចង់និយាយរឿងណាមួយ? ការងារនៅធនាគារ ឬរឿងឆាកសង់ទីម៉ង់របស់ឯង?»
«ឆាកសង់ទីម៉ង់ស្អីឯង!»
«រឿងបុស្បានារី! ស្រីតារាម្នាក់នោះដូចជាមានគេនៅពីក្រោយ!»

យុត្តនាសើចស្ងួត ងើយភ្នែកសម្លឹងពិតានធ្វើហី៖
«មនុស្សប្រុសសង្ហាចិត្តបានសម្តីសំដៅល្អ ស្រីស្អាតតាមស្រលាញ់ជារឿងធម្មតា បើឯងចង់ចេះក្បួនញ៉ែស្រីខ្លះ ហាមកឲ្យត្រង់ៗមក! ហើយស្រីតារាម្នាក់នេះ ក៏មិនទាន់ប្រាកដថាត្រូវចិត្តគ្នាដែរ!»
«តែគេត្រូវចិត្តនឹងឯងរួចហើយ!»
យុត្តនាញាក់ស្មារបៀបអំនួត។
«អីចឹងរឹតតែជួយមិនបានទៀតហើយ! រឿងស្នេហាបង្ខំចិត្តអត់បានទេរិទ្ធិ! យ៉ាប់ដែរឲ្យតែស្រីដែលឯងពេញភ្នែកសុទ្ធតែត្រូវចិត្តយើង?»
រិទ្ធិដឹងថាយុត្តនាកំពុងឌីលេង ប៉ុន្តែគេនិយាយមែនទែនវិញ៖
«នាងបង្ហាញខ្លួនដូចជាឆាប់ពេក ឯងគួរយកខួរក្បាលគិតខ្លះហើយ!»
«២០១៤ហើយ! សម័យឥលូវគេស្រលាញ់គ្នាមិនបាច់យូរពេកទេ!»
រិទ្ធិសើចខឹកៗ គេលែងនិយាយធ្វើឲ្យយុត្តនាទ្រាំមិនបានសួរវិញ៖
«សើចស្អី?»
«ឯងក៏មិនមែនល្ងង់ដូចសម្តីឯងដែរ! មាត់ផ្សើងចិត្តផ្សេង! ឯងដឹងហើយថាកំពុងលេងល្ខោនអស់នេះ!»
យុត្តនាបួញមាត់ក្រេបទឹកបន្តហើយបណ្ដោយបប្ចូរមាត់ឲ្យនៅទើរនឹងមាត់ កែវ គេមិនស្តីតែ

នៅចាំស្ដាប់សម្ដីគូកនក្នុងពេលរិទ្ធិនិយាយមកបន្ត៖
«ល្បិចខ្សោយៗ! តារាល្បីម៉្លឹងៗដើរខូចឡានអត់សូហ្វ័រ? ហើយមកខូចចំផ្លូវឯងជិះកាត់រាល់ថ្ងៃទៀតលោកទេសាភិបាល? អ្នកសិល្បៈកម្រិតលេខមួយជិះឡានចាស់បែបនេះមានគេជឿដែរ?»
យុត្តនាញញឹមចុងមាត់ គេបន្ថែមពីក្រោយរិទ្ធិ៖
«មួយអាទិត្យមុនទើបតែរើមកនៅក្បែរ Apartment ខ្ញុំទៀត? ចង់ដឹងដែរតើ! គេធ្វើរឿងច្រើនយ៉ាងនេះ ដើម្បីអ្វីទៅ?»
យុត្តនាញញឹមតែគេកំពុងសញ្ជឹងគិត តើស្រីម្នាក់នេះមានបំណងអី នាងដាក់ខ្លួនពេកហើយ នាងទន់ភ្លន់ពេកហើយ មិនសមថាទើបតែជួបគ្នាប៉ុន្មានដង នាងលេងល្ខោននឿយហត់ដល់ម៉្លឹងទេ។រូបរាងប៉ុណ្ណេះដែរមិនដែលថាមិន ធ្លាប់ចុះស្នាមរឿងស្រីតាមស្រលាញ់ទេ ដល់ថ្នាក់ស្រីៗគ្រាន់តែកម្រើកដៃយុត្តនាដឹងថានាងលេងស្នៀតអីទៅ ហើយ តែលើកនេះទៀត គេក៏ចង់គិតថាស្រីៗស្រលាញ់បុរសម្នាក់  គេបង្កើតឱកាសឡើងមកជារឿងធម្មតា តែដល់ថ្នាក់ដូរផ្ទះមកនៅក្បែរ ដកជំនួយការលែងឲ្យដើរតាម ដូរឡានទំនើបមកជិះឡានខូច ផែនការអស់នេះមិនដឹងថា អ្វីទៅជាគោលដៅដែលនាងចង់បានទេ។ គេលាន់មាត់តិចៗ៖
«ខ្ញុំគ្មានអីគួរឲ្យនាងចង់បានស្រាប់ហើយ! ឯងមិនមែនមិនដឹងទេ!»
រិទ្ធិអង្គុយគោះដៃមិនមាត់ យុត្តនាហើបមាត់ពោលបន្ថែមយឺតៗ៖
«កាលនៅជណ្ដើរយន្ត កូនចៅខ្ញុំតែមកប្រាប់ថា នាងធ្លាប់នៅជាមួយអ្នកណាឯងដឹងអត់?»
«អ្នកណា?»
«ប៉ែន ពេជ្រប្រាថ្នា!»

រិទ្ធិជ្រួញចិញ្ចើម។ ខាងគេខ្លួនឯង គេស៊ើបដឹងត្រឹមថានាងជាក្មួយចិញ្ចឹមលួចលាក់របស់បុរសចិនសម្បូរ ល្បិចព្រោះគេចាប់អារម្មណ៍គ្រប់យ៉ាងទាក់ទងតែនឹងបុរសនោះ មិនស្មានដល់ទេថាភាគីខាងយុត្តនាដឹងរឿងរបស់នាងជ្រៅជាងនេះ ទៅទៀត។
គេអង្គុយទ្រេត ហើយលើកកំប៉ុងទឹកក្រូចពីមុខខ្លួនដែលម្ចាស់ផ្ទះទើបតែទម្លាក់ឲ្យ មកកាច់ក្រេបកម្ដៅចិត្ត។ កំសួល Pepsiមិនបានជួយបន្ធូរចម្ងល់ទាំងឡាយក្នុងបេះដូងអ្នកប្រុសទីពីរដ៏រាបសាតែម៉ត់ចត់នេះឡើយ។
បើនៅសុខៗនារីអាថ៌កំបាំងម្នាក់ព្យាយាមបង្ហាញខ្លួនម្ដងជាពីរដង ក្បែរជីវិតយុត្តនា ហើយទី

បំផុតនាងមានពូម្នាក់ដែលជាមនុស្សជិតស្និទ្ធរបស់ប៉ាគេ គ្រប់យ៉ាងហាក់បីដូចជាក្រឡាអុកដ៏គួរឲ្យសង្ស័យមួយ។ ទោះយ៉ាងណាវានៅមិនទាន់ស្មើនឹងអតីតកាលរបស់នាងជាមនុស្សធ្លាប់នៅ ក្បែរធុរកិច្ចជនសុភាពបុរសក្លែងក្លាយ ប៉ែន ពេជ្រប្រាថ្នានោះដែរ។

«បើដឹងអញ្ចឹង មិញសុំនៅបន្ទប់គេមួយយប់ហ្មងហើយ! គេថាបើស្រីស្រលាញ់កុំធ្វើឫកច្រើនពេក! ដូចបុស្សាក៏មិនអន់ដែរ!»

ដឹងថាគេកំពុងនិយាយលេងស៊កសៀតកំដរបរិយាកាស តែចិត្តគេមិនរាក់ដូចសម្ដីឡើយ។ យ៉ាងណាក៏រិទ្ធិគ្មានពេលកំដរគេលេងសើចដែរ នាយនិយាយបន្ថែមភ្លាម៖

«ធ្លាប់នៅជាមួយកូនប្រុសឧកញ៉ា ប៉ែន ពេជ្រ មែនឬមិនមែន មិនដឹងទេ! តែគេជាក្មួយរបស់លេខាប៉េងគឺដឹង!»

យុត្តនារភ្នែកសម្លឹងរិទ្ធិ គេហាក់ភ្ញាក់ផ្អើលដែរនឹងព័ត៌មានបន្ថែមនេះ តែគេនៅមិនចេញស្ដីព្រោះកំពុងវិលខ្វាល់ជុំវិញការរិះគិតនឹងរំលឹក សកម្មភាពទាំងឡាយរបស់នាងកាលពីមុននេះ។

«ខ្ញុំត្រូវគេធ្វើបាបតាំងពីតូចៗមក ទម្រាំបានប៉ុណ្ណេះ ទើបតែមានលោកម្នាក់ទេ ដែលម្ដងជាពីរដងល្អចំពោះខ្ញុំ!»

សំឡេងរិទ្ធិលាន់មកតិចៗផ្ដាច់អារម្មណ៍បាចសាចរបស់យុត្តនា៖

«ស្រីម្នាក់នេះចង់លេងល្បែងអី? ស្គាល់ទាំង ប៉ែន ពេជ្រប្រាថ្នា ស្គាល់ទាំងលេខាប៉េង?»

អ្នកប្រុសទីមួយនៅតែរក្សាភាពវាហីរបស់ខ្លួន៖

«អញ្ចឹងបានល្អ សុទ្ធតែមនុស្សស្គាល់គ្នា!»

រិទ្ធិលែងរវល់នឹងចរិតឌឺដងរបស់យុត្តនា គេចាប់ចូលដល់សាច់រឿងសំខាន់តែម្ដង៖

«លេខាប៉េងមួយរយៈនេះមានរឿងប្លែកៗច្រើន គាត់នៅពីក្រោយការដាក់ថ្នាក់រំញោចឲ្យឧកញ៉ាប៉ែន ពេជ្រ ហើយពេលខ្ញុំសួរគាត់ គាត់ថាធ្វើដើម្បីលោកប៉ា! ប៉ុន្តែលោកប៉ាមិនដឹងរឿងទេ នៅថ្ងៃដែលឯងទៅជួបឪពុកពៅបញ្ញា លោកប៉ាក៏មិនបានដឹង ហើយយប់នោះពេលខ្ញុំកំពុងនៅក្នុងមន្ទីរពេទ្យ លោកប៉ាបានទូរសព្ទមកសួរនាំ ព្រោះលោកមិនបានដឹងរឿងអ្វីទាំងអស់! ពូប៉េងអត្តនោម័តិធ្វើរឿងនេះដោយខ្លួនឯង តែពេលខ្ញុំសួរគាត់ គាត់មិនសារភាពអំពីគោលដៅពិតប្រាកដរបស់គាត់ទេ!»

យុត្តនាឆ្លើយធ្វើហី៖

«វាត្រូវតែអញ្ចឹងហើយ! តើអ្នកណាខំធ្វើរឿងយ៉ាងច្រើន ហើយមកសារភាពប្រាប់ឯងងាយៗ

នោះ!»
«ខ្ញុំអត់ខ្វល់ទេ! សំខាន់ខ្ញុំមិនឲ្យលោកប៉ាមានរឿងដោយមនុស្សបែបនេះដាច់ខាត! ម្នាក់នេះមានប្រវត្តិស្រពិចស្រពិលនៅក្បែរខ្លួនលោកប៉ាយូរឆ្នាំមក ហើយ លោកប៉ាទុកចិត្តគាត់ដូចបងប្អូនបង្កើត រឿងអីក៏និយាយប្រាប់គាត់ ប៉ុន្តែគាត់វិញធ្វើរឿងលាក់ជាច្រើន។ ខ្ញុំទៅជួបអ្នកស្រុករបស់គាត់នៅទំនប់រលកគាត់គ្មានប្រពន្ធកូនទេ ប៉ុន្តែឧស្សាហ៍ឡើងចុះទីនោះ មិនដឹងមានការអី នៅភ្នំពេញគាត់មានក្មួយស្រីចិញ្ចឹមម្នាក់ ថ្មីៗនេះនាងចាប់ផ្តើមបង្ហាញខ្លួននៅក្បែរអ្នកប្រុសទីមួយរបស់ ហួត ស៊ីវ សេណារីយ៉ូនេះប្រាកដជាមានក្បាលនិងកន្ទុយរបស់វា!»

យុត្តនាឆ្លើយវិញ ទៅនឹងការអធិប្បាយដ៏វែងរបស់រិទ្ធិ៖
«ងាយស្រួលបំផុត ឯងទៅជួប ប៉ែន ពេជ្រ ហើយសួរគាត់ទៅ ថាតាមពិតលេខាប៉េងជាអ្នកណា មកពីណា យើងអាចនឹងដឹងបំណងរបស់គាត់!»
រិទ្ធិចងចិញ្ចើមដោយចម្ងល់៖
«ហេតុអីលោកប៉ាយើងមិនសួរទៅសួរ ប៉ែន ពេជ្រ?»
«ឯងគិតថាឯងឆ្លាតណាស់ហើយ តែឯងបានវាយស្នោបង្អើលពស់រួចទៅហើយ បើលេខាប៉េងពិតជាមានល្បិច ពេលនេះគាត់ប្រាកដជាដឹងខ្លួន ឯងនៅឆ្ងាយពីលោកប៉ាដូច្នេះ លេខាប៉េងមានវិធីច្រើនទៀតត្រៀមជាស្រេចក្នុងការទប់ទល់នឹងឯងជា មុន ដូច្នេះយប់នេះនិយាយជាមួយលោកប៉ា ទាល់តែឯងមានភស្តុតាងឲ្យច្បាស់ដូចថ្ងៃ!»
«ចុះហេតុអីឯងដេញខ្ញុំឲ្យទៅសួរឧកញ៉ា ប៉ែន ពេជ្រ?»
«ព្រោះថាលេខាប៉េងស្គាល់លោកប៉ាយូរហើយ ទំនាក់ទំនងលេខាប៉េងនិងលោកប៉ា ក្រៅពីលោកប៉ាមានតែពួកម៉ាករបស់គាត់ប៉ុណ្ណោះទើបដឹង ហើយពួកម៉ាកគាត់គឺនៅសល់តែ ប៉ែន ពេជ្រ ម្នាក់គត់!»
រិទ្ធិងក់ក្បាលផ្ងក់ៗព្រោះសម្តីគេហាក់សមទំនងដែរ។
«តែគាត់នៅមិននិយាយរួចនៅឡើយ!»
យុត្តនារវើរក្អែកសញ្ជឹងគិត គេនិយាយដោយទឹកមុខនឹងនះ៖
«នឹងក៏ជាចំណោទបញ្ហាមួយ តើលេខាប៉េងចង់ឲ្យតានោះស្លាប់ដើម្បីអ្វី? គេដឹងហើយថាលោកប៉ាមិនចង់ឲ្យ ប៉ែន ពេជ្រ ស្លាប់ទេ នៅពេលដែលរកគម្រោងធុរកិច្ចរតនៈសោភ័ណមិនទាន់បាន?»

រិទ្ធិឆ្លើយតបវិញក្នុងទឹកមុខសញ្ជឹងគិត៖
«ខ្ញុំមើលឃើញរឿងពីរ បើប៉ូលិសចាប់បានគាត់អាចឆ្លើយដាក់លោកប៉ា តែបើអត់ទេ ប៉ែនពេជ្រ ត្រូវស្លាប់ ហើយឯងជាអ្នកទទួលខុសត្រូវ នៅក្នុងពេលជាមួយគ្នាក្មួយស្រីរបស់គាត់ស្រាប់តែបង្ហាញខ្លួនក្បែរឯង អញ្ចឹងឯងអាចជាគោលដៅសំខាន់សម្រាប់គាត់!»
«អញ្ចឹងឯងគិតថាគាត់ចង់លេងអ្វីជាមួយខ្ញុំ?»
រិទ្ធិឆ្លើយតបវិញភ្លាម៖
«ខ្ញុំដឹងរឿងគាត់ គាត់ប្រហែលជាចង់ចាត់ការខ្ញុំជាង ចំណែកឯងប្រហែលជាគាត់ឲ្យក្មួយស្រីគាត់ ពង្វាងឯងចេញពីរង្វល់បញ្ហានេះ ព្រោះគាត់ខ្លាចឯងនៅរាំងការងាររបស់គាត់!»
«អញ្ចឹងខ្ញុំដើរតួកំដរគាត់តែម្តងទៅ!»យុត្តនាឆ្លើយតបធ្វើហី។
រិទ្ធិដៀងភ្នែកសម្លឹងគេ។ ....អ្នកឃើញគេសើចបង្ហាញស្នាមស្នេហ៍នាចុងបបូរមាត់....អ្នកក៏នឹកឃើញ ភ្លាមដល់ ពៅបញ្ញា ធីតាស្រអែមស្រស់ដែលបុរសៗចង់បានមកនែបនិត្យជិតកាយ។ តែសម្រាប់អ្នកប្រុសទីពីរកាន់តែគិត នាយតែងតែយល់ថានាងនិងនាយនៅឆ្ងាយពីគ្នាដូចទន្សាយនិងដួងខែ។ ដែលសំខាន់គឺបើថ្ងៃណាមួយ នាងដឹងថាខ្លួនជាជនបង្កប់ កុំថាឡើយស្នេហាបើសូម្បីតែតំណែងជំនួយការជាទីគោរពស្រលាញ់ក្នុង បេះដូងនាងក៏ប្រហែលលែងសល់ដែរ។

គេធ្វើមុខស្រងូតឲ្យយុត្តនាចាប់ថ្នាក់បានដោយនិយាយទាំងលើកតេឡេចុចទូរទស្សន៍មើល៖
«មួយរយៈនេះឃើញឯងចេះពិបាកចិត្ត តាមពិតរឿងហ្នឹងទេ?»
រិទ្ធិព្រហើយដកអារម្មណ៍មកវិញទើបឆ្លើយបង្វែងដាន៖
«លោកប៉ាប្រហែលកំពុងមានគ្រោះថ្នាក់ បើសិនលេខាប៉េងពិតជានៅពីក្រោយរឿងអស់នេះមែន!»
យុត្តនាឆ្លើយវិញធ្វើហី៖
«គ្មានអីស្មុគទេ! ថាមិនបានស្រីស្អាតដែលគាត់ប្រើមកនោះ អាចត្រូវយើងប្រើវិញផង!»
រិទ្ធិយល់ពីអ្វីដែលយុត្តនានិយាយ។ ហោចណាស់គេក៏បានធូរចិត្តដែលមានបងប្អូនធម៌ម្នាក់អាចរំលែករឿង អស់នេះជាមួយគ្នាបាន។
គេចាកចេញទៅ បន្សល់នូវបុរសវ័យក្មេងដែលតែងតែនឹកដល់នារីម្នាក់។ គេស្អប់បរិយាកាសបែបនេះព្រោះវាជាការល្បងភាពអត់ធ្មត់របស់គេច្រើន យប់មកហើយ។ ចំណែកថ្ងៃនេះ មាន

រឿងច្រើនពេក គេមិនចង់អត់ធ្មត់តទៅទៀតឡើយ។ គេលើកទូរសព្ទចុចហើយបន្ទាប់មក និយាយតិចៗ៖

«សុខសប្បាយអត់?»

ស្ថានភាពរបស់ ពៅបញ្ញា និងឫកពាដែលនាងជួបគេចុងក្រោយពេលគេទៅបាយជាមួយស្រីម៉ូដែលល្បី ឈ្មោះមិនសមថានាងព្រមលើកទូរសព្ទរបស់គេក្នុងពេលនេះទេ ប៉ុន្តែនាងបែរជាលើក។ តើនាងនឹងប្រើសម្តីគ្រោតគ្រាតរបៀបណាតបនឹងការនឹករលឹករបស់នាយ ឬមួយក៏នាងមានអ្វីៗផ្សេងចង់និយាយ?

«មានការអី? ឆាប់និយាយទៅ! បើរឿងបងវណ្ណៈទៅវាយលោកមុននោះហី! ខ្ញុំអត់អីប្រកែកទេ គឺនៅរង់ចាំទទួលដីកាកោះហៅជានិច្ច!»

រឿងដែលគេសឹងថាភ្លេចបាត់ទៅហើយនាងបែរជារំលឹកមកវិញ។ ស្រីនេះចំជារឿងច្រើនហើយអស្មិមានះ។ គេឆ្លើយទាំងខាំមាត់ក្នាញ់៖

«គ្រោតគ្រាតម៉េះអ្ហះ?»

ពៅបញ្ញា ឆ្លើយតបវិញស្រួយស្រើប៖

«អាស្រ័យលើប្រភេទមនុស្សដែរ!»

អ្នកប្រុសផុសចិត្តមានះ៖

«ឡូយម្ល៉ឹងៗចង់ជួបគ្នាឥឡូវមែនអត់?»

«លោកយកអីមកគំរាមខ្ញុំយុត្តនា? ចរិតនៅតែមិនដូរ! កោតណាស់!»

យុត្តនាដឹងថានាងលែងភ័យលែងខ្លាច ព្រោះទោះយ៉ាងណាក៏ប៉ានាងត្រូវគេងពេទ្យ នាងស្មានថាគាត់គាំងបេះដូងព្រោះអាថ៌កំបាំងទាំងអស់ត្រូវនាយនិយាយ ចេញអស់ហើយ បានជានាងហ៊ានក្រអឺតអញ្ចឹង។ គេកាន់តែគិតកាន់តែក្នាញ់ ។

អ្នកប្រុសទីមួយ វាចាតបទាំងញញឹមស្ងួត៖

«អញ្ចឹងយើងភ្នាល់គ្នាទៅ! ថាខ្ញុំមានអី ដែលនាងមិនចង់ឲ្យគេដឹង?»

ស្ងាត់សូន្យ។

នាងមិននិយាយតែក៏មិនដាក់ទូរសព្ទ។ គេដឹងថានាងកំពុងរិះគិតសស្ទើតសស្លក់ហើយថាអ្វីទៀតទៅដែលគេអាច នឹងធ្វើចំពោះគ្រួសារនាង។

គេបានចិត្តនិយាយបន្ថែម៖

«បើប្រាំនាទីមិនគ្រប់! ខ្ញុំទុកពេលឲ្យនាង ១០ នាទីមេធាវី! ខ្ញុំទៅចាំនាងនៅមុខផ្ទះ»

«លោកឆ្កួតហើយ!»នាងឆ្លើយដោយស្លន់ស្លោ។

ទោះនាងប្រឹងរឹងមាំតែអ្នកដឹងថានាងកំពុងភ័យ។ គេសើចតិចៗហើយបន្តធ្វើហី៖

«ព្រោះឆ្កួតហ្នឹងហើយ ដែលនាងត្រូវប្រយ័ត្ន មកមិនទាន់ពេល ខ្ញុំអាចឆ្កួតជាងនេះ!»

នាងនៅស្ងៀម គេកាន់តែអាណិតនាង។ យុត្តនាដឹងថានាងកំពុងពិបាកចិត្ត តែគេចេះតែចង់ធ្វើបាបនាង។

«អូខេ! បន្តិចទៀតជួបគ្នា!»

គេបម្រុងចុចបិទទាំងស្នាមញញឹមស្រស់បង្គួតរាត្រីកាល ប៉ុន្តែសំឡេងនាងហៅមកភ្លាម៖

«យុត្តនា!»

គេមិនដាច់ចិត្ត ទោះបីនៅជំអក់មិនឆ្លើយ តែទីបំផុតគេនៅតែឆ្លើយ៖

«យ៉ាងម៉េច?»

«ម៉ោង១២ហើយ! ខ្ញុំចេញមិនបានទេ ដឹងអត់?»

«ព្រោះដឹងហ្នឹងហើយបានជាខ្ញុំចង់ឲ្យនាងចេញ!»

«កុំធ្វើអញ្ចឹង!»សំឡេងនាងលែងកាចហើយ នាយដឹងច្បាស់តែនាយនៅតែចង់បញ្ឈឺ៖

«ខ្ញុំអត់ធ្វើអីទេគ្រាន់តែចង់ឃើញមុខមនុស្សគ្រោតគ្រាត! ថាមុខហ្នឹងអាក្រក់អាម៉េចបានជាសម្តីអាក្រក់ម៉េះ?»

នាងមិនខ្លាចគេទេ ព្រោះចរិតកំសាកមិនមែនជារបស់ ពៅបញ្ញា ឡើយ។ តែនាងខ្លាចរឿងមួយបំផុតក្នុងជីវិតគឺការត្រូវបាត់បង់កិត្តិយស។ នាងត្រូវគេធ្វើបាបប៉ុន្មានដងហើយ ប៉ុន្តែគឺមិនមានមនុស្សម្នាដឹងឡើយ បើម្តងនេះគេមកនៅពីមុខផ្ទះធំមែន ស្រីប្រុសក្មេងចាស់ជាបរិវារក្នុងផ្ទះច្បាស់ជាដឹងឮគ្រប់គ្នា។ រឿងនេះហើយដែលនាងខ្លាចយុត្តនាព្រោះនាងដឹងថា គេនិយាយផុយហើយធ្វើក៏ផុយដូចគ្នា។

«លោកជានាយកធនាគារហើយ លោកមានសង្សារជាតារាទៀត លោកកុំធ្វើខូចកិត្តិយសខ្លួនឯង!»

នាងនិយាយតាពាសព្រោះភ័យ តែយុត្តនាបែរជាសប្បាយចិត្ត។

«មានគេប្រចណ្ឌខ្ញុំមិនមែនហ្នឹង?»

ទម្លាប់គិតយ៉ាងណានិយាយប្រាវជាចរិតរបស់គេ នាងដឹងហើយតែយ៉ាងណាក៏ដោយនាងនៅ

តែ ហួសចិត្ត។
ពៅបញ្ញានិយាយ៖
«លោកទុកពេលនេះគេងស្រមៃ លើកខ្លួនឯងដាក់លើចង្អេរទៅ!»
យុត្តនាដឹងថានាងពិតជាប្រចណ្ឌគេដែលនិយាយពាក្យអស់នេះ គេសប្បាយចិត្ត តែនៅមានះធ្វើបាបនាង៖
«អត់ទេ នៅលើចង្អេរពីរនាក់សប្បាយជាង! ខ្ញុំពាក់អាវហើយ! ពីរនាទីទៀតជិះដល់មុខផ្ទះអ្នកនាងធំល្មម!»
ពៅបញ្ញាប្រហែលជាដឹងថា នាងមានតែប្រើវិធីដដែលទើប នាងបន្ទន់សំឡេងស្លូតបូត និយាយសួរវិញខ្សាវៗ៖
«ហេតុអ្វីក៏លោកចូលចិត្តធ្វើបាបខ្ញុំ!?»
«ស្រលាញ់!»

គេឆ្លើយផ្ទួងរកតែពេលស្រីតូចដកដង្ហើមសឹងមិនទាន់។ គេនិយាយអ្វីៗផុយៗណាស់ឃ្លានេះប្រាកដណាស់ គឺគេនិយាយបញ្ឆោះនាងប៉ុណ្ណោះ នាងដឹង ប៉ុន្តែម៉េចក៏ទៅជាមានអារម្មណ៍ថារំភើបហើយបេះដូងចាប់លោត?
«ចង់ថើបគ្នាទៀត! មិនបាន?»
នាងនៅស្ងៀមឈឹង ទោះគេបន្ថែមឃ្លាទីពីរមកទៀតក៏ដោយ។ ស្រីស្អាតគ្មានពាក្យនិយាយបន្សល់ទុកភាពស្ងប់ស្ងាត់ក្នុងប្រអប់ បញ្ជូនសំឡេង។ តែនរៈទទួលអារម្មណ៍ថាអ្នកអាចដឹងពីសង្វាក់ដង្ហើមសិចស៊ីរបស់ នាង។
គេញញឹមម្នាក់ឯងហើយចាប់បន្លឺបន្ថែម៖
«ម៉េច? សួរអស់ឬនៅមេធាវី! ចុងក្រោយនាងចាញ់ លើសវនាការហើយ! ទោះនាងសួរយូរប៉ុណ្ណាក៏ដោយ! មិនបាច់បន្លាយពេលទេ!»
«គ្មានអ្នកណាធ្វើអញ្ចឹងដាក់មនុស្សដែលគេស្រលាញ់ទេ!»
នាងស្រាប់តែឆ្លើយមកវិញស្រាលៗហើយទន់ភ្លន់រហូតដល់បេះដូងខាងប្រុសទន់ល្មៃសឹងរបូតទូរសព្ទពីដៃវិញម្ដង។
ចិត្តចាប់ផ្ដើមស្រយង់ ហើយភ្នែកគេក៏មមី៖
«ពីរោះម៉េះ? សំឡេងអ្នកណាគេហ្នឹង? បាត់ស្រីឆ្នាសទៅណាហើយ?»

នាងបិទទូរសព្ទភឹង សឹងថាមិនចង់ឮពាក្យតបរបស់អ្នក តែយុត្តនារលាយអស់ហើយចិត្តចង់ឈ្នះព្រោះគេកំពុងទទួលអារម្មណ៍ដូច នៅកណ្ដាលសួនផ្កាក្រអូបប្រហើរ។ ស្រីម្នាក់នេះនិយាយដូចចង់ប្រាប់នាយថានាងក៏មានចិត្តខឹងដែលនាយ បណ្ដើរស្រីផ្សេងមែន។

នាងបិទទូរសព្ទព្រោះអៀននឹងសម្ដីខ្លួនឯង? ឬនាងលេងល្បិចដាក់អ្នកប្រុសទីមួយចិត្តទន់ឈប់ធ្វើបាបនាងប៉ុណ្ណឹង???។
ទោះអ្វីក៏ដោយ គេមិនខ្វល់ ព្រោះគេកំពុងសប្បាយចិត្តពេកទៅហើយ។
អ្នកប្រុសវេភ្នែកគិតហើយរំលឹកច្រំដែលៗភាសារបស់នាង «លោកមើលខ្លួនឯងទៅ សមនឹងស្ដាប់ ពាក្យពីរោះៗដែរអត់? ហើយបើចង់ស្ដាប់ណាស់ Callទៅបុស្បានារីរបស់លោកទៅ!» នាងដូចជាប្រចណ្ឌ ហើយប្រការនេះធ្វើឲ្យគេចាប់ងាកទៅគិតពីនារីម្នាក់ទៀតនោះមែន។ គេក្រោកទៅរកកុំព្យូទ័រ យួរវាមកដាក់លើភ្លៅហើយចាប់ផ្ដើមចុចរាវរកអ្នកណាម្នាក់។
រូបរាងនារីម៉ូដែលដ៏សិចស៊ី បុស្បានារីសាត់ពេញអេក្រង់។ មួយសន្ទឹកណាក៏មើលទៅមិនចង់ដកភ្នែកមកវិញដែរ។ អ្នកប្រុសទីមួយជ្រួញចិញ្ចើមរិះគិត។ សម្ដីរិទ្ធិលាន់មកវិញក្នុងអារម្មណ៍គេ៖
«ខ្ញុំទៅជួបអ្នកស្រុករបស់គាត់នៅទំនប់រលកគាត់គ្មានប្រពន្ធកូន ទេ ប៉ុន្តែឧស្សាហ៍ឡើងចុះទីនោះ មិនដឹងមានការអី នៅភ្នំពេញគាត់មានក្មួយស្រីចិញ្ចឹមម្នាក់ ថ្មីៗនេះនាងចាប់ផ្ដើមបង្ហាញខ្លួននៅក្បែរអ្នកប្រុសទីមួយរបស់ ហួត ស៊ីវ សេណារីយ៉ូនេះប្រាកដជាមានក្បាលនិងកន្ទុយរបស់វា! ឯងមិនចេះគិតមើលខ្លះទេ គេតារាល្បីម៉្លឹងៗដើរខូចឡានអត់សូហ្វ័រ ហើយមកខូចចំផ្លូវឯងជិះកាត់រាល់ថ្ងៃទៀត ហើយគេជិះឡានចាស់បែបនេះឯងជឿដែរ? មួយអាទិត្យមុនទើបតែរើមកនៅក្បែរ Apartment ឯងទៀត? គេធ្វើរឿងច្រើនយ៉ាងនេះ ចៃដន្យល្អមែនណេះ?»
យុត្តនាសម្លឹងទៅស្នាមញញឹមស្រស់ស្រទន់របស់តារាស្រី ដែលពៅបញ្ញាគ្មានឡើយឱកាសសូម្បីតែផ្ទឹមនឹងនាងត្រឹមផ្ទៃមុខ កុំថាឡើយដល់កម្ពស់កំពនិងសម្បុរស្បែក។
គេនិយាយខ្សឹបៗ៖
«នាងចង់បានអីបុស្បា? ម្នាក់ៗគិតថាខ្ញុំសាច់ជ្រូកបីជាន់អ្ហេះ?»

## ២២

អាថ៌កំបាំងស្រីស្អាត

ម៉ោង១១យប់សាជាថ្មី។
នេះជាពេលវេលាដែលមនុស្សម្នាស្វែងរកដំណេករៀងខ្លួន លើកលែងតែតារាស្រីដែលមានកាលវិភាគការងារញឹកស្អេកដូចជាបុស្បា នារី។
«បងអេនឌី! ខ្ញុំទៅលែងរួចហើយ បើថានេះចាំស្អែកខ្ញុំមកថតជួសទៀត»
«កុំអីសុំអង្វរបុស្បា ជួយមួយម៉ោងពីរម៉ោងទៀតបង្ហើយទៅ! ដឹងស្រាប់ហើយថារឿងមនុស្សមកជុំគ្នាវិញមិនងាយទេ!»
«តែបងក៏គួរគិតពីខ្ញុំខ្លះដែរ ខ្ញុំអស់ដៃអស់ជើងមែនណ៎ាបង ខ្ញុំថតទៀតក៏អត់កើតដែរ! បងចង់ឲ្យរូបចេញមកមុខខ្មូរអត់?»
ថាហើយតារាស្រីវ័យក្មេងឈោងដៃទាញយកកាបូបដៃរបស់នាងស្ពាយលើស្មា រួចចាកចេញដោយមិនរវល់ងាកក្រោយ។

ក្នុងបេះដូងនាងគឺលែងមានពេលផ្ដោតលើការងារស្ទូឌីយោនេះដូចមុន ទៀតហើយ។ ស្នាមញញឹមរបស់នាយកធនាគារវ័យក្មេងនៅជិតដាមមកជាប់ជានិច្ចគ្រប់ ដង្ហើមចេញចូល។ ការដែលជំរុញចិត្តនាងឲ្យកាន់តែទទូចចង់បានបុរសនោះ ក៏ដោយសារថាគេកាន់តែរឹងរូសកាន់តែនឹងន កាន់តែព្រងើយកន្តើយចំពោះសម្រស់របស់នាង នាងរឹតតែមានះចង់ឈ្នះចិត្តគេ។ ស្បែកជើងកែងតូចស្រួចលាន់ស្នូរតិចៗលើកម្រាលថ្មល់កំដររាត្រីកាល ស្ងាត់ជ្រងំ។
«ប្រុសចិត្តថ្ម ប្រុសគល់ឈើ និយាយទូរសព្ទមួយភ្លែតក៏អត់ ទុកមុខឲ្យបន្តិចក៏អត់ មេធាវីខ្មៅក្អិតរបស់លោកអស្ចារ្យប៉ុណ្ណាទៅ ទាបក៏ទាបល្អិតក៏ល្អិតមុខគ្មានរសជាតិកោតណាស់លោកចោលសាច់ស្រវ៉ា ឆ្អឹង!»
នាងរអ៊ូរង៉ូវៗម្នាក់ឯងដោយលើកដៃចុចបញ្ជារថយន្តពីចម្ងាយផង ដើរជិតដល់ឡានស្រាប់តែហ្វាឡានមួយផ្សេងទៀតស៊ីញ៉ូមកលើនាង ធ្វើឲ្យបុស្បាលើកដៃរងទាំងសៅហ្មងក្នុងចិត្ត។
«ចុះពីណាគេនឹងមិនដែលមានឡានជិះទេហ្អី?»
កំដរទឹកមុខសៅហ្មងរបស់ស្រីស្អាតម្ចាស់ឡានដ៏ព្រហើននោះ ហ៊ានចុះមកដោយរុញទ្វាបិទទៅវិញគគ្រាំង។ បុស្បាមិនមែនស្រទ្បាំងកាំងដោយសារកាយវិការនោះទេ ប៉ុន្តែនាងភាន់ភាំងព្រោះនៅចំពោះមុខ កណ្ដាលរាត្រីស្ងាត់បែបនេះ ទេសាភិបាលវ័យក្មេងដែលបេះដូងនាងនឹកគេទាំងយប់ទាំងថ្ងៃ ស្រាប់តែបង្ហាញខ្លួន។
«ឲ្យខ្ញុំធ្វើសូហ្វ័រអត់?»

ប្រុសស្រីទាំងទ្វេបានក្លាយជាលលកញីឈ្មោលកំដរភាពត្រជាក់ ល្ហឹមនៃរាត្រីកាលរបស់រាជធានីភ្នំពេញ។ នរៈស្រស់សង្ហាក្លាយជាទេវបុត្រដែលបង្ហាញកាយនៅក្បែរនាងដូច វេទមន្តធ្វើឲ្យស្រីស្អាតយល់ថានាងសំណាងណាស់ក្នុងការមានរូប សម្រស់ល្អឯក អាចធ្វើឲ្យបុរសៗរួមទាំងនាយកធនាគារវ័យក្មេងវង្វេងចិត្តសូម្បីតែ ទើបជួបគ្នាបានប៉ុន្មានដង។
ដៃគេកាន់ចង្កូតបណ្ដើរយុត្តនានិយាយបណ្ដើរៈ
«ទៅណា?»
សម្ដីគេចាប់ផ្ដើមកំបុតហើយមិនសួរគួរសមដូចកាលពីលើកមុនៗ តែបុស្បាយល់ថានាងកាន់តែពេញចិត្ត ព្រោះនេះបង្ហាញថា នាងនឹងគេកាន់តែជិតដិត ។
«ទៅផ្ទះ! គឺអស់កម្លាំងមែនទែនហើយ!»
នាងឆ្លើយតម្អូញតិចៗល្មមឲ្យបុរសៗបាក់ចិត្តនឹងសូរសព្ទស្រទន់ ពីរោះរបស់នាងបាន។ យុត្តនាញញឹម គេមិនងាកមុខមកមើលស្រីស្អាតទេតែអាកប្បកិរិយានាយបង្ហាញថានាយពេញចិត្តនឹងធ្វើការនេះផ្ដាប់នាង។

គេឈប់ឡានហើយជូននាងដល់បន្ទប់ដូចកាលពីយប់មុន តែគេនៅត្រេងត្រាងមាត់ទ្វារមិនចូលទៅខាងក្នុងទេ។ ក្រសៃភ្នែកនារីឯកា សម្លឹងមកអ្នកប្រុសយ៉ាងស្រទន់ មិនដឹងថានាងមានចេតនាបង្ហាញពីចិត្តស្នេហាចំពោះនាយឬមួយនាងជា ស្រីពោរពេញទៅដោយមនោសញ្ចេតនាទន់ភ្លន់បែបនេះជាទូទៅនោះឡើយ។ គេឃើញភ្នែកនាងហើយចាំបាច់ត្រូវតែសម្លឹងតបមកវិញដោយស្រទន់ដូច គ្នា។បានឱកាសបុស្បានិយាយស្រាលៗៈ
«អរគុណណាស់!»
យុត្តនាញញឹមៈ
«ឈប់និយាយពាក្យហ្នឹងទៅបុស្បា!»
«ខ្ញុំនៅតែនិយាយ ព្រោះលោកល្អនឹងខ្ញុំ! ខ្ញុំចងចាំលោកជានិច្ច ព្រោះលោកការពារខ្ញុំ ពេលខ្ញុំមានបញ្ហាលោកក៏បង្ហាញខ្លួន ហើយមិនដែលគិតចង់បានអ្វីពីខ្ញុំ ខុសពីមនុស្សប្រុសផ្សេងៗដែលខ្ញុំធ្លាប់ជួប!»
យុត្តនាចាប់មានអារម្មណ៍ថាអាណិតនាង។ គេសម្លឹងកែវភ្នែកនាងទាំងសងខាងដែលគ្មានទំនងសោះថា នាងកំពុងសម្ដែងកុនល្ខោនឡើយ។ «ឬមួយសូម្បីតែលេខាប៉េងប្រើប្រាស់នាងក៏នាងធ្វើដោយបង្ខំចិត្ត ដែរ?»គេគិតផងសម្លឹងភ្នែកនាងមិនដកផង។ មិនដឹងហេតុអ្វីស្រីស្អាត

នេះ មានចរិតលក្ខណៈខុសពី ពៅបញ្ញា ដាច់ភឹង។ នាងទន់ណាស់តែពេលប៉ះភ្នែកនាយ នាងមិនងាយដកវាចេញទៅវិញទេ។ គឺទុកឲ្យខ្សែភ្នែកដ៏អាថ៌កំបាំងប៉ះគ្នាដោយសេរី។ នាងមានចេតនាឬនាងមិនបានដឹងមែនថា ខ្សែភ្នែកនាងកំពុងបន្ទន់ចិត្តបុរសម្នាក់ យ៉ាងមានប្រសិទ្ធភាពហើយគេកំពុងប្រៀបធៀបនាងកាន់តែច្រើនឡើងៗទៅនឹង នារីដែលស្ថិតនៅក្នុងបេះដូងគេ។

«ខ្ញុំមិនល្អពេក ដូចនាងកំពុងឃើញទេបុស្បា!»

គេនិយាយតិចៗព្រោះមិនចង់និយាយវាចេញតែក៏មិនចង់ឲ្យនាងខូចចិត្ត។

បុប្ផាកាន់តែទន់ គេកាន់តែខ្លាចថាខ្លួន ជាអ្នកធ្វើឲ្យនាងខ្ទេចខ្ទាំទើប គេនិយាយពាក្យនោះចេញដោយមិនដឹងខ្លួនទេ។

តែបុស្បាតបវិញមួយៗ៖

«តែខ្ញុំទុកចិត្តលោកយុត្តនា! អ្វីម្យ៉ាងធ្វើឲ្យខ្ញុំទុកចិត្តលោក !ខ្ញុំដឹងថាទោះលោកនៅទីនេះរហូតដល់ព្រឹកទៀត ក៏លោកមិនធ្វើអ្វីខ្ញុំដែរ!»

យុត្តនា រេភ្នែកទៅរករាងកាយរបស់នាង ជាក្រសែភ្នែកដែលបុរសគ្រប់គ្នាមិនអាចលាក់វាបានទេនៅពេលគេប្រឈម នឹងស្រីស្អាតបំផុតក្នុងពេលស្ងាត់បំផុត ហើយនាងកំពុងពោលពាក្យល្អៗបំផុតមកឆាបយកបេះដូងគេ។

គេពោលបន្លប់៖

«កុំទុកចិត្តខ្ញុំពេក!»

«អត់ទេ! តែខ្ញុំទុកចិត្តភ្នែករបស់ខ្ញុំ!»

នាងឆ្លើយតបដោយសម្លឹងមុខនាយមិនព្រិច។ ខ្សែភ្នែកនាងស្រទន់ហួស ដែលពិបាកឲ្យបុរសៗមិន ស្រយុតស្រយង់ក្នុងចិត្តបាន។ នាងនិយាយបន្ថែម៖

«លោកអាចមកទីនេះបានគ្រប់ពេល! ទោះបីទុកទីនេះជាកន្លែងរបស់លោកក៏ដោយ!»

នាងនិយាយបន្ថែម។

យុត្តនា យល់ថាវាលឿនពេកហើយក្នុងការដែលនាងនិយាយពាក្យអស់នេះចេញមក។ ន័យរបស់នាងទោះវាបញ្ជិតបញ្ជៀងតែចុងក្រោយវានៅតែច្បាស់ៗ មិនខុសអ្វីពីការសារភាពស្នេហ៍របស់ស្រីម្នាក់មកឲ្យបុរសម្នាក់ ដោយត្រង់ៗគ្មានលាក់លៀមនោះឡើយ ។ គេឈ្ងោកមុខគេចចេញពីភ្នែកនាង។

ដោយរក្សាភាពជាសុភាពបុរសលើផ្ទៃមុខ គេសួរវិញស្រាលៗ៖
«ហេតុអ្វីល្អនឹងខ្ញុំម្ល៉េះបុស្បា?»
សំណួរនេះគឺហាក់ចង់ជំនួសឲ្យឃ្លាថា«ហេតុអ្វីនាងមកស្រលាញ់មនុស្សដូចខ្ញុំ?»គ្រាន់តែយុត្តនានិយាយចេញមកមិនរួច។
នាងនៅទ្រឹងចំពោះសំណួរនេះ។ នាងរវេភ្នែកទៅទីផ្សេងដែលក្នុងពេលសំណួរជាច្រើនលេចចេញមកក្នុង បេះដូងខ្លួនឯង។«ឯងធ្វើដើម្បីពូឯង ឬឯងពិតជាពេញចិត្តបុគ្គលិកលក្ខណៈរបស់គេ? ឯងពេញចិត្តគេ ព្រោះគេជាអ្នកមានយសស័ក្តិឬឯងពេញចិត្តភាពជាសុភាពបុរសរបស់គេ បុស្បា?»
នាងនៅទីទើរក្នុងបរិយាកាសស្ងាត់ស្ងៀម។
យុត្តនា ក៏មិនចង់ឲ្យនាងទញ់ទាល់ដោយសារសំណួរនេះដែរ។ គេញញឹមប្តូរបរិយាកាសហើយនិយាយបន្ថែម៖
«សម្រាកទៅ! យប់ជ្រៅហើយ! Good Night!»

គេញញឹមម្តងទៀតហើយបែរខ្នងចាកចេញទៅ។ ស្រីស្អាតនៅឈ្ងោកសម្លឹងឥដ្ឋព្រោះលង់នឹងសំណួរគេនៅឡើយ។ នាងនៅទីទើរចំពោះអ្វីម្យ៉ាងដែលនៅស្ទះត្រឹមបំពង់កស្ទើមិនចេញនិយាយមិនរួច ប៉ុន្តែនាងពិតជាមិនចង់រង់ចាំដល់ជណ្តើរយន្តលេបត្របាក់រូបគេទៅ បាត់សល់តែនាងឯកោម្នាក់ឯងទើបព្រមនិយាយវានោះទេ។ នារីម៉ូដែលឆ្លើយតិចៗស្រាលៗពីក្រោយខ្នងបុរសដែលកំពុងបោះជំហាន ចេញទៅ៖
«ព្រោះបងជាមនុស្សល្អ! »
យុត្តនា បញ្ឈប់ដៃដែលប្រុងថាចុចបើកជណ្តើរ។
ឃ្លារបស់នាងសាមញ្ញសោះតែហេតុអ្វីគេមានអារម្មណ៍ថារំភើបម្ល៉េះ?។ គេសួរនាងថា ហេតុអ្វីល្អនឹងគេ ចំណែកនាងឆ្លើយវិញថា ព្រោះគេជាមនុស្សល្អ ហើយពាក្យ«បង»នេះ វាអត់សាមញ្ញទេសម្រាប់មនុស្សទើបស្គាល់គ្នា។ ជាពិសេសគឺនាងជាស្រីស្អាតទៀត។
គេបែរក្រោយយឺតៗសម្លឹងស្រីម្នាក់ដែលជួបពេលណានាងតែងតែនាំមកនូវភាពធូរស្រាលនិងឲ្យកិត្តិយសឲ្យតម្លៃនាយ។
«មនុស្ស កុហក! មនុស្ស កម្រោល! អ្នកលេងកាប់ចាក់! មនុស្សមិនគោរពសម្តី! ខ្ញុំខ្ពើមលោក!»

ពាក្យប្រមាថកាតទានអស់នេះ គេស្តាប់ឆ្អែតហើយរាល់ពេលនៅជិតស្រីដែលគេស្រលាញ់ ហើយនឹកនាងពេញបេះដូង។
នាងប្រហែលរៀនបានខ្ពស់បង្ហិនតែលុយ ព្រោះនាងមិនដឹងទេថា វាគួរឲ្យតូចចិត្តប៉ុណ្ណានៅពេលដែលស្រីម្នាក់ថាឲ្យប្រុសម្នាក់ នូវភាសាអស់នេះក្នុងពេលស្រីផ្សេងៗគេតែងតែរើសយកពាក្យល្អៗជា ច្រើនសម្រាប់មនុស្សដែលនាងស្រលាញ់។
យុត្តនា ឃើញកែវភ្នែកបុស្បាដែលសម្លឹងមកនាយបញ្ជាក់ជាស្រេចនូវភាសាត្រូវការគេ សេចក្តីស្រលាញ់គេនិងកោតស្ញប់ស្ញែងគេ។
ទោះបីក្នុងបេះដូងអ្នក គ្មាននាង សូម្បី១%ធៀបជាមួយមេធាវីដ៏កាចឆ្នាស បន្ថែមពីនោះរិទ្ធិទើបតែរំលឹកប្រាប់អ្នកថាលេខាប៉េងនៅពីក្រោយ ការបង្ហាញខ្លួនរបស់បុស្បា ប៉ុន្តែការគោរពរបស់នាងនៅតែធ្វើឲ្យអ្នកទន់ចិត្ត ហើយចង់ធ្វើអ្វីៗតបស្នងឲ្យនាងបានសប្បាយចិត្តវិញ។
គេមិនចង់និយាយពាក្យដដែលៗ ប្រាប់នាងថាគេមិនមែនល្អដូចនាងគិតទេ ទោះបីគេប្រុងថានិយាយវាទៀតក្តី។
គេពោលពីអ្វីមួយផ្សេង៖
«ស្អែកទំនេរអត់?»

បបូរមាត់ញ័រតិចៗរបស់នាង ដែលកាត់កែរខ្មាស បង្ហាញមនោសញ្ចេតនាដាក់មនុស្សប្រុសកណ្តាលយប់ស្ងាត់ស្ងួន្យនេះ ចាប់បង្ហើបស្នាមញញឹម ព្រោះសំណួររបស់គេគឺជាចម្លើយស្រេចហើយថា គេព្រមទទួលនាងជាសង្សារ ជាមនុស្សសំខាន់លើសពីអ្វីដែលកំពុងមាន។ នាងងក់ក្បាលតិចៗ។
បុស្បាមិននិយាយ តែវាជាចម្លើយស្រេចថា ដើម្បីគេ ពេលណាក៏បាន ពេលណាក៏នាងទំនេរ។
យុត្តនា ព្រិចភ្នែកដែលពេញដោយមនោសញ្ចេតនាស្រទន់ ។ គេមិននិយាយវិញដូចគ្នាតែគេញញឹម។ ដៃម្ខាងលើកនាឡិកាបង្ហាញនាង ហើយបន្ទាប់មកលើកម្រាម៩បង្ហាញនាងដោយលើកចិញ្ចើមជាសញ្ញាសួរថា អូខេ?

ស្រីស្អាតងក់ក្បាលសាជាថ្មីទាំងទឹកមុខស្មើរយំស្មើរសើច។ នរៈញញឹមហើយបែរខ្នងចូលទៅក្នុងជណ្តើរ។ គេប្រញាប់ចេញព្រោះគេមិនចង់ឃើញនាងរំភើបជាងនេះមិនអញ្ចឹង ថាមិនបានគេអាចឈានដល់ដំណាក់កាលទប់ចិត្តលែងបានហើយចំណាយរាត្រី នេះនៅកន្លែងរបស់នា

ង។
បុស្បារង់ចាំគេចាកចេញផុតទើបនាងដើរយឺតៗចូលទៅក្នុងផ្ទះ។
នាងធូរស្រាលចិត្ត...ដំណើរសង្ខាស្វាហាប់ជាងមុនព្រោះកំពុងទទួល អារម្មណ៍ថាជ័យជម្នះត្រូវបានដណ្ដើមមកហើយក្ដាប់ពេញក្នុងដៃ។ កាលពីមិនទាន់បាន គឺប្រាប់ខ្លួនឯងថាស្រលាញ់គេតែដល់ពេលគ្រប់យ៉ាងបានដល់ដៃបែរជា មានអារម្មណ៍ថាស្រលាញ់ខ្លួនឯងទ្វេឡើង។
នាងប្រាប់ខ្លួនឯងស្ងាត់ទាំងសម្លឹងរាងកាយខ្លួនឯងក្នុងផ្ទាំងកញ្ចក់ដែលធំច្រងាងអែបក្បែរទ្វារ៖
«បុស្បានារីៗឯងស្អាតថ្នាក់នេះ ទន់យ៉ាងនេះមានអ្នកណាគេចឯងរួចនោះ?»
ស្នូរទូរសព្ទរោទ៍មកពុះជ្រែករាត្រីកាលស្ងាត់សូន្យសុង កន្ត្រាក់ទាំងបេះដូងភ្លើតភ្លើនរបស់នារីអ្នកសិល្បៈ។
«លឿនយ៉ាងនេះអ្វី? បែកគ្នាមិនទាន់បានមួយដង្ហើមផង គេខលមក?»
នាងគិតដោយអារម្មណ៍សោមនស្សហើយលូករកទូរសព្ទពីក្នុងកាបូបដៃជា ប្រញាប់។ ដឹងអីឃើញអេក្រង់កាលណាមិនត្រឹមតែស្រងាកចិត្តទេ តែថែមទាំងស្លេកមុខ ។
នាងរអ៊ូតិចៗដោយភ្ញាក់ផ្អើល៖
«ប្រាថ្នា?»

ស្រីស្អាតរារែក មុនពេលដាច់ចិត្តលើកព្រោះថាទោះពេលនេះអត់ចង់លើកតែនាងក៏គេចមិនបានទេ។ គេជាម្ចាស់សាជីវកម្មតម្លៃរាប់លានដែលជាគោលដៅនៃស្រីៗតារាភាគ ច្រើន។ មិនតែប៉ុណ្ណោះគេជាកូនប្រុសច្បងរបស់ ឧកញ៉ា ប៉ែន ពេជ្រ ដ៏ល្បីឈ្មោះនោះផង។ សំខាន់គឺគេនឹងនាងធ្លាប់មានរឿងស្ងាត់កំបាំងមកជាមួយគ្នា វាស្ងាត់និងអាថ៌កំបាំងដល់ថ្នាក់ថា សូម្បីតែពូនាងក៏មិនដឹងដែរ។
«បង?»នាងឆ្លើយទូរសព្ទគេតិចៗ។
«សុខសប្បាយអត់បុស្បា?»
ប៉ែន ពេជ្រប្រាថ្នា និយាយមួយៗតាមស្ទីលបុរសដែលមិនចេះខ្វះស្នេហ៍។
មិនដឹងខ្យល់អី បានជាយប់ជ្រៅយ៉ាងនេះបក់គេឲ្យនឹកដល់នាងហើយខលមកទេ។
បុស្បាខាំមាត់និយាយតបវិញដោយទឹកមុខស្មើៈ

«ល្អហើយដែលមានអ្នកខ្លះនៅចាំលេខទូរសព្ទខ្ញុំ!»
ដឹងថានាងអន់ចិត្ត ដែលបានដាច់ការទាក់ទងគ្នាជាយូរមកហើយ ព្រោះតែភាគីខាងបុរសអស់ចិត្តរំភើបនឹងស្រីស្អាតដោយរវល់រវើរវាំ ជាមួយ ស្រីស្អាតផ្សេងជាច្រើនទៀត។ គេពោលតិចៗលួងនាង៖
«ធ្វើកុំងមើល៍? នៅឯណានៀក!? កំពុងនឹកផង!»
នាងធ្វើភ្នែកក្រឡឹបក្រឡាប់។ ក្នុងពេលដែកំពុងចាប់បុរសថ្មីគ្មានស្រីណាម្នាក់មានអារម្មណ៍ចង់ ជួបសង្សារចាស់នោះឡើយ។ មធ្យោបាយបន្ទាន់គឺគេចសិនដើម្បីរកយុទ្ធសាស្ត្រលាងជម្រះ។ នាងតបវិញភ្លាម៖
«អូនជាប់ថត! នៅខេត្តនៅឡើយ! ចាំទៅដល់ភ្នំពេញវិញចាំគិតទៀត!»
«ថតនៅខេត្ត? ខេត្តណា? ថ្ងៃណាមកវិញ?»
«ប្រហែលបីបួនថ្ងៃទៀត!»
«បាន! ចាំជួបគ្នាម្តងមើល៍ ចង់មើលអូនឯង ធាត់ស្គមឥឡូវនៀក?»
ស្រីស្អាតក្តាប់មាត់តបវិញព្រោះឆ្អែតចិត្តនឹងចរិតព្រាននារីរបស់គេ៖
«ទៅវាស់ពួកតារាថ្មីៗក្មេងៗអស់ហ្នឹងទៅ!»
«អីគេ!?? រវល់រៀងខ្លួន ខានជួបគ្នាមួយរយៈចេះឌឺផង?»
«លោកច្រឡំហើយដែលគិតថាមនុស្សដូចលោកមានតម្លៃឲ្យខ្ញុំស្រលាញ់ ហើយរង់ចាំ!»នាងគិតក្នុងចិត្តទាំងសៅហ្មង។ ការរង់ចាំមនុស្សប្រុសខ្ពស់កប់ពពកម្នាក់ដែលមើលមកមនុស្សស្រីជា ទំនិញទិញដូរ បានធ្វើឲ្យស្នេហាដំបូងរបស់បុស្បានារីរុះរោយទៅក្នុងទន្លេចតុមុខ តាំងពីយូរណាស់មកហើយ ចាប់តាំងពីគេបានរាងកាយនាងហើយមិនដែលត្រលប់មកវិញសូម្បីតែសួរសុខទុក្ខ ឥឡូវនេះនៅស្ងាត់ៗនឹកឃើញខលមករកតើគេមានបំណងអ្វីក្រៅតែពី ម្តងម្កាលកម្រើកតណ្ហានឹកឃើញចង់លេងសើចនឹងនាងនោះ។

ស្រីស្រស់ប៉ប្រិមចិត្តកាន់តែខ្លាំង ពេលដែលប្រៀបប្រដូចគេទៅនឹងទេសាភិបាល ហួតយុត្តនា បុរសសង្ហាថ្មីក្នុងបេះដូងនាង។ស្គាល់គេមួយរយៈហើយតែដៃនាងក៏គេ មិនដែលប៉ះតើធុរកិច្ចជនល្អតែឈ្មោះ ប៉ែន ពេជ្រប្រាថ្នា ធ្វើម៉េចអាចឲ្យនាងចងចាំក្នុងបេះដូងទៀតដែរ? នាងនិយាយធ្វើជាស្ងាប៖
«ប៉ុណ្ណឹងចុះបង! ខ្ញុំអានរឿងបន្តសិនស្អែកត្រូវថតពីព្រលឹមងងឹត!»

«បាន! មកភ្នំពេញពេលណាទាក់ទងមកបងភ្លាមអូខេ?»
«ចាំ!»
គេដាក់ទូរសព្ទចុះបន្សល់ឲ្យស្រីស្អាតនូវក្ដីបារម្ភថ្មី។
ការបង្កើតឆាកស្នេហាដោយរៀបចំ ហើយដែលភាគីណាម្នាក់មិនបានតាំងចិត្តអាចជារឿងពិបាក ប៉ុន្តែលើកនេះ រវាងនាងនិងយុត្តនា គឺទាំងសងខាងហាក់បីដូចជាមានចេតនាឲ្យវាកើតឡើង អញ្ចឹងទើបតែបានលទ្ធផលលេចមុខសង្សារចាស់មកវិញ តើអ្វីនឹងកើតឡើង។ ចុះបើពូនាងដឹងពីទំនាក់ទំនងពីមុនរបស់នាង គាត់នឹងថាយ៉ាងណា?
បុស្បាធ្លាក់ទៅក្នុងក្ដីកង្វល់សាជាថ្មី។

ទោះបីយ៉ាងណា នៅថ្ងៃបន្ទាប់ៗមក ភាពផ្អែមល្ហែមល្ហិនរបស់អ្នកប្រុសទីមួយ ហួត ស៊ីវ និងតារាម៉ូដែលល្បីឈ្មោះបានបង្ហាញចេញមកដូចដែលលេខាប៉េងចង់បាន ព្រោះយុត្តនាកំពុងរុញទូកបណ្ដោយទឹក ហើយភាគីខាងស្រីកំពុងត្រេកត្រអាលនឹងទំនាក់ទំនងនេះ។
ជារៀងរាល់ថ្ងៃមនុស្សម្នាឃើញយុត្តនានិងសិល្បៈ ការិនីបណ្ដើរគ្នាចុះឡើងនៅតាមហាងទំនិញទាំងឡាយ ភោជនីយដ្ឋាននិងកន្លែងកម្សាន្តផ្សេងៗ។ ប៉េងកាន់តែសប្បាយចិត្តព្រោះថាទោះបីយុត្តនាបង្ហាញខ្លួននៅធនាគារ ទៀងទាត់ពេលវេលានិងមានការងារដ៏ស្មុគនិងរវល់ តែគេនៅតែមានទឹកមុខ ញញឹមប្រិមប្រិយតាមរបៀបអ្នកកំពុងទើបតែមានស្នេហា។

«ហើយថ្ងៃនេះ អាល្អិតនោះអត់ហៅឯងទៅណាទេ?»
លេខាវ័យចំណាស់ពោលសួរក្មួយស្រីដែលកំពុងប្រិមប្រិយក្នុងការបានបេះដូងបុរសនាយកធនាគារតាមគម្រោងការពូនាង។
បុស្បាឆ្លើយដោយមិនងើបមុខពីការចាក់កន្សែងបង់ក វែងអន្លាយពណ៌ប្រផេះ។
«គាត់រវល់! ថ្ងៃនេះមានប្រជុំដល់ទៅបីជាប់គ្នា!»
តាចាស់ដៀងភ្នែកសម្លឹងកន្សែងចាក់ក្នុងដៃស្រីស្អាត។ គាត់ដឹងថាអ្នកណាជាម្ចាស់របស់នេះហើយ។គាត់ក្រៅពីសប្បាយ ថែមទាំងស្ញើចក្នុងចិត្តដែលរយៈពេលខ្លីសោះ ហួត យុត្តនា នៅឯណាធ្វើអ្វី គឺបុស្បាដឹងគ្មានសល់។
គាត់សួរបញ្ជាក់៖
«ថ្ងៃសុក្រនេះ វាព្រមចេញទៅក្រៅប្រទេសតាមឯងមែន?»
«ចាំ»នាងឆ្លើយដោយទំនុកចិត្តហើយញញឹមខ្ញីបសម្លក់កន្សែងក្នុងដៃ។ ចិត្តនាងកំពុងស្រមៃ

ថា គេនៅជាប់ក្នុងកន្សែងនេះ គឺនៅក្នុងចំណងរបស់នាង។ តែលេខាប៉េងរភ្នែកដ៏តូចរបស់គាត់គិតសាចុះសាឡើង។
«ពូនៅតែមិនទាន់ទុកចិត្ត!»
បុស្បាងើបមុខដ៏ស្រស់ផូរផង់សម្លឹងមកពូខ្លួនទាំងចម្ងល់លេចចេញលើ ផ្ទៃមុខ។ នាងមិនទាន់សួរទេតែគាត់និយាយពន្យល់មកជាស្រេចទៅហើយ៖
«លើកលែងតែ ….»
នាងកាន់តែអន្ទះសាចង់ស្ដាប់ គាត់បន្ថែមផ្ទួង៖
«វាហ៊ានបណ្ដើរឯង នៅនឹងមុខ ក្មេងស្រីនោះ! ពៅបញ្ញា!»
បុស្បា ទម្លាក់ទឹកមុខ ភ្នែកនាងផុសចេញនូវពន្លឺច្រណែននិងក្រអឺត។
សំឡេងបុរសមានល្បិចលាន់មកបន្ត៖
«ឯងទុកចិត្តខ្លួនឯងដែរអត់ក្មួយរបស់ពូ?»
បុស្បាមិនមាត់តែនាងមានភាពសៅហ្មងលើផ្ទៃមុខ។ ទោះបីមិនដែលជំពាក់ មាត់អ្វីជាមួយគ្នាទោះបីថា យុត្តនា មិនដែលមានសង្សារច្បាស់លាស់ជាមួយអ្នកណា ដូចជាមួយខ្លួនប៉ុន្តែករណីមេធាវីនោះនៅតែជាបន្លាក្នុងចិត្តនាង ។ លេខាប៉េងរំលឹកមកភ្លាមៗធ្វើឲ្យបុស្បាភ្លេចអស់នូវសុភមង្គលទាំង ឡាយដែលនាងកំពុងក្ដាប់ក្នុងដៃ។ ស្រីស្អាតនិយាយតិចៗ៖
«ខ្ញុំក៏ចង់ដឹងដូចគ្នា!»

## ២៣

### គម្រោងពាណិជ្ជកម្ម ចុងក្រោយរបស់បងរាជ

ទោះយ៉ាងណាការសប្បាយរបស់ប៉េងមិនអាចលាក់បាំងផុតពីកន្ទុយ ភ្នែកថៅកែគាត់ឡើយ ហួត ស៊ីវនៅស្ងៀមទ្រាំស្ដាប់របាយការណ៍កូនចៅដែលរាយការណ៍ពីលទ្ធផលពីការ ឃ្លាំមើលលើគោលដៅទាំងឡាយដែលគាត់បានបញ្ជាទៅ។

«អ្នកប្រុសធំកក់សំបុត្រយន្តហោះជាមួយតារាម៉ូដែលនោះ យប់ថ្ងៃសុក្រនេះគាត់នឹងចេញទៅប្រទេសជប៉ុនជាមួយគ្នា!»
ហួត ស៊ីវ រអ៊ូតិចៗ៖
«ដើរបានឆ្ងាយល្អណាស់ណ៎ា? ក្មួយស្រីអាប៉េងចង់នាំកូនប្រុសខ្ញុំចេញឆ្ងាយពីខ្ញុំប៉ុន្មានថ្ងៃ

ប៉ុន្មានខែ?»
ហួត ស៊ីវ មិនមែនថាមិនសង្ស័យចំពោះអ្វីៗដែលបម្រុងនឹងកើតឡើងនោះទេ គ្រាន់តែថាគាត់មិនទាន់ច្បាស់រវាងលេខាប៉េងនិងកូនប្រុសទីពីរ តើអ្នកណាទៅជាមនុស្សគ្រោះថ្នាក់ឲ្យប្រាកដ។ ពីដំបូងនៅពេលដែលលេខាប៉េងលើកឡើងនូវអំណោះអំណាងផ្សេងៗប្រឆាំងនឹង កូនប្រុសធម៌ទីពីរ ហួត ស៊ីវ នៅរង់ចាំមើលថាតើកូនប្រុសទីពីរមានធ្វើអ្វីគួរឲ្យកត់សំគាល់ឬ ទេ? ស្រាប់តែចុងក្រោយនេះលេចចេញស្នេហាផ្អែមល្ហែមថ្មីរវាងនារីម៉ូដែល និងកូនប្រុសច្បងទៅវិញ។ ហើយពេលដែលអ្នកស៊ើបការណ៍រាយការណ៍ថាបុស្បានារីជាក្មួយចិញ្ចឹមប៉េង ទៀត ហួត ស៊ីវ កាន់តែពិចារណា។ គាត់ងើបមុខសួរទៅកាន់កូនចៅ៖
«អ្នកប្រុសទីពីរអត់មានមកទេ?»
«អត់មានសោះទាន! គាត់ដូចជារវល់ខ្លាំងណាស់ នៅសំងំមន្ទីរពេទ្យច្រើនជាងនៅផ្ទះ ព្រោះប៉ែន ពេជ្រ នៅមិនទាន់និយាយរួចនៅឡើយ»
ហួត ស៊ីវ រិះគិតក្នុងចិត្តស្ងាត់ៗ៖
«ខេមរិទ្ធិ! កូនឯងកំពុងគិតអ្វីហើយកំពុងធ្វើអ្វី កូនឯងពិតជាលង់ចិត្តលើអាកញ្ញាស់នោះ ដល់ថ្នាក់លែងស្គាល់ឪពុកខ្លួនឯងពិតមែន ឬមួយក៏កំពុងជាប់ដៃក្នុងការស្វែងរកគម្រោងពាណិជ្ជកម្មនោះ?»
គាត់ងើបមុខសួរទៅកាន់កូនចៅដែលនៅឈរជ្រប់មុខរង់ចាំទទួលបញ្ជា៖
«នាំម្ដាយ ខេមរិទ្ធិ មកភ្នំពេញហើយឬនៅ?»
«រួចរាល់ហើយទាន គាត់ស្នាក់នៅបន្ទប់ខាងក្រោយ ត្រូវជូនដំណឹងទៅអ្នកប្រុសទីពីរពេលណាដែរទាន!»
«នៅទេ យប់នេះខ្ញុំត្រូវការទៅមើលសិនថា កូនខ្ញុំរវល់ក្នុងពេទ្យម្ល៉ឹងៗដើម្បីអ្វី បើសិនគេពិតជាបែកឆ្វេងមែនចាំប្រាប់គេថាម្ដាយគេនៅទីនេះក៏ មិនទាន់យឺតពេលដែរ។»

រាត្រីកាលចូលមកដល់គ្របដណ្ដប់លើមន្ទីរពេទ្យដ៏ស្ងាត់ជ្រងំនិង ស្រងេះស្រងោច។ មនុស្សមានលុយនិងមានល្បិចច្រើនដូច ហួត ស៊ីវ មិនលំបាកឡើយក្នុងការបន្លំខ្លួនចូលទៅកាន់បន្ទប់ស្នាក់នៅវីអាយភី របស់ឧកញ៉ា ប៉ែន ពេជ្រ។ ហួត ស៊ីវឈរសម្លឹងអតីតមិត្តសម្លាញ់ដែលដេកលង់លក់ស្ងួកស្ងឹង ដៃជាប់សេរ៉ូម ច្រមុះមាត់ជំនួយដោយខ្យល់អុកស៊ីហ្សែន។
«វាសមមុខឯងហើយ អាមិត្តទ្រុស្តមិត្ត!»

ហួត ស៊ីវ គិតបណ្ដើររវើក្នែកសម្លឹងជុំវិញបន្ទប់បណ្ដើរ គេប្រទះឃើញកុំព្យូទ័រនិងទូរសព្ទដៃរបស់រិទ្ធិនៅលើកូនតុក្បែរ អ្នកជំងឺបង្ហាញថាអ្នកប្រុសទីពីរនៅមិនឆ្ងាយប៉ុន្មានពីទីនេះ ឡើយ។ គាត់បន្តសើចចំអកស្ងាត់ៗក្នុងចិត្តម្នាក់ឯង៖

«វារឹតតែសមមុខឯងទៅទៀត ដែលកូនដល់ទៅបីបួននាក់គ្មានអ្នកណាមកដេកកំដរឯងមួយ!»

ស្នូរជើងអ្នកណាម្នាក់នៅខាងក្រៅទ្វារ ធ្វើឲ្យ ហួត ស៊ីវ ប្រញាប់ប្រញាល់រវើក្នែករកកន្លែងលាក់ខ្លួន។ ចុងក្រោយគាត់បានចូលដល់បន្ទប់ទឹកសំងំលាក់ខ្លួនក្នុងនោះ បាន ៥ ៦ដង្ហើមមុនពេលរិទ្ធិចូលមកដល់បន្ទប់នេះដែរ។ តាមរយៈប្រលោះទ្វារដែលបិទមិនទាន់ជិត ហួត ស៊ីវ ឃើញរូបរាងស្គមខ្ពស់របស់ប្រុសទីពីរដើរសំដៅគ្រែអ្នកជំងឺដោយមាន កំប៉ុងកាហ្វេនៅនឹងដៃ។ សម្រាប់ភ្នែករបស់ ហួត ស៊ីវរិទ្ធិគឺស្រកសាច់សន្ទឹក ហើយទឹកមុខគេពោរពេញទៅដោយទុក្ខកង្វល់។

ហួត ស៊ីវ រិះគិតដោយមួហ្មង «ឯងអាណិតវាដល់ថ្នាក់ស្គមខ្លួនឬអ្វីអាកូនចម្កួត ឯងទីបំផុតព្រមយកចោរធ្វើជាឪពុករស់នៅជាមួយវាយូរៗ ចាញ់នយោបាយវាឬក៏ចាញ់ស្នេហ៍កូនស្រីខ្មៅក្រិតរបស់វា? ប៉ែន ពេជ្រ ម្ដៃឆ្នាំមុនឯងដណ្ដើមបេះដូងបងរាជពីយើង ក្រោយមកដណ្ដឹងសង្សារយើងជាប្រពន្ធ ហើយឥលូវឯងប្រុងយកទាំងកូនប្រុសធម៌យើងទៀត?» គាត់ដកអារម្មណ៍ពីភាពទោមនស្សមកវិញព្រោះអ្នកជំងឺចាប់ផ្ដើមក្អក ខេះៗ ហើយរិទ្ធិស្រែកហៅតិចៗ៖

«លោកឪកញ៉ា?»

សំឡេងឧកញ៉ា ប៉ែន ពេជ្រ លាន់តិចៗបន្ទាប់ពីគាត់លើកប្រអប់បំពង់ខ្យល់ចេញពីច្រមុះ៖

«ថ្មើរណោះហើយក្មួយមិនទាន់សម្រាកទៀតរិទ្ធិ?»

មិនខ្វល់ថារិទ្ធិឆ្លើយតបយ៉ាងណាទេ ហួត ស៊ីវ នៅឯនេះចាប់ផ្ដើមកើតឆេះឆួលនៅក្នុងចិត្ត គាត់គិតទាំងទោសៈ៖

«ពីរនាក់នេះលេងល្បិចបំភាន់ភ្នែកអ្នកផងបានល្អ! ឯងថាអា ប៉ែន ពេជ្រ និយាយមិនរួចការពិតកុហក ពីរនាក់ឯងសំងំជួបគ្នាក្នុងពេលនេះ តើកំពុងរៀបផែនការអ្វី ទីបំផុតឯងអាចធ្វើឲ្យកូនប្រុសយើងប្រឆាំងនឹងយើង?»

សំឡេងរិទ្ធិលាន់មកតិចៗពីក្រៅទ្វារ៖

«ឧកញ៉ាទើបតែនិយាយរួចកុំប្រឹងនិយាយពេក សម្រាកឲ្យមានកម្លាំងទៅ ការងារនៅផ្ទះនិងក្រុមហ៊ុនអ្នកនាងពៅបញ្ញាដោះស្រាយបានរួចរាល់អស់ ហើយ»

«ខ្ញុំចង់ចេញពីមន្ទីរពេទ្យ ខ្ញុំដេកស្ញៀមយូរហើយក្ដួយ ខ្ញុំមិនចង់ដេកស្ញៀមតទៀតទេ!»
រិទ្ធិងក់ក្បាលផ្ងក់ៗព្រោះយល់ចិត្តគាត់។ បុរសខ្លាំងម្នាក់ដែលសកម្មខាងការងារជំនួញបែរជាត្រូវមកបង្ខាំង ខ្លួននៅក្នុងមន្ទីរពេទ្យច្រើនថ្ងៃមកហើយ គាត់អន្ទះសាចាកចេញពិតជាត្រឹមត្រូវណាស់។ សម្ដីរបស់ ប៉ែន ពេជ្រ ស្រាប់តែដាស់អារម្មណ៍អ្នកកំលោះឲ្យនឹកឃើញទៅដល់រឿងហេតុកើតឡើង ទាំងអំបាលម៉ានកាលពីពេលថ្មីៗនេះ ពិសេសគឺឧបាយកលទាំងឡាយរបស់លេខាប៉េង។ គេហើបមាត់តិចៗដោយមិនដឹងខ្លួន ព្រោះលង់ទៅក្នុងចំណោទបញ្ហាដ៏ស្មុគស្មាញ៖
«ឧកញ៉ា! មួយរយៈនេះខ្ញុំជួបមនុស្សម្នាក់ឈ្មោះប៉េង គេដូចជាកំពុងធ្វើការឲ្យអគ្គទេសាភិបាល ហួត ស៊ីវ ខ្ញុំសង្ស័យថាគេកំពុងធ្វើអ្វីម្យ៉ាងដែលអាក្រក់ច្រើនជាងល្អ ពិសេសពាក់ព័ន្ធនៅនឹងការលបលួចដាក់ថ្នាំរំញោចទៅក្នុងកែវទឹករបស់ លោកឧកញ៉ានៅថ្ងៃដែលឧកញ៉ាណាត់ជួបលោកយុត្តនា!»
ប៉ែន ពេជ្រ ចងចិញ្ចើមរិះគិត នៅឯនេះ ហួត ស៊ីវ ក្ដាប់ដៃទាំងសៅហ្មងគាត់រិះគិតបន្តះ
«សូម្បីតែរឿងអញ្ចឹងក៏ឯងប្រាប់វា ឯងក្បត់នឹងប៉ាពេញទីហើយរិទ្ធិ»
សំឡេង ប៉ែន ពេជ្រ លាន់មកបន្តះ
«ប៉េងណាខ្ញុំនឹកមិនឃើញទេ ប៉ុន្តែបើថាវាជាមនុស្សជំនិតរបស់ ហួត ស៊ីវ ប្រាកដណាស់លើកនេះហួត ស៊ីវ វាលេងខ្ញុំ បើខ្ញុំជា! ខ្ញុំនឹងទៅសួរវាថា ហេតុអ្វីវាចង់ឲ្យខ្ញុំស្លាប់ម្ល៉េះ?»
រិទ្ធិឈ្ងោកមុខសម្លឹងឥដ្ឋ។ តាមពិតក្រៅពីការចង់ស្វែងរកប្រវត្តិពិតរបស់លេខាប៉េង គេនៅមានបំណងដ៏សំខាន់មួយទៀតកប់ក្នុងទ្រូងជាយូរមកហើយ នោះគឺការរកមធ្យោបាយបញ្ចប់គំនុំរវាងឪពុកធម៌ខ្លួននឹងបុរសចំណាស់ ម្នាក់នេះ។ គេលាន់មាត់ដោយគ្មានព្រាងទុកះ
«ឧកញ៉ា! ក្នុងចំណោមមិត្តទាំងបួនអគ្គទេសាភិបាល ហួត ស៊ីវ គឺជាមិត្តចុងក្រោយដែលនៅមានជីវិត ហេតុអីលោកយល់ថាគាត់ចង់ឲ្យលោកស្លាប់ ឬមួយមនោសញ្ចេតនាមិត្តភាពរវាងអ្នកទាំងពីរពិតជារលាយបាត់ប្រាកដ មែន?»
ហួត ស៊ីវ ក្ដាប់មាត់រង់ចាំស្ដាប់ចម្លើយរបស់ ប៉ែន ពេជ្រ ដូចគ្នា។ ស្មានមិនដល់ថាឪពុករបស់មេធាវីមិនឆ្លើយនឹងសំណួរនេះ បែរជាដកដង្ហើមវែងហាក់តឹងទ្រូង។ រិទ្ធិឃើញគាត់ហាក់ប្រឹងច្រត់ដៃប្រឹងឡើងអង្គុយក៏ជួយគ្រាគាត់ និងរវៃកម្ពស់គ្រែបន្ថែមឲ្យគាត់បានផ្អែកខ្នងផង។
«គឺគម្រោងរតនៈសោភ័ណដែលធ្វើឲ្យអាស៊ីវ វាភ្លីភ្លើល្ងីល្ងើដល់ថ្ងៃនេះ!»
រិទ្ធិនៅទ្រឹងចលនានិមិត្តតែរឿងបុរសចំណាស់រំលឹកសាជាថ្មីពី គម្រោងការអច្ឆរិយនោះ។ ហួត

ស៊ីវ ក៏ភ្លឹកស្មារតីនឹងឃ្លាដ៏ខ្លីចុងក្រោយនេះ រហូតដល់គាត់លែងខ្វីក្រោធខឹងចំពោះពាក្យដែលដៀលថាភ្លីភ្លើ ល្ងីល្ងើ។
«វាស្មានថាបងរាជស្លាប់ទៅ ទុកគម្រោងការនោះនៅនឹងខ្ញុំ បានជាវាច្រណែនគុំគួនកើតជារឿងចងអាឃាតគ្នាដល់ថ្ងៃនេះ!»
រិទ្ធិថយមកអង្គុយលើកៅអីវិញជាមួយនឹងសំណួរវិលខ្វាល់ពេញក្នុងអារម្មណ៍៖
«ឬមួយឧកញ៉ា ប៉ែន ពេជ្រ ពិតជាគ្មានរបស់គម្រោងពាណិជ្ជកម្មនោះក្នុងដៃទេ?»
ហួត ស៊ីវ សើចស្ងួតម្នាក់ឯង៖
«ងើបពីងាប់ភ្លាមចេះលេងល្បិចភ្លាមហ្ន៎??»

ស្នូរដង្ហើមធំរបស់ឧកញ៉ា ប៉ែន ពេជ្រ លាន់ឡើងកំដរភាពស្ងាត់ជ្រងំនៃផ្ទៃបន្ទំ។ រិទ្ធិនៅតែរក្សាភាពស្ងៀមស្ងាត់មិនសួរសំណួរអ្វី មិនមានប្រតិកម្មអ្វីដែលបង្ហាញថាខ្លួនអ្នកកំពុងពុះកញ្ជ្រោលចំពោះ ការបង្ហើបចុងក្រោយនេះឡើយ។ ឃើញដូច្នោះ ប៉ែន ពេជ្រ រឹតតែជឿថាបុរសក្មេងម្នាក់នេះ គ្មានការខ្វល់ខ្វាយចំពោះអ្វីទៅដែលហៅថាគម្រោងពាណិជ្ជកម្មរតនៈ សោភ័ណនោះទាល់តែសោះ។ អ្វីមួយបានញ៉ាំងឲ្យបុរសទើបតែរួចពីស្លាប់ កាន់តែចង់និយាយចេញមកនៅអាថ៌កំបាំងដែលកប់ក្នុងចិត្តជាច្រើនឆ្នាំ មកហើយ។
«ខ្ញុំនិយាយពីគម្រោងពាណិជ្ជកម្មដ៏ល្បីកក្រើកមួយក្នុងមជ្ឈដ្ឋាន អ្នករកស៊ី ជាពិសេសពួកអ្នករកស៊ីផ្នែកមាសពេជ្រកែវកងនិងត្បូងថ្ម។ មិត្តសម្លាញ់ខ្ញុំម្នាក់គឺបងរាជ គាត់ជាបុគ្គលមានទេពកោសល្យអច្ចរិយ គម្រោងពាណិជ្ជកម្មទាំងឡាយដែលគាត់សរសេរឡើងត្រូវបានដណ្ដើមគ្នាចង់ បានដោយពួកថៅកែធំកាលពីសម័យនោះ!»
ប៉ែន ពេជ្រ បញ្ឈប់ប្រយោគកណ្ដាលទីដោយក្អកខេះៗ។ ប្រការនេះធ្វើឲ្យបុរសដែលលបស្ដាប់ពីក្នុងបន្ទប់ទឹករឹងរឹតតែ អន្ទះសាតឹងណែនពេញទ្រូង រិទ្ធិងើបមុខសន្សឹមៗសម្លឹងនាយថៅហ្វាយ គេពោលសួរមួយៗធ្វើដូចភ្ញាក់ផ្អើល៖
«លើលោកនេះពិតជាមានមនុស្សពូកែដល់ម្លឹង?»
ប៉ែន ពេជ្រ មិនខ្វល់ក្នុងការឆ្លើយបញ្ជាក់ទៅនឹងសំណួរនេះទេ គាត់បន្តនិយាយមួយៗដូចនិយាយឲ្យខ្លួនឯងស្ដាប់៖
«គម្រោងការចុងក្រោយនៅក្នុងជីវិតរបស់គាត់មានឈ្មោះថារតនៈសោភ័ណ ជាផែនការរកស៊ីដែលមានសក្ដានុពលរយៈពេលវែង ផ្ដោតលើធនធានធម្មជាតិត្បូងថ្មនៅខេត្តរតនៈគិរី។

គម្រោងការនេះត្រូវបានគេនិយាយតៗគ្នា ហើយចៅកែជាច្រើនត្រូវឆ្កួតវង្វេងដោយសារវា!»
រិទ្ធិពោលសួរវិញ៖
«មានមនុស្សជឿរឿងអស់នេះដែរ?»
ប៉ែន ពេជ្រ ដៀងភ្នែកមើលមកនាយ ហើយគាត់សួរបកត្រលប់វិញ៖
«មានន័យថាក្មួយមិនជឿ?»

រិទ្ធិដឹងខ្លួនថាខ្លួនត្រង់ជ្រុលពេក ម្ល៉ោះហើយគេញញឹមមិនឆ្លើយតប តែទឹកមុខរបស់គេបានបញ្ជាក់ប្រាប់ទៅឧកញ៉ា ប៉ែន ពេជ្រ ជាស្រេចហើយថា គេជាមនុស្សដែលជឿតែលើអ្វីដែលគេបានឃើញផ្ទាល់ភ្នែកតែប៉ុណ្ណោះ ឯពាក្យចចាមអារ៉ាមមិនអាចធ្វើឲ្យគេឆ្កួតវង្វេងបានឡើយ។
មនុស្សគឺចម្លែកដូច្នេះហើយ នៅពេលដែលគេកាន់តែមិនចង់បាន ខ្លួនក៏កាន់តែចង់និយាយប្រាប់ ប៉ែន ពេជ្រ គឺឋិតនៅក្នុងស្ថានភាពបែបនេះឯង គាត់និយាយបន្តយឺតៗ៖
«បើគ្រប់គ្នាសុទ្ធតែមានគំនិតដូចក្មួយ ពូប្រហែលបានធូរស្រាលច្រើន! ប៉ុន្តែខុសគ្នាត្រង់ថាអ្នកនៅក្នុងសង្គមពាណិជ្ជកម្មសុទ្ធតែជា មនុស្សលោភ បើថ្ងៃនេះគេមានមួយលាន គេសម្លឹងចង់បានដប់លាននៅថ្ងៃស្អែក! ដែលកាន់តែលំបាកនោះគឺថាគម្រោងការមុនៗរបស់គាត់សុទ្ធតែទាក់ទាញ បានប្រាក់ចំណូលបានច្រើនហួសទៅហើយ ភស្តុតាងនោះធ្វើឲ្យគ្រប់គ្នាយល់ថា ទម្រាំថាគម្រោងការដ៏ថ្មី សន្លាងនេះទៀត តើវាអាចនាំមកនូវផលប្រយោជន៍មហាសាលកម្រិតណាទៅ?»
រិទ្ធិសួរកាត់៖
«គាត់ស្លាប់ដោយសារតែគម្រោងការនេះមែនអត់?»
ហ្លួត ខេមរិទ្ធិ អ្នកប្រុសទីពីររបស់ ហ្លួត ស៊ីវ ប្រហែលជាអាចគិតដូចមនុស្សច្រើនគ្នាថា បុគ្គលដែលមានវត្ថុមានតម្លៃក្នុងដៃហើយត្រូវបានគេដឹងឮច្រើនពេក ច្រើនតែរស់នៅមិនបានយូរ។ ទោះបីគេបញ្ឈប់សំណួរដ៏ខ្លីត្រឹមតែប៉ុណ្ណេះ ប៉ុន្តែក្នុងចិត្តគេបានគិតហួសដល់រឿងផ្សេង។ គេមិនដឹងថា តើម្ចាស់គម្រោងនោះត្រូវគេសម្លាប់ដើម្បីដណ្តើមធ្វើជាកម្មសិទ្ធិ ដែរឬក៏យ៉ាងណា? បើមែនអ្នកដែលមានគម្រោងការក្នុងដៃនោះហើយជាអ្នកសម្លាប់គាត់ ហើយបើសិនជាឧកញ៉ា ប៉ែន ពេជ្រ បច្ចុប្បន្នជាម្ចាស់គម្រោងនោះ មានតែជាងកាលពីដប់ឆ្នាំមុនគាត់ជាឃាតកសម្លាប់មិត្តភ័ក្តិគាត់ ដើម្បីប្លន់យកវា។ ឥលូវនេះទៀតឪពុកធម៌ខ្លួន ហ្លួត ស៊ីវ ហេតុតែចិញ្ចឹមចិត្តចង់

បានគម្រោងការនោះបានប្រើប្រាស់គ្រប់ល្បិចកល ប្រឆាំងទៅនឹងមិត្តភ័ក្តិ ដែលនៅសល់តែមួយគត់របស់ខ្លួន ដោយបង្កើតឡើងជាបញ្ហាស្មុគស្មាញជាច្រើនជំពូកដល់មនុស្សជំនាន់ក្រោយៗ។ អ្នកប្រុសទីពីរដកដង្ហើមវែង ហើយនិយាយមួយៗដោយក្រៀមក្រំ ៖
«តើបានប្រយោជន៍អីទៅ បើកសាងគម្រោងដ៏អស្ចារ្យមួយមកសម្រាប់តែបំផ្លាញខ្លួនឯង ហើយបង្កើតរឿងទុក្ខវេទនាច្រើនដល់ម្ល៉ឹង!»
ឧកញ៉ា ប៉ែន ពេជ្រ ស្ដាប់ឮហើយសួរតបមកកាន់រិទ្ធិវិញ៖
«ក្មួយយល់ថា បងរាជស្លាប់ដោយសារមានគម្រោងនោះក្នុងដៃមែនទេ?»
រិទ្ធិនៅស្ងៀមមិនឆ្លើយ ឧកញ៉ា ប៉ែន ពេជ្រ និយាយបន្តដោយទឹកមុខក្រៀមក្រំ៖
«មិនមែនទេ គឺគាត់ស្លាប់មុនពេលសរសេរគម្រោងនេះចប់!»

រិទ្ធិងើបមុខហើយជ្រួញចិញ្ចើមដោយចម្ងល់មួយរយជំពូក។ គេសម្លឹងទៅបុរសចំណាស់ដែលនៅពីមុខខ្លួន គឺសម្លឹងក្នុងរបៀបពិនិត្យឲ្យជាក់ថា តើអ្វីដែលគាត់កំពុងនិយាយជាការពិតឬក្លែងក្លាយ។
ទោះបីយ៉ាងណាគេមិនអាចអត់ធ្មត់មិនសួរសំណួរបន្ទាន់នោះទេ៖
«ឧកញ៉ាចង់មានន័យថាគម្រោងការដែលគេល្បីតគ្នានោះ គ្រាន់តែជាគម្រោងការដែលសរសេរមិនទាន់ចប់?»
ហួត ស៊ីវ នៅក្នុងបន្ទប់បន្ទោសខ្លួនឯងក្នុងចិត្តស្ងាត់ៗ៖
«ឯងឆ្កួតជឿវាទៅអាស៊ីវ!!»
ចំណែករិទ្ធិវិញកាន់តែក្ដុកក្ដាក់ក្នុងចិត្ត។
ជាយូរមកហើយដែលគេចម្លែកក្នុងចិត្តថា ប្រសិនបើឧកញ៉ា ប៉ែន ពេជ្រ ពិតជាមានគម្រោងនោះក្នុងដៃ មិនសមថាគាត់មិនយកវាប្រើក្នុងរយៈពេលច្រើនឆ្នាំមកនេះ។ ហេតុផលមានតែពីរប៉ុណ្ណោះទីមួយគឺគម្រោងការនោះគ្មានប្រសិទ្ធភាពទេ ចំណែកទីពីរដូចគាត់និយាយអញ្ចឹង គឺនោះជាគម្រោងការខ្យល់ដែលគ្មាននៅលើលោកនេះ។ នរៈយើងងើបមុខសួរសំណួរបន្ត៖
«ចុះហេតុអីក៏ឧកញ៉ាមិនប្រាប់គ្រប់គ្នាឲ្យដឹងពីការពិតនេះទៅ ម៉េចក៏ឧកញ៉ាទុកឲ្យគ្រប់គ្នានៅតែចង់បានគម្រោងការនោះ ពិសេសអគ្គទេសាភិបាល ហួត ស៊ីវ ដែលនៅតែយល់ខុសទល់សព្វថ្ងៃ!»
ប៉ែន ពេជ្រ សើចជូរចត់៖

«ព្រោះបងរាជស្លាប់ ហើយមុនពេលស្លាប់គាត់បានមានជំងឺដ៏ធ្ងន់ធ្ងរផ្នែកបញ្ញាស្មារតី ចាប់តាំងពីទំព័រទីមួយនៃគម្រោងការរតនៈសោភ័ណ វាគឺជាការសរសេរផ្ដេសផ្ដាសគ្មានក្បាលគ្មានកន្ទុយរបស់មនុស្សខូច ខួរក្បាលម្នាក់តែប៉ុណ្ណោះ។ មុនពេលគាត់ស្លាប់ខ្ញុំបានសន្យាចំពោះមុខគាត់ថា គាត់នៅតែជាមហាបុរសផ្នែកពាណិជ្ជកម្ម គ្មានអ្នកណាដឹងពីស្ថានភាពចុងក្រោយរបស់គាត់ ហើយគ្មានអ្នកណាដឹងថារតនៈសោភ័ណជាគម្រោងការខ្យល់របស់មនុស្សខូចសតិម្នាក់នោះទេ!»

រិទ្ធិហួសចិត្តចំពោះហេតុផលនេះ។

គេគិតចុះគិតឡើងនៅតែមិនយល់មិនទទួលស្គាល់ចំពោះហេតុផលនេះឡើយ បើព្រោះតែភក្ដីភាពចំពោះមិត្តភ័ក្ដិ ហើយឧកញ៉ា ប៉ែន ពេជ្រ សុខចិត្តឱបទុក្ខកង្វល់នេះ តើវាទំនងដែរទេ មនុស្សស្លាប់បាត់ទៅហើយយូរទៅគេគង់តែភ្លេច ហេតុអីគាត់ស្រលាញ់កេរ្តិ៍ឈ្មោះមិត្តភ័ក្ដិដល់ថ្នាក់លាក់បាំងការ ពិតទាំងអស់ បណ្ដោយឲ្យជីវិតខ្លួនឯងប្រឈមនឹងគ្រោះថ្នាក់គ្រប់ពេលវេលា គេនិយាយសួរទាំងសង្កត់ពាក្យមួយៗបង្ហាញថាគេងឿងឆ្ងល់ជាខ្លាំង៖

«ទោះយ៉ាងណា ឧកញ៉ាក៏គួរប្រាប់អគ្គទេសាភិបាល ហួត ស៊ីវ ដែរមែនអត់? អ្នកទាំងពីរជាមិត្តនឹងគ្នា មិនគួរទុកឲ្យមានរឿងយល់ច្រឡំយូរយ៉ាងនេះទេ ខ្ញុំជាក្មេងជំនាន់ក្រោយតែខ្ញុំសោកស្ដាយយ៉ាងខ្លាំងដែលឮរឿងនេះ»

«ក្មួយស្មានថាវាជឿខ្ញុំ?»

«តែពួកលោកជាមិត្តនឹងគ្នា?»

«ជាងម្ភៃឆ្នាំមុនចាស់ទុំក្នុងផ្ទះខ្ញុំបានដណ្ដឹងស្រីត្រកូល ខ្ពស់ម្នាក់មករៀបការនឹងខ្ញុំ នាងជាសង្សាររបស់ ហួត ស៊ីវ ដោយសាររឿងនោះវាមិនដែលគិតថាលើកលែងឲ្យខ្ញុំទេ!»

រិទ្ធិធ្លាក់ថ្លើមក្ដុកអស់កម្លាំងល្វិតល្វែហើយទ្រេតខ្នងទៅលើ កៅអី។ ឬមួយជំទាវ កុសុមាសព្វថ្ងៃជាអតីតសង្សារចាស់របស់ឪពុកធម៌ខ្លួន? គាត់ធ្វើរឿងជាច្រើនប្រឆាំងឧកញ៉ា បែន ពេជ្រ ដោយសារតែគំនុំស្នេហ៍ចាស់ ឬមួយដោយសារគម្រោងការពាណិជ្ជកម្មនោះ។ នៅពេលរិទ្ធិលែងមាត់លែងក ប៉ែន ពេជ្រ និយាយបន្ត៖

«នៅយប់ដែលបងរាជស្លាប់ ខ្ញុំបានខលទៅរកវាតែវាមិនលើកទូរសព្ទខ្ញុំទេ ក្រោយមកខ្ញុំយល់ថា ខ្ញុំនិយាយអីក៏វាមិនជឿដែរ ខ្ញុំក៏បណ្ដោយតាមហ្នឹងទៅ!»

នៅក្នុងបន្ទប់ទឹក ហួត ស៊ីវ និយាយប្រាប់ខ្លួនឯងស្ងាត់ៗក្នុងចិត្ត៖

«ទោះឥលូវឯងមកនិយាយក៏យើងនៅតែមិនជឿដដែល អាកំពូលល្បិច!!»
សំឡេងរិទ្ធិសួរឡើងថ្មមៗ៖
«ចុះលោកឧកញ៉ាមានសល់ភស្តុតាងសម្រាប់ការពារខ្លួនទេ? បើអ្វីទាំងអស់នោះជាការពិត ហេតុអ្វីលោកឧកញ៉ាខ្លាចអគ្គទេសាភិបាល ហួត ស៊ីវ មិនជឿ? ហើយមានអ្នកណាផ្សេងទៀតដឹងរឿងនេះដែរអត់?»
«ភរិយាខ្ញុំ! សក្ខកុសុមា! នៅថ្ងៃដែលបងរាជស្លាប់នាងក៏នៅទីនោះដែរ!»
ហួត ស៊ីវ ញ័រដៃជើងទ្រេតទៅទប់ខ្នងនឹងជញ្ជាំងបន្ទប់ទឹក។ បើសិនជាជំទាវសង្សារចាស់របស់គាត់នៅទីនោះដែរ នាងច្បាស់ជាដឹងថាអ្វីដែល ប៉ែន ពេជ្រ និយាយនេះជាការពិតឬគ្រាន់តែល្បិចមួយ។
«ឬមួយបងរាជពិតជាស្លាប់មុនពេលគម្រោងការនោះសរសេរចប់មែន?»
ហួត ស៊ីវ សួរក្នុងចិត្តដោយអារម្មណ៍វិលខ្វាល់មិនដឹងជើងត្បូង បើអាចធ្វើបានគាត់នឹងហោះទៅឲ្យដល់ផ្ទះស្ត្រីនោះ ដើម្បីសួរនាំ ហើយគាត់ជឿថានាងនឹងមិននិយាយកុហកលោកឡើយ។
សំឡេងអ្នកប្រុសទីពីរបន្តនូវសំណួរថ្មីមួយទៀត៖
«ចុះគម្រោងការដែលបានសរសេរផ្តេសផ្តាសនោះ ឧកញ៉ានៅរក្សាទុកដែរទេ?»
រិទ្ធិអន្ទះសាយ៉ាងនេះ ព្រោះគេពិតជាចង់ឲ្យអ្វីៗដែលបានឮក្នុងយប់នេះក្លាយទៅជាការ ពិតទាំងអស់ ដើម្បីឲ្យខ្លួនគេអាចផ្សះផ្សានូវទំនាស់រវាងបុរសចំណាស់ទាំងពីរ។
«គ្មានអីជាអាថ៌កំបាំងទេ!»
ឧកញ៉ានិយាយធ្វើហី។
«ខ្ញុំទុកនៅផ្ទះ! វាជាអក្សរសរសេរដៃរបស់បងរាជពិតៗ វាជាអនុស្សាវរីយចុងក្រោយរវាងខ្ញុំនិងមនុស្សដែលខ្ញុំគោរពបំផុត ក្នុងមួយជីវិតនេះ រឿងអីថាខ្ញុំមិនរក្សាវាទុក?»

រិទ្ធិសែនធូរស្រាលក្នុងចិត្ត។
ម្តងនេះគេយល់ថាគេសំណាងដែលអាចដោះស្រាយបញ្ហាទាំងពួងបានដោយងាយ ស្រួល។ ក្នុងសេចក្តីសង្ឃឹមរបស់គេ គឺថាបេសកកម្មក្នុងនាមជាអ្នកលួចរបស់ នឹងត្រូវប្តូរមកជាបេសកកម្មផ្សះផ្សាទំនាស់ដ៏ធំសម្បើម រវាងបុរសទាំងពីរវិញ ។
យប់នោះ រិទ្ធិចិញ្ចឹមចិត្តរង់ចាំឱកាសវិលត្រលប់ទៅផ្ទះ ដើម្បីស្វែងរកសំណៅឯកសារនោះ ឯ

ហួត ស៊ីវ ក៏ចេញទៅណាត់រកនារីជាទីស្រលាញ់របស់គាត់ ដើម្បីស្វែងរកការពិតកាលពីច្រើនឆ្នាំមុនដូចគ្នាដែរ។

## ២៤

ការពិត១សម្រាប់ ហួត ស៊ីវ

រាត្រីណាស់ហើយ សក្ខណាបើកឡានត្រលប់មកពីជួបជុំមិត្តភ័ក្តិចាស់ៗវិញ។ ប្រមាណប្រាំរយម៉ែត្រពីគេហដ្ឋាន នាងស្រាប់តែក្រឡេកភ្នែកទៅឃើញអ្នកម្តាយ បោះជំហានហាក់បន្ទាន់នឹងអ្វីម្យ៉ាង។ ស្ត្រីអភិជន ចូលទៅក្នុងភោជនីយដ្ឋានដ៏ទំនើបមួយ ដែលសក្ខណានាងមិនដែលចូលទៅទេពីមុនមក«ជំទាវ ម៉ាក់?»
នាងគិតយ៉ាងណាក៏គិតមិនយល់ថាយប់ថ្មើរនេះទៅហើយ តើអ្នកម្តាយមានធុរៈអ្វីនៅឯភោជនីយដ្ឋាននោះ នាងលើកទូរសព្ទបម្រុងចុចក៏ឃើញថារលត់ថ្ម ដូច្នេះខ្ជិលគិតច្រើនសក្ខណាបត់ឡានរឹងចូលទៅចតក្នុងបរិវេណចំណត ភោជនីយដ្ឋាននោះ។

«បង! ជំទាវប៉ាក់ខ្ញុំអំបាញ់មិញលោកចូលទៅខាងណាហើយ ខ្ញុំចង់និយាយពីស្ត្រីក្នុងសំលៀកបំពាក់ពណ៌ទឹកប្រាក់អំបាញ់មិញ!» នាងសួរទៅសន្តិសុខ ស្រីតូចដើរកាត់តាមសួនច្បារតម្រង់ទ្វារភោជនីយដ្ឋាន ដែលស្ងប់ស្ងាត់លន្លង់លន្លោចកំដរដោយភ្លេងវីយោឡុងស្រាលៗ នៅបរិវេណបន្ទប់ធំមានភ្ញៀវខ្លះ ប៉ុន្តែមិនឃើញវត្តមានម្តាយខ្លួនឡើយ សក្ខណារវេ្ភកសម្លឹងទៅកាន់បន្ទប់តូចៗជាច្រើន ដែលសម្រាប់ភ្ញៀវពិសេសៗចង់បានភាពជាឯកជន។
«ជំទាវម៉ាក់មកពិសាបាយជាមួយអ្នកណា បងប្រាថ្នាឬបងអមរា?» នៅខាងស្តាំដៃគឺផ្លូវឆ្ពោះទៅកាន់សួនច្បារខាងក្រោយ កុមារតូចម្នាក់រត់ចុះឡើងនៅទីនោះ ហើយព័ន្ធជើងដួលរមៀលទៅលើស្មៅ សក្ខណាបោះបង់ចោលការគិតពីអ្នកម្តាយ ដោយនាងចេញឆ្ពោះទៅសួនច្បារហើយលើកក្មេងនោះឡើង។
«ឃើញអត់រត់លឿនពេក! ចុះប៉ាម៉ាក់ទៅណា?»
ម្តាយក្មេងក៏មកដល់ ស្ត្រីនោះនិយាយអរគុណសក្ខណាហើយដឹកដៃកូនតូចគួរឲ្យស្រលាញ់ចុះទៅ ខាងក្នុងភោជនីយដ្ឋានវិញ។ សក្ខណារវេ្ភកសម្លឹងជុំវិញខ្លួន នេះគឺជាបរិវេណសួនច្បារដ៏ស្រស់បំព្រងងងឹតខ្លះភ្លឺខ្លះក្រោម អំពូលពណ៌ពងមាន់លម្អដោយអន្លើ។
«សុំទោសអ្នកនាងមានកក់តុទុកទេ?» សន្តិសុខម្នាក់ស្ទុះចេញពីទីណាមិនដឹង មកបាំងផ្លូវ

ឃាត់ដំណើរនាង។ ក្នុងវិនាទីដែលមិនដឹងថាត្រូវឆ្លើយយ៉ាងណា សក្ខណាធ្វើជានិយាយ៖
«គឺសន្តិសុខនៅមុខឲ្យខ្ញុំមករកជំទាវម៉ាក់នៅហ្នឹង!»
«អ! អញ្ចឹងអ្ហេបាទ! សុំអញ្ជើញ!» សន្តិសុខបើកផ្លូវបន្សល់នូវសំណួរមួយចំនួនក្នុងចិត្តស្រីស្អាត។
«ទើបតែដឹងទេនៀក នៅសួនច្បារក៏មានតុអង្គុយហូបអីដែរ ហើយអីក៏ពិសេសម៉េះ មានអ្នកយាមឃាត់ផ្លូវទៀត គិតទៅស្រុកខ្មែរចម្លែកៗ»

សក្ខណាបោះជំហានទៅមុខដោយសោមនស្សរីករាយ ព្រោះក្លិនផ្កាម្លិះលាក្រអូបស្រាលស្រទន់កំពុងទាក់ទាញមនោសញ្ចេតនា នាងយ៉ាងមានប្រសិទ្ធភាព។ ដោយចិត្តចង់ឃើញទិដ្ឋភាពនៅទីនេះនាងបានបោះបង់ចោលការតាមរកម្តាយ ទៅម្ខាងសិន។
ប៉ុន្តែសំឡេងស្រាលៗហើរតាមខ្យល់មកពីទីណាមិនដឹង ទាញចិត្តនាងឲ្យវិលមកវិញ។
«លោកគិតយ៉ាងមិចបានណាត់ខ្ញុំចេញមកថ្មើរណេះស៊ីវ?»
«ជំទាវម៉ាក់?»
នៅក្រោមពន្លឺភ្លើងព្រាលៗនាងបានរកឃើញទីតាំងដែលអ្នកម្តាយកំពុង មានវត្តមាន។ នោះគឺខ្ទុះដ៏ប្រណីតមួយបំពាក់ព័ទ្ធជុំវិញដោយកូនអំពូលភ្លើង ចម្រុះពណ៌។ ស្ត្រីអភិជនអង្គុយក្បែរកូនតុអាហារដែលក្រាលដោយសំពត់សនិងអ្វីៗ គ្រប់យ៉ាងលើនោះសក្បុសទាំងអស់ រួមទាំងកន្ត្រកផ្កានៅចំកណ្តាលតុផង។
តាំងពីពេលដែលនាងឮសំឡេងម្តាយអំបាញ់មិញនាងកាត់យល់ស្រេចហើយថា អ្នកដែលកំពុងនៅរួមតុជាមួយម្តាយមិនមែនជាបងប្រុសស្រីទាំងទ្វេ ឡើយ។ នៅពេលដែលនាងចង់ដឹងថាអ្នកណាម្នាក់កំពុងអង្គុយទល់មុខម្តាយរបស់ ខ្លួន នាងកាន់តែមិនហ៊ានបង្ហាញខ្លួនឆាប់រហ័ស ព្រោះអាចជារឿងខ្វះសុជីវធម៌ ប្រសិនបើម្នាក់នោះជាភ្ញៀវឬមិត្តភ័ក្តិរបស់គាត់។ ដែលកាន់តែគួរឲ្យទើសចិត្តនោះគឺដើមផ្កាម្លិះធំចង្រ្កោងរាយព័ទ្ធ ជាជួរបានធ្វើឲ្យនាងនៅតែលំបាកក្នុងការមើលឲ្យឃើញជនម្នាក់នោះ ។ នាងស្មានយ៉ាងណាក៏មិនគិតដល់ថា អ្នកដែលកំពុងនៅពីមុខម្តាយខ្លួនស្ងាត់ៗក្នុងបរិយាកាសដ៏ឯកជននោះ តាមពិតជាអគ្គទេសាភិបាលវ័យចំណាស់ដ៏ល្បីឈ្មោះនោះឡើយ។
រហូតដល់បុរសនោះបន្លឺសំឡេងរសាត់តាមខ្យល់មកប៉ះសោតានាងឮ៖
«ព្រោះខ្ញុំមិនចង់ទៅផ្ទះនោះ! ក្រែងនាងជាអ្នកហាមមិនឲ្យខ្ញុំទៅមែនអត់?»

គំនិតមួយលេចឡើងក្នុងអារម្មណ៍សក្ខណា សំឡេងនេះនាងដូចធ្លាប់ស្គាល់ប៉ុន្តែរកនឹកមិនឃើញថាជាអ្នកណា។

«លោកយល់ល្អហើយ ព្រោះខ្ញុំមិនចង់ឲ្យកូនអមរាឃើញលោក!»

ស្អីគេអីចេះ? អីក៏អាថ៌កំបាំងម្ល៉េះ? ម៉េចក៏អ្នកម៉ាក់មិនចង់ឲ្យបងអមរាដឹង? ចុះចំណែកខ្ញុំដែលមកឈរឃើញពេលនេះ។

ចម្ងល់បានរុញនាងឲ្យដើរសន្សឹមៗទៅក្បែរប្រុសស្រីទាំងពីរដោយមិនដឹងខ្លួន ។

សក្ខណា វែករំលងមែកដើមផ្កាម្លិះបែកមែកសាខាហើយសម្លឹងទៅរកផ្ទៃមុខ នៃបុរសចំណាស់ម្ចាស់ទ្រព្យសម្បត្តិមហាសាលដែលជារឿយៗនាងបានឃើញនៅក្នុង ទស្សនាវដ្ដី។

«លោក ហួត ស៊ីវ? »

នាងសួរខ្លួនឯងដោយភ្ញាក់ផ្អើល។

«មានការអ្វី លោកឆាប់និយាយទៅ! យប់ជ្រៅហើយខ្ញុំត្រូវទៅផ្ទះវិញ!»

ជំទាវនិយាយមួយៗដោយមិនសម្លឹងបុរសនោះឡើយ។ក្នុងចិត្តនាងគឺ តឹងតែងពេលឃើញបុរសនេះកាលណាព្រោះថាកូនស្រីច្បងអមរាទើបតែមានរឿង ហើយថ្មីៗដោយសារស្ដាប់ឮពីទំនាក់ទំនងអាថ៌កំបាំងកាលពីអតីតកាលនោះ រួចកាលណា មិននិយាយមិនស្ដីរកម្ដាយដើរផឹកស្រាបាត់ៗដល់យប់ជ្រៅនៅតាម ក្លឹបមិនទាន់ដោះស្រាយលើកទឹកចិត្តវិញបានផង បានជាជំទាវមិនចង់ជួប ហួត ស៊ីវសូម្បីតែបន្តិច នេះបើកុំតែគាត់បង្ខំថានាងមិនចេញមកនឹងទៅរកដល់ផ្ទះម៉្លេះសម នាងមិនព្រមមកតទល់ជាមួយបុរសនេះដាច់ខាត។

ក្នុងចិត្តសក្ខណាវិញក៏មិនសុខស្រួលប៉ុន្មានឡើយស្រីតូចគិតទាំងចម្ងល់៖

«មិត្តភ័ក្តិរបស់ប៉ាតើគាត់មានការអ្វីជាមួយជំទាវម៉ាក់ថ្មើរណេះ?»

សក្ខណាគិតម្នាក់ឯងទាំងភ្នែកមូលក្លំមុតថ្លា។

សូរសំឡេងបុរសចំណាស់បានឆ្លើយតបនូវចម្ងល់នានាដែលនាងកំពុងមាន៖

«ខ្ញុំចង់សួរបញ្ជាក់នាង ទាក់ទងជាមួយរឿងកាលពីជាងដប់ឆ្នាំមុន!»

សក្ខណាអាចមើលឃើញភាពស្មុគស្មាញនឹងទើសទាល់ដែលអណ្ដែតចេញមកលើ ផ្ទៃមុខអ្នកម្ដាយ។ លោកជំទាវឆ្លើយតបមួយៗ ដោយមិនសម្លឹងមុខគូសន្ទនា៖

«ស៊ីវ! ប៉ុន្មានលើកហើយដែលខ្ញុំប្រាប់ឲ្យលោកឈប់រំលឹកឈប់និយាយរឿងកន្លង ហួសទាំងអស់នោះ កូនអមរាខ្ញុំមិនទាន់និយាយបានឲ្យនាងស្ងប់ចិត្តផង ឥលូវប៉ាគេក៏កំពុងនៅមន្ទីរ

ពេទ្យ ហើយលោកមករកខ្ញុំនិយាយរឿងដដែលៗ សមដែរទេ?»
«គឺខ្ញុំមកសួរនាងពីគម្រោងការរបស់បងរាជ !......រតនៈសោភ័ណ!»
ជំទាវកុសុមាបើកភ្នែកធំៗសម្លឹងអតីតគូសង្សារ ។ លោក ហួត ស៊ីវ សម្លឹងនាងតបដោយពន្លឺភ្នែកមុតថ្លា។ ទោះបីនាងជានារីតែម្នាក់គត់ដែលគាត់ឱបជាប់ពេញបេះដូង ប៉ុន្តែនាងដឹងថាទឹកមុខគាត់លើកនេះមិនឲ្យនាងគេចវេះមិនឆ្លើយបាន នោះឡើយ។
បន្ទាប់មកនាងងាកមុខចេញ។
«ហេតុអីនៅសុខៗលោកមកសួរខ្ញុំរឿងអស់នេះ?»
ហួត ស៊ីវ សម្លឹងមុខនារីដែលគាត់ធ្លាប់ស្រលាញ់និងទុកចិត្តជាងគេ ហើយក្នុងចិត្តគាត់ក៏កំពុងវិលរំលឹកទៅដល់វាចារបស់ឧកញ៉ា ប៉ែន ពេជ្រ ដែលគាត់បានលបស្ដាប់ឮមុននេះនៅក្នុងមន្ទីរពេទ្យ។
ហួត ស៊ីវ និយាយបន្ថែមក្នុងសំឡេងមួយៗតិចៗ ប៉ុន្តែភ្នែកសម្លឹងមុខស្ត្រីអភិជនស្ទើរមិនប៉ប្រិចៈ
«គម្រោងរតនៈសោភ័ណការពិតគឺគ្មានទេមែនអត់? កុសុមា! បងរាជមិនសរសេរគម្រោងនោះចប់ទេមែនអត់? នៅពេលដែលមនុស្សគ្រប់គ្នានិយាយពីគម្រោងនោះ បងរាជបានឡប់សតិទៅហើយមែនអត់?»
ភាពស្លេកស្លាំងបន្ទាប់មកភិតភ័យបង្ហាញចេញយ៉ាងច្បាស់ជាក់ស្ដែងលើ ផ្ទៃមុខលោកជំទាវដ៏ស្រស់ផូរផង់។ ចំណែកសក្ខណាដ៏ទៀងត្រង់និងមានចិត្តដូចភ្លើងចំបើងចាប់ផ្ដើមចង ចិញ្ចើមក្របួចមាត់ខឹង។
«ម្នាក់នេះអាងអីមកសម្លុតជំទាវម៉ាក់?»
នាងគិតទាំងក្ដៅឆេវម្នាក់ឯង។
ទោះយ៉ាងណា ហួត ស៊ីវ រកឃើញចម្លើយពិតដែលបង្ហាញចេញលើផ្ទៃមុខរបស់ម្ដាយនាងសក្ខណារួច ជាស្រេចទៅហើយ។ មនុស្សស្គាល់គ្នាយូរយ៉ាងនេះ ជំទាវកុសុមាមិនអាចលាក់កំបាំងអារម្មណ៍ពិតរបស់គាត់ពីក្រសែភ្នែក ហួត ស៊ីវ បានឡើយ។ គាត់អស់កម្លាំងល្វិតល្វៃទម្លាក់ខ្លួនស្រុញទៅលើកៅអីបង្អែកហើយសើច តិចៗទាំងអស់សង្ឃឹម គឺសើចចំអកឲ្យខ្លួនឯងៈ
«នាងដឹងទេកុសុមា? ជាងដប់ឆ្នាំមកហើយ ដែលខ្ញុំតាមរករបស់នោះ នាងដឹងខ្ញុំនឿយហត់

យ៉ាងណា? នាងដឹងថាវាជាគម្រោងការខ្យល់ម៉េចក៏នាងមិននិយាយប្រាប់ខ្ញុំ? ហើយទុកឲ្យខ្ញុំឆ្កួតយូរយ៉ាងនេះ?»

ពួកគេនិយាយពីអ្វី?

នាងតូចគិតមិនយល់សោះ តែនាងមិនចង់យល់មិនចង់ដឹងទេ តែនាងគ្រាន់តែចង់ច្បាស់ក្នុងចិត្តថា តើអ្វីទៅដែលធ្វើឲ្យអ្នកម្ដាយហាក់ស្មុគស្មាញពន់ពេកនៅ ចំពោះមុខគេម្នាក់នោះ?។ នាងតាមដានទឹកមុខអ្នកមានគុណទាំងចិត្តញាប់ញ័រ។

លោកជំទាវងាកមុខមករកគូសន្ទនា តែគាត់ហាក់ភិតភ័យដែរបានជានិយាយទាំងទ្រូងដង្ហក់៖

«គឺមកពីលោកខ្លួនឯង ស៊ីវ! លោកលោភលន់ដល់ណា? លោកចង់មានបានដល់ណាទៀត ? លោកជោគជ័យប៉ុណ្ណេះហើយ ពេលណាទើបចេះស្ងប់?»

ហួត ស៊ីវ លែងមាត់ក។

គាត់គ្មានអារម្មណ៍មកស្ដាប់ពាក្យបន្ទោសអស់នេះទេ តែភាពអស់សង្ឃឹមរបស់គាត់បានក្លាយជាការពិត។

ស្ត្រីនេះជាមនុស្សតែម្នាក់គត់ដែលគាត់ស្រលាញ់ហើយជឿនាងជាងគេ។ តាំងពីដើមរៀងមក កុសុមាថាមែនគឺមែន មិនមែនគឺមិនមែន។ ពេលនេះនាងគឺជាសាក្សីចុងក្រោយសម្រាប់ឲ្យគាត់ប្រាកដថាអ្វីដែល គាត់បានស្ដាប់ឮក្នុងពេទ្យគឺជាការពិត។....ដែលវាជាការពិតដ៏សាហាវសម្រាប់គាត់។

ឃើញមុខគាត់....ជំទាវកុសុមាដឹងថាខ្លួនជ្រុលសម្ដី ហើយក៏កើតចិត្តអាណិតអតីតគូស្នេហ៍។ លោកជំទាវបន្ថយសំឡេងមកវិញ និយាយបន្តដោយស្រងូត៖

«កាលណោះ គឺប្ដីខ្ញុំបានសន្យាជាមួយបងរាជ ខ្ញុំនៅទីនោះដែរ ដូច្នេះខ្ញុំមិនអាចនិយាយប្រាប់អ្នកណាបានទេ ខ្ញុំសុំទោស! ឥលូវនេះលោកជ្រុលជាដឹងទៅហើយ ខ្ញុំសង្ឃឹមថាលោករំងាប់ចិត្តឈប់ចំណាយពេលចង់បានរបស់នោះទៀតទៅ! បងរាជមិនបានសរសេរវាទេ ដោយសារតែគិតពីគម្រោងនេះ គាត់បានធ្លាក់ខ្លួនឈឺធ្ងន់ទៅហើយ អ្វីដែលនៅសល់គឺក្រដាសសរសេរផ្ដេសផ្ដាសប៉ុន្មានសន្លឹកប៉ុណ្ណោះ! បងពេជ្រមិនចង់ឲ្យគ្រប់គ្នាគិតថាជីវិតចុងក្រោយរបស់បងរាជគឺជា មនុស្សសរសៃប្រសាទម្នាក់ អញ្ចឹងគាត់លាក់រឿងនេះជាងដប់ឆ្នាំមកហើយ លោកក៏ត្រូវជួយលាក់វាបន្តដែរ!»

ហួត ស៊ីវ សើចខឹកៗ.....កាន់តែសើចគឺកាន់តែផុសចេញនូវការឈឺចាប់មក។
«ពេលនេះខ្ញុំទើបតែដឹងការពិត! ជិតម្ភៃឆ្នាំហើយកុសុមា! នាងក៏ដឹង នាងដឹងណាស់ថា ខ្ញុំចង់បានរបស់នោះណាស់ តែមួយម៉ាត់ក៏នាងមិននិយាយប្រាប់ខ្ញុំ! ក្នុងបេះដូងនាង ខ្ញុំនៅតែគ្មានតម្លៃស្មើនឹងអាពេជ្ររហូតមក!»
សក្ខណាធ្លាក់ថ្លើមក្តុកពេលឮប្រយោគចុងក្រោយនោះ។
«បុរសនេះជាស្អីទៅបានជាហ៊ានប្រៀបធៀបជាមួយប៉ានាង?»
ក្នុងពេលស្រីតូចកើតច្រាស់ច្រាល់ មិនដឹងថាគួរតែចេញទៅព្រមានបុរសនោះឬមួយទុកមុខឲ្យម្តាយធ្វើជា មិនដឹងរឿង.... នាងក៏ងាកសម្លឹងទៅម្តាយភ្លាមចាំមើលប្រតិកម្ម។
ទឹកមុខលោកជំទាវពោរពេញដោយភាពទើសទាល់និងគេចវេះធ្វើឲ្យសក្ខណាកើតឆ្ងល់។
«ស្អីអ៊ីចេះ? ម៉េចក៏អ្នកម៉ាក់យល់មុខតាចាស់នេះដល់ម្ល៉ឹង??? រាល់ដងអ្នកម៉ាក់ជាមនុស្សមានឫកពារបៀបរបបណាស់ កុំថាឡើយមកបញ្ចេញមនោសញ្ចេតនាយល់ចិត្តជាមួយគាត់ សូម្បីនិយាយក៏មិនងាយមើលមុខអ្នកណាដោយទឹកមុខរបៀបនេះដែរ?»
សំឡេង ហួត ស៊ីវ លាន់មកបន្តៈ
«ម្ភៃឆ្នាំមុនវាដណ្តើមនាងពីខ្ញុំ! ខ្ញុំស្មានតែថាវាបានតែរាងកាយនាង ហើយស្មានតែចិត្តនាងនៅជាមួយខ្ញុំរហូតមក! តែទើបតែដឹងពេលនេះថា នាងទុកឲ្យខ្ញុំឆ្កួតម្នាក់ឯងជាងម្ភៃឆ្នាំមកហើយ!»
លោកជំទាវក្រោករឹងចោលកៅអី ស្របពេលសក្ខណាហេងហាងក្នុងចិត្តស្ទើរតែទន់ជង្គង់ដួល។ អាថ៌កំបាំងដ៏អាម៉ាស់ដែលនាងទើបតែបានឮ ធ្វើឲ្យបេះដូងនាងស្ទើរតែគាំងចលនា។
សំឡេងអ្នកម្តាយបន្លឺឡើងក្នុងពេលអារម្មណ៍នាងងងឹតឈឹងៈ
«មនុស្សស្រីរៀបការត្រូវតែតាមប្តី ខ្ញុំប្រាប់លោកច្រើនដងហើយ វាមិនមែនជាកំហុសអ្នកណាទាំងអស់ អ្នកណាក៏ធ្លាប់មានអតីតកាលដែរ លោកត្រូវរៀនបំភ្លេចវា!»
ហួត ស៊ីវ ក៏ក្រោកឡើងដែរ គាត់និយាយខ្សោយៗតែសង្កត់ពាក្យធ្ងន់ៗៈ
«តែខ្ញុំបំភ្លេចនាងមិនបាន! ខ្ញុំបំភ្លេចអីក៏បាន! ប៉ុន្តែក្នុងចំណោមកូននាងបីនាក់ មានពីរនាក់ជាកូនរបស់ខ្ញុំទៅហើយ! ខ្ញុំមិនមែនចិត្តថ្មដូចនាងទេកុសុមា! បើនិយាយពីប្តី! ខ្ញុំទើបជាប្តីរបស់នាង!»

សក្ខណាទទួលអារម្មណ៍ដូចផែនដីបាក់ធ្លាក់សង្កត់ នាងយល់ថាខ្លួនឯងគ្មានអារម្មណ៍ដកដង្ហើមទេ នាងរត់គ្មានស្គាល់ទិសតំបន់ចេញឆ្ងាយពីមនុស្សចាស់ទាំងពីរនាក់ នោះ កាន់តែ

ឆ្ងាយកាន់តែល្អ។ សក្ខណាឡើងដល់រថយន្តតាំងពីពេលណាក៏មិនដឹងខ្លួន នាងបើករថយន្តចុះឡើងពេញទីក្រុងភ្នំពេញ ដោយដៃម្ខាងជូតទឹកភ្នែកទឹកសំបោរមិនចេះរីងស្ងួត។
ទោះបីនាងមកពីប្រទេសមួយ ដែលមនុស្សប្រកាន់យកនូវទស្សនបើកចំហ មិនរវល់រឿងឯកជនរបស់អ្នកណា ប៉ុន្តែការពិតរបស់ម្ដាយនាងមិនអាចឲ្យនាងទទួលយកបានជាដាច់ខាត។
តើអ្នកណាទៅនៅក្នុងចំណោមពួកយើងទាំងបី ដែលជាកូនរបស់បុរសមុខក្រាស់នោះ នាងសួរខ្លួនឯងហើយសួរទៀត យំហើយយំទៀត ទាល់តែខ្សោះកម្លាំងលែងអាចបើកឡានតទៅមុខទើបព្រមចតស្ងៀមនៅក្បែរ ផ្លូវ។
កណ្ដាលរាត្រីស្ងាត់ជ្រងំ ប៉ែន ពេជ្រសក្ខណា នៅសោយសោកម្នាក់ឯង អស់ចិត្តអស់ចង់ទើបបត់ឡានហួសទៅកាន់មន្ទីរពេទ្យ។
នៅពីក្រៅបន្ទប់ដែលឪពុកខ្លួនសម្រាន្ត នាងបង្អើបទ្វារលបមើលលោក ហើយថយមកឈរយំសាជាថ្មីអាណិតអ្នកមានគុណ។
«ប៉ា! បើប៉ាដឹងរឿងឆ្កួតអស់នេះ តើប៉ាឈឺចាប់យ៉ាងណាទៅ មិត្តសម្លាញ់របស់ប៉ាចិញ្ចឹមចិត្តលើភរិយារបស់ប៉ាជាយូរមកហើយ ហើយកូនរបស់ប៉ាបីនាក់ គេថាមានពីរនាក់ជាកូនរបស់គេ?»
នាងឃើញខ្លួនឯងនៅក្នុងផ្ទាំងកញ្ចក់មន្ទីរពេទ្យ ភ្នែកយំហើមជាំបើទុកឲ្យឪពុកនាងភ្ញាក់ដឹងខ្លួនមកឃើញ តើនាងអាចឆ្លើយនឹងសំណួររបស់លោកដោយវិធីណា។
ស្រីតូចពិតជាយល់ថា ខ្លួនគ្មានកន្លែងដែលត្រូវទៅមែននៅក្នុងយប់នេះ។
នាងនឹកឃើញដល់ ពៅបញ្ញា ប៉ុន្តែ ពៅបញ្ញា មិននៅភ្នំពេញទេ គឺជាប់បេសកកម្មនៅខេត្តដូច្នេះនាងគ្មានអ្នកដើម្បីនិយាយជាមួយឡើយ។
បើមិនទៅផ្ទះម្ដាយ គឺមានតែទៅផ្ទះឪពុក ស្រីស្អាតបរឡានយឺតៗទៅដល់គេហដ្ឋានរបស់ឪពុកក្នុងពេលយប់ជ្រៅណាស់ទៅហើយ។
«អ្នកនាងសក្ខណាយប់ម្ល៉េះ?»
អ្នកបម្រើវ័យចំណាស់ក្នុងផ្ទះរបស់ ពៅបញ្ញា ពោលសួរទាំងទឹកមុខស្លន់ស្លោ។
ទោះបីសក្ខណានិង ពៅបញ្ញា ត្រូវគ្នាចាក់ទឹកមិនលិច ប៉ុន្តែគេមិនដែលឃើញកូនស្រីពៅនៃផ្ទះភរិយាដើម មកលេងផ្ទះភរិយាទីពីរក្នុងវេលាថ្មើរណេះឡើយ។ ចុះបើពេលនេះនាងទុកឡានចោលច្រងាងមិនមាត់មិនក យួរកាបូបដើរយឺតចូលទៅក្នុងផ្ទះ មិនឲ្យស្ត្រីចំណាស់ទាំងពីរកើតសង្ស័យម្ដេចនឹងកើត?

មីងសែមលាន់មាត់សាជាថ្មីដោយកិរិយាគោរពខ្លាចចិត្ត៖

«អ្នកនាងពៅមិននៅទេ ប៉ុន្តែយប់ណាស់ហើយអ្នកនាងសក្ខណាសម្រាន្តនៅទីនេះហើយ កុំចេញទៅណាទៀត!»

សក្ខណាលាន់មាត់តបវិញខ្សឹបៗព្រោះគ្មានកម្លាំងកំហែង៖

«មីង ខ្ញុំសូមគេងនៅបន្ទប់ពៅបញ្ញាហើយ!»

ស្ត្រីចំណាស់តបវិញដោយគោរពឱនលំទោន៖

«ចាស! អញ្ជើញអ្នកនាង! ម៉ោះខ្ញុំជួយយកកាបូបទៅ!»

«មិនបាច់ទេមីងយប់ជ្រៅហើយ! មីងនាំគ្នាទៅសម្រាន្តចុះ បន្ទប់ពៅបញ្ញា ខ្ញុំស្គាល់ច្បាស់!»

ស្រីតូចដើរឃើតឆ្ពោះទៅជាន់ទីមួយ។ អ្នកបម្រើនាំគ្នាបិទភ្លើងភ្លឹប ពីក្រោយខ្នងធ្វើឲ្យផ្ទះដ៏ធំដែលស្ងាត់ជ្រងំស្រាប់ទៅហើយនោះ កាន់តែស្ងាត់លើសមុនទៅទៀត ព្រោះងងឹតស្លុប។ ជើងនាងឈានស្រាលលើកម្រាលព្រំតម្រង់ទៅបន្ទប់ប្អូនស្រីម្តាយទីទៃ ចៃដន្យអីទ្វារបន្ទប់មិនបានបិទជិតឡើយ។ នាងជ្រួញចិញ្ចើមរវើក្អែកសម្លឹងទៅខាងក្នុងដែលស្ទើរងងឹតស្ទើរភ្លឺ ព្រោះអ្នកដែលកំពុងនៅខាងក្នុងបន្ទប់ហាក់គ្មានចេតនាបើកភ្លើង បំភ្លឺពេញទំហឹងទេ។

តាមប្រឡោះប្រមាណបីធ្អាប់ ដៃស្រីតូចឃើញខ្នងបុរសម្នាក់កំពុងឈរអានអ្វីម្យ៉ាងមានសណ្ឋានដូច ជាសន្លឹកក្រដាសច្រើនសន្លឹក ដោយបែរមុខទៅរកមាត់បង្អួច។ ដោយសារជួបបុរសនេះកាលណាមានរឿងក្តៅចិត្តកាលនោះ ដូច្នេះនាងនៅចំណាំគេបាន។ ស្រីតូចដកថយចេញពីទីនោះទាំងចោទសួរក្នុងចិត្តខ្លួនឯងស្ងាត់ៗ៖

«យើងពិបាកចិត្ត រហូតដល់ច្រឡំបន្ទប់ពៅបញ្ញា?»

នាងដើរបកក្រោយឆ្ពោះមកកាន់កាំជណ្តើរវិញ ស្របពេលអ្នកបម្រើស្រីដដែលលើកភេសជ្ជៈមួយកែវមកដល់។

សក្ខណាពោលសួរខ្សឹបៗទាំងមួហ្មង៖

«ហើយមីង? ម្នាក់ហ្នឹងដល់ថ្នាក់មកនៅផ្ទះនេះហើយអ្ហេះ?»

ដំបូងអ្នកបម្រើរៀងឡិងឡង់មិនដឹងនាងចង់សំដៅលើអ្នកណា តែបន្ទាប់មកគាត់ក៏នឹកឃើញដល់ជំនួយការវិទ្ធិដែលទើបតែត្រលប់មក ពីមន្ទីរពេទ្យ គាត់ឆ្លើយតបវិញ៖

«អូ ជំនួយការវិទ្ធិ? គាត់ទើបតែស្នាក់នៅផ្ទះនេះមួយរយៈពេលដែលលោកឧកញ៉ាធ្លាក់ខ្លួនឈឺ ព្រោះអ្នកនាងពៅយល់ថាយើងមិនមានមនុស្សប្រុសគ្រាន់នឹងបានពឹង ពាក់!»

សក្ខណាខាំមាត់ព្រោះទទួលអារម្មណ៍ថាធុញទ្រាន់ សូម្បីតែឮឈ្មោះបុរសនេះ។ នាងទទួលកែវទឹកពីដៃអ្នកបម្រើហើយដេញគាត់ឲ្យទៅសម្រាកសាជាថ្មី។
សក្ខណាបែរក្រោយដើរត្រលប់មករកបន្ទប់គេងវិញ ហើយមិនខ្ចីទាំងងាកមើលបន្ទប់ពៅបញ្ញា ដែលរិទ្ធិកំពុងមានវត្តមាននៅ ទីនោះ ដើម្បីស្វែងរកភស្តុតាងនៃគម្រោងការរតនៈសោភ័ណ។ ដូច្នេះនាងបង្ហួសទៅកាន់បន្ទប់ផ្សេងមួយទៀត ដែលតាមពិតទីនោះទើបបន្ទប់ជាបន្ទប់របស់ជំនួយការនេះ។

ក្នុងភាពធ្លាក់ទឹកចិត្តនិងល្វើយហួសហេតុនាងបិទទ្វារទៅវិញ ដោយមិនខ្ចីទាំងចុចភ្លើងបើក ពន្លឺភ្លើងជះពីខាងក្រៅមកតាមចន្លោះវាំងននមាត់បង្អួច ដែលបិទមិនទាន់ជិតបានបង្ហាញគ្រែដំណេកធំច្រងាងមួយ នាងបោះកាបូបទៅលើគ្រែនោះហើយទាញវាំងននបិទបង្អើយ ធ្វើឲ្យផ្ទៃបន្ទប់ទាំងមូលទៅជាងងឹតសូន្យសុង។
សក្ខណាទម្រេតខ្លួនទៅលើគ្រែទាញភួយដណ្តប់ មិនរវល់សូម្បីតែថាក្លិនទឹកអប់សេសសល់ក្នុងបន្ទប់នេះ មិនមែនជាក្លិនមនុស្សស្រីក៏ដោយ។ ពេលវេលារំលងទៅក្នុងភាពទុក្ខសោកនិងស្ងាត់សូន្យឈឹង សក្ខណាលង់លក់សន្សឹមៗនៅក្រោមការបបោសអង្អែលដោយចំហាយម៉ាស៊ីន ត្រជាក់។ នាងមិនបានដឹងទេថា ម្ចាស់បន្ទប់ពិតប្រាកដកំពុងដើរវិលត្រលប់មកវិញទាំងហត់នឿយនិងរក កន្លែងសម្រាកដូចគ្នា។
អ្នកប្រុសទីពីរ ហួត ខេមរិទ្ធិ ដែលតឹងតែងក្តុកក្តួលចិត្តពេញមួយថ្ងៃ ក្រោយពីបានដឹងការពិតនៃប្រវត្តិដ៏ក្រៀមក្រំរបស់គម្រោងធុរកិច្ច មានតែឈ្មោះគ្មានការពិតនោះ គេប្រាស់ខ្លួនទៅលើគ្រែដូចសព្វដងក្នុងពេលរាងកាយទាំងមូលពិតជា ហត់នឿយដល់កម្រិត ប៉ុន្តែខួរក្បាលនៅច្របូកច្របល់ជាមួយបញ្ហាជាច្រើនជំពូក។
គេខំធ្មេចភ្នែកបង្ខំរាងកាយឲ្យសម្រាក...។
ពីរបីនាទីរំលងទៅដៃអ្នកណាម្នាក់ទន់ល្មើយលើកគងមកលើខ្នងគេ ធ្វើឲ្យភ្នែកអ្នកប្រុសទីពីរដែលខំសម្ងំបិទបើកខ្វាកមកវិញដោយ ស្វ័យប្រវត្តិ.....
ជួបរឿងជាច្រើនពេញមួយថ្ងៃបេះដូងនៅញាប់ញ័រមិនទាន់បាត់បែរជា កណ្តាលរាត្រីងងឹត ហើយក្នុងទីដំណេកខ្លួនឯងផ្ទាល់ ស្រាប់តែទទួលអារម្មណ៍ថាមានមនុស្សម្នាក់ផ្សេងទៀត កំពុងមានវត្តមាន ក្បែរ តើប្រតិកម្មបែបណាដែលគេនឹងបញ្ចេញឡើងក្នុងពេលនេះ?។
អ្នកប្រុសទីពីររបស់ ហួត ស៊ីវ បែរក្រោយរហ័ស ដូចផ្លេកបន្ទោរហើយយាជើងធាក់រាងកាយ

ដែលនៅពីក្រោយខ្លួនរបូតខ្ទាក ទៅលើឥដ្ឋ។
ព្រមជាមួយនោះគេស្ទុះភ្លែតតម្រង់មាត់ទ្វារលូកដៃចុចកុងតាក់ភ្លើងបើក។
ពន្លឺអគ្គិសនីបំភ្លឺពេញផ្ទៃបន្ទប់បង្ហាញរូបរាងមនុស្សម្នាក់តូច ច្រឡឹងរមូរក្នុងភួយក្រាសធំកំពុងកម្រើកតិចៗ ហាក់បីដូចជាភ្ញាក់ពីដំណេក។ ទោះបីកម្រាលព្រំនៃផ្ទះត្រកូលអភិជននោះក្រាស់ឃ្មឹកអាចជួយឲ្យសក្ខណា ជៀសផុតពីការឈឺចាប់ ដែលត្រូវមួយជើងខ្ទាតចុះពីលើគ្រែយ៉ាងដំណំ ប៉ុន្តែមិនអាចបន្តជួយទ្រនាងឲ្យដេកលក់តទៅទៀតបានឡើយ ដូច្នោះហើយគេឮសូរសម្រែកដោយតក់ស្លុតរបស់នាង នៅពេលដែលបើកភ្នែកឡើងកាលណាឃើញបុរសដែលនាងមិនចូលចិត្ត កំពុងឈរស្រឡាំងកាំងក្បែរទ្វារ ហើយខ្លួនឯងដួលច្រងាប់ច្រងិលទៅលើឥដ្ឋ។

នៅក្នុងរថយន្តសក្ខណារំលឹករឿងរ៉ាវកាលពីយប់ប្រាប់ពៅបញ្ញាទាំងសៅហ្មង។ នាងបញ្ចប់ប្រយោគចុងក្រោយដោយភ្នែកសម្លក់កញ្ចក់ឡាន៖
«នេះហើយជាស្នាដៃបងរិទ្ធិដ៏ល្អរបស់ឯង!»
ពៅបញ្ញាទើបត្រលប់មកពីខេត្ត ដំបូងនាងមកដល់ភ្លាម ឃើញកន្ទុយឡានរិទ្ធិចាកចេញរ៉េវហើយសួរអ្នកបម្រើទើបដឹងពីរឿងប្រទូសរ៉ាយគ្នាជាមួយសក្ខណា។ នាងបារម្ភណាស់ព្រោះងាកទៅបងស្រីខុសម្ដាយក៏បម្រុងនឹងចាកចេញ ដូចគ្នានឹងភាគីខាងប្រុសដែរ មេធាវីស្រីគិតថាទំនាស់រវាងពួកគេប្រហែលធំដុំស្រាយលែងចេញហើយ បានជាខំស្រូតរត់មកឡើងឡានសក្ខណាតាមនិយាយសម្រន់កំហឹងនាងដឹងអី ពេលមកស្ដាប់ចប់បែរជាអស់សំណើចទប់មិនជាប់។
សក្ខណាងាកមកសម្លឹងនាង ដោយទឹកមុខងរង៉ក់។ ដៃស្រីតូចផ្ទះជំទាវកុសុមា កាន់ចង្កូតបើកឡានបណ្ដើរមាត់និយាយបណ្ដើរ៖
«សប្បាយចិត្តណាស់ហើយ ឃើញខ្ញុំត្រូវមួយជើងខ្ទាតទៅដល់ឥដ្ឋ!»
ពៅបញ្ញាលើកដៃរាវស្រឡូនខ្ទប់មាត់សើច ។ សកម្មភាពនាងកាន់តែធ្វើឲ្យសក្ខណានឹកឃើញមុខបុរសនោះហើយនឹកឃើញថា យ៉ាងណាប្អូនស្រីច្បាស់ជាកាន់ជើងគេ ដូច្នេះនាងក៏កាន់តែមួហ្មងថែមឡើង។
នាងនិយាយបន្ថែមភ្លាម៖
«នេះកុំតែយល់ឯងទេ កុំអីខ្ញុំនិយាយជាមួយប៉ូលិសតែម្ដង!»

តាមពិតទៅ ពៅបញ្ញា ខំទប់សំណើចព្រោះថាខ្លាចខ្លួនកាន់តែសើចធ្វើឲ្យសក្ខណាកាន់តែខឹង ។ ពេលនេះឃើញនៅតែខឹង នាងឆ្លើយតបវិញតិចៗសម្រួលបរិយាកាសៈ

«មកពីឯងដែរ! បន្ទប់ខ្ញុំមិនដេកឯងទៅដេកអីបន្ទប់គេ?»

មកដល់ត្រង់ណេះ សក្ខណាបើកភ្នែកមូលក្លំងាកមកមើលប្អូនស្រីរបស់នាង។ និយាយពីរឿងបន្ទប់ទាំងពីរនោះ ហាក់បីដូចជាកំពុងជួយនាងឲ្យនឹកឃើញពីរឿងអ្វីម្យ៉ាងយ៉ាង សំខាន់។ ស្រីស្អាតក៏និយាយកាត់ ពៅបញ្ញា ភ្លាមៈ

«ឈប់! ឈប់! ខ្ញុំទើបតែនឹកឃើញ បើសិននោះមិនមែនជាបន្ទប់របស់គេហេតុអីខ្ញុំបើកទ្វារទៅឃើញគេឈរ នៅទីនោះ? មានតែគេលបចូលបន្ទប់ឯង តើគេចូលមកធ្វើអីនៅទីនោះ?»

«ឯងក៏បាននិយាយដែរថាពេលនោះងងឹត ហើយឯងកំពុងស្មុគស្មាញក្នុងចិត្តផងឯងច្បាស់ជាមើលច្រឡំហើយអ្នកនាង! បងរិទ្ធិគោរពគេណាស់ជាពិសេសមនុស្សស្រី គាត់មិនធ្វើអញ្ចឹងទេ!»

«ប៉ុន្តែ.....! អូខេបាន! ខ្ញុំអត់ភស្តុតាងខ្ញុំអត់មានអីនិយាយទេ មិនមែនមកពីគេលេងខ្ញុំមួយជើង ខ្ញុំខឹងគេហើយមកនិយាយតាមចិត្តឯណា! នេះគឺឯងនឹងលោកប៉ាតែពីរនាក់ម៉ង ក្បែរមនុស្សដែលខ្ញុំមិនទុកចិត្ត បានជាខ្ញុំប្រឹងប្រាប់ឯង!»

«តែយើងក៏គ្មានអីត្រូវគិតធ្ងន់ធ្ងរយ៉ាងហ្នឹងដែរសក្ខណា! និយាយរួមបន្ទប់ខ្ញុំអត់មានអីអាថ៌កំបាំងទេ!» ខ្ញុំទម្លាប់មានតុធ្វើការនៅហ្នឹង ជជែកគ្នានៅហ្នឹង មិនថាតែគាត់ទេ បងវណ្ណៈក៏ចេញចូលបានដូចគ្នា!ឯងគិតអគតិពីគេពេកហើយដឹង?»

សក្ខណាកាន់តែគ្នាន់ក្នាញ់នាងរអ៊ូៈ

«ខ្ញុំមិនដឹងថាអាគាត់នោះ ឲ្យឯងនិងលោកប៉ាលេបថ្នាំអីទេ! និយាយរួមគ្មានអីគួរឲ្យទុកចិត្តបន្តិចសោះ ថ្ងៃនេះខ្ញុំនិយាយឯងមិនជឿថ្ងៃណាមួយឯងគួរតែដឹង»

ពៅបញ្ញា ធ្មេចភ្នែកដកដង្ហើមយូរ មើលទៅនាងចង់ដូរប្រធានបទ ព្រោះសក្ខណាមិនអាចពន្យល់បានទេនៅក្នុងពេលនេះ។ មេធាវីនិយាយពីរឿងផ្សេងវិញៈ

«ឈប់ហ្គាវ៉ាសសាំងនោះទៅ! សុំចូលលុបមុខបន្តិច!»

ពៅបញ្ញាចូលទៅក្នុងបន្ទប់ទឹក ទុកឲ្យសក្ខណានៅអង្គុយចាំក្នុងរថយន្តម្នាក់ឯង។

មិនដល់១នាទីស្រួលបួលផងបុរសម្នាក់ដើរកាត់ពីមុខនាងរឹងធ្វើឲ្យ នាងបើកភ្នែកធំៗដោយភ្ញាក់ផ្អើល។ គេចេញពីហាងកាហ្វេលំដាប់អភិជនមួយចម្ងាយមិនដល់ ៥០ ម៉ែត្រពីទីនោះឡើយ។ គេកាន់កាហ្វេក្នុងដៃ ប្តូរសំលៀកបំពាក់ ខុសពីប៉ុន្មានម៉ោងមុននេះ ហើយដើរញាប់ជើង

តម្រង់ឡើងរថយន្តដ៏ទំនើបមួយ។
នោះមិនមែនជារថយន្តដែលនាងធ្លាប់ឃើញនៅផ្ទះឪពុកខ្លួនទេ ក៏មិនមែនជារថយន្ត ពៅ បញ្ញា ឬអ្នកណាៗក្នុងគ្រួសារ ប៉ែន ពេជ្រ ដែរ ប៉ុន្តែជាប្រភេទរថយន្តដ៏មានតម្លៃខ្ពស់ ចុះចម្លែកអីគឺអ្នកជិះនោះគឺជំនួយការរិទ្ធិដែលនាងទើបតែមាន រឿងជាមួយកាលពីយប់មិញ?។
«ម្នាក់នេះនៅសុខៗបានឡានពីណាមកថ្លៃម្ល៉េះ? ក្រែងគេជាជំនួយការលោកប៉ាស្លៀកពាក់សំលៀកបំពាក់ធ្វើការជានិច្ច? ម៉េចក៏ព្រឹកនេះស្លៀកពាក់ដូចស្ទាវហើយមានវ៉ែនតាខ្មៅទៀត? ហើយផឹកកាហ្វេថ្លៃសម្បើមម៉េះ? ប្រាក់ខែប៉ុន្មានដុល្លារទៅ? មនុស្សមកពីណាមិនដឹង នៅមុខលោកប៉ាឫកពាផ្សេង ដល់ជួបតាមផ្លូវឫកពាផ្សេង ថាមិនត្រូវបានអ្នកណាម្នាក់ទិញក្បាលឲ្យឡានទំនើបជិះដើម្បីចូល មកបំផ្លាញលោកប៉ាផងក៏ថាបាន?»

គិតចប់កាលណា នារីបញ្ឆេះរថយន្តរបស់ខ្លួនហើយជិះតាមតិចៗពីក្រោយដោយមិនដឹងថាខ្លួនបានបោះបង់ចោលប្អូនស្រីនៅកណ្ដាលផ្លូវ។
រថយន្តរបស់អ្នកប្រុសទីពីរបត់វឹងចូលទៅរកផ្លូវជាតិលេខបួន ហើយបំបោលឆ្ពោះទៅក្រៅក្រុង។ ស្រីតូចបន្តទៅតាមនាយ កាន់តែឆ្ងាយនាងកាន់តែចង់ដឹង។
«គេមកជួបអ្នកណាឆ្ងាយយ៉ាងនេះ?»
ប្រហែលជិតមួយម៉ោង ដែលសក្ខណាអត់ធ្មត់បានក្នុងការតាមដានអ្នកប្រុសទីពីរ ព្រោះតែនាងចង់បញ្ជាក់ថាការគិតរបស់ខ្លួនដែលសង្ស័យគេជាមនុស្ស អាក្រក់ត្រូវគ្មានខុសនោះមិនបានឲ្យស្រីតូចនឿយណាយក្នុងការតាម ពីក្រោយបុរសនេះទេ ស្រាប់តែនាងឃើញរិទ្ធិបន្ថយល្បឿន នៅក្បែរផ្លូវបត់ចូលទីលានកូនគោលមួយ។
ស្រីស្អាតឈប់ឡានតក់ក្រហល់ព្រោះខ្លាចគេដឹងថានាងតាម ឯចិត្តក៏កាន់តែផុសឡើងនូវក្ដីសង្ស័យ៖
«ស្អីគេនៀក? លេងកូនគោលចាំបាច់មកឆ្ងាយម្លឹងដែរ? នៅភ្នំពេញអត់មាន?»
រិទ្ធិបត់ទៅក្នុងមណ្ឌលវាយកូនគោលដែលជារឿយៗ គេតែងមានសុវត្ថិភាពក្នុងការលួចលាក់ជួបជាមួយឪពុកធម៌ខ្លួន។

គេចុះពីលើរថយន្តទាំងមិនដឹងខ្លួនថាស្រីស្អាតអ្នកបើករថយន្ត ដ៏ចំណាប់មកពីអាមេរិកតាមគេពីក្រោយប្រកបដោយប្រសិទ្ធភាពមិនមាន ដានអ្វីបន្តិចដូច្នេះឡើយ ព្រោះក្នុងបេះដូងគេពេលនេះ កំពុងផ្ដោតតែលើការដោះស្រាយទំនាស់ដ៏យូរយាររវាងមិត្តសម្លាញ់វ័យ ចំណាស់ទាំងទ្វេ

តែប៉ុណ្ណោះ។
គេនាំរាងកាយស្រស់សង្ហាក្នុងសំលៀកបំពាក់កីឡាដ៏ស៊ីវិល័យតាមបែប អភិជនឆ្ពោះទៅទីលានខាងក្នុង ល្មមពេលរថយន្តដ៏ទំនើបមួយផ្សេងទៀតបោលមកដល់រឹង ហើយទ្វាររបើកខ្វាកបង្ហាញរូបរាងអគ្គទេសាភិបាល ហួត ស៊ីវ ចុះមកច្បាស់នៅនឹងភ្នែក។
ស្រីតូចសក្ខណាស្ទើរស្រក់ឈាមតាមភ្នែកនិមិត្តតែនាងឃើញរិទ្ធិងាក ទៅឱនលំទោនទទួលបុរសនោះ។ សំណុំឯកសារមួយក្នុងដៃរបស់រិទ្ធិធ្វើឲ្យនាងរំលឹកឡើងវិញពីកាល ដែលគេលបលួចឈរអានអ្វីមួយទាំងមិនបានបើកភ្លើងក្នុងបន្ទប់ប្អូន ស្រីពៅខ្លួនកាលពីយប់មិញនោះឡើងវិញ។ ភ្លាមៗនាងចាប់អារម្មណ៍ថាមនុស្សប្រុសម្នាក់នេះ គ្រោះថ្នាក់ពេកហើយ គេឆ្លៀតពេលប៉ានាងមិននៅប្អូនស្រីនាងទៅខេត្តគេក៏ចូលរុករើ បន្ទប់ពៅបញ្ញាស្វែងរកឯកសារអ្វីក៏មិន ដឹងហើយពេលនេះមិនដឹងជារបស់អ្វីទៅដែលគេកំពុងមានក្នុងដៃនោះ? គេលួចវាមកឲ្យ ហួត ស៊ីវ ឬអ្វី? ហើយតើវានឹងនាំទុក្ខទោសដល់ឪពុកខ្លួន ប្អូនស្រីខ្លួនដែរឬទេនោះក៏មិនទាន់ដឹង។ ម្យ៉ាងសក្ខណា ទើបតែកាលពីព្រលប់មុននេះនាងលបឮរឿងអាថ៌កំបាំងមួយចំនួនរវាង ហួត ស៊ីវ និងម្ដាយដែលបង្ហាញច្បាស់ថាបុរសចំណាស់ដ៏មានទ្រព្យនេះមិនបានទុក ឪពុកខ្លួនជាមិត្តទៀតផងនាងកាន់តែឆេះឆួលក្នុងចិត្ត។
«វីវរហើយ! មនុស្សមានពុតនេះ ជាបក្សពួករបស់តាកំហូចនេះមែន!!!! បាន!! លោកឯងស៊យហើយមកប៉ះសក្ខណា! ចាំមើលលោកឯងមានអីអាចបកស្រាយលាងខ្លួនបាន?»
នាងលូកដៃទៅក្នុងកាបូបរាវរកទូរសព្ទទើបនឹកឃើញថាទូរសព្ទរបស់ ខ្លួនគ្មានថ្មទេ ចំណែកមួយដែលនាងប៉ះនេះជាទូរសព្ទរបស់ពៅបញ្ញា។ មិនខ្វល់ច្រើន ទូរសព្ទអ្នកណាក៏ដោយសំខាន់គឺនាងត្រូវតែថតឲ្យបានរូបភាពរបស់ ជំនួយការរិទ្ធិនៅជាមួយ ហួត ស៊ីវ។
ស្រីតូចចុះពីលើរថយន្តថ្នមៗ ដៃត្រៀមរួចរាល់ទៅលើទូរសព្ទហើយចាប់ផ្ដើមចុចថតសកម្មភាពឪពុកកូន ទាំងទ្វេ ដែលកាន់តែទៅហួសឆ្ងាយទៅហើយ ដើម្បីបានរូបភាពច្បាស់នាងត្រូវតែក្លាហានដើរទៅមុខមួយជំហានហើយ មួយជំហានទៀត តែមិនយូរប៉ុន្មានបាទដៃធំមួយលូកមកក្ដោបមាត់នាងពីក្រោយជាប់ ហើយក្លិនអ្វីម្យ៉ាងឆួលចម្លែកបានធ្វើឲ្យនាងទន់ជើងជាបណ្ដើរៗ រហូតដល់លែងដឹងខ្លួន។